# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ




# ផែនការជាតិ ៣ឆ្នាំ ស្តីពី ការត្រួតពិនិត្យគ្រឿងញៀន ២០១៣-២០១៥

## អ.ជ.ប.គ.ញ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
លេខៈ ៧០៣ សជណ

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**គោរពជូន**
**ឯកឧត្តម នាយឧត្តមសេនីយ៍ កែ គឹមយ៉ាន ឧបនាយករដ្ឋមន្ត្រី និងជា**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**កម្មវត្ថុ** ៖ ករណីសំណើសុំពិនិត្យ និងសម្រេចលើសេចក្តីព្រាងផែនការជាតិ ០៣ ឆ្នាំ (២០១៣-២០១៥) ស្តីពីការត្រួតពិនិត្យ គ្រឿងញៀន ។

**យោង** ៖ -លិខិតលេខ ០១៦ /ល.ស ១៣ អ.ជ.ប.គ.ញ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៣ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
-ចំណាររបស់សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០១៣ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រី សូមជំរាបជូនឯកឧត្តម មេត្តាជ្រាបថា ៖ ចំពោះករណីនេះ រាជរដ្ឋាភិបាលបានសំរេចឯកភាពតាមសេចក្តីព្រាងផែនការជាតិ ០៣ ឆ្នាំ (២០១៣-២០១៥) ស្តីពីការត្រួតពិនិត្យ គ្រឿងញៀន ។

សេចក្តីដូចបានជំរាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែង អនុវត្តតាមការគួរ ។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ប្រាក់ សុខុន**

ចម្លងជូន ៖
-ក្រសួងមហាផ្ទៃ
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងផែនការ
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់សាលាខេត្ត-រាជធានី
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**
លេខ : ០១៦/១៣ ...អ.ជ.ប.គ.ញ

*រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែ កុម្ភៈ ឆ្នាំ២០១៣*

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**
**នៃព្រះរាជាណាចក្រកម្ពុជា**

***ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!***

**កម្មវត្ថុ:** សំណើសុំពិនិត្យ និងសម្រេចលើសេចក្តីព្រាងផែនការជាតិ ០៣ឆ្នាំ (២០១៣-២០១៥) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាជ្រាបថាៈ បន្ទាប់ពីបានអនុវត្តផែនការជាតិ ៥ឆ្នាំ (២០០៥-២០១០) និង ផែនការសកម្មភាពឆ្នាំ ២០១១ និង ២០១២ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ទទួលបានលទ្ធផលគួរអោយកត់សំគាល់ក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ។ ទន្ទឹមនឹងនេះក៏នៅមានបញ្ហាមួយចំនួនត្រូវបន្តដោះស្រាយជាបន្តបន្ទាប់ ដែលតម្រូវការចាំបាច់ក្នុងការរៀបចំផែនការជាតិបន្ត ដើម្បីត្រួតពិនិត្យគ្រឿងញៀន នៅកម្ពុជា ។

.ការរៀបចំផែនការជាតិ ០៣ឆ្នាំ ស្តីពីការត្រួតពិនិត្យគ្រឿងញៀននេះ គឺដើម្បីបន្តអនុវត្តយុទ្ធសាស្រ្ត និងផែនការសកម្មភាពដែលមិនទាន់បានសំរេចក្នុងកំឡុងឆ្នាំ ២០០៥-២០១២ ព្រមទាំងដាក់ចេញនូវវិធានការយុទ្ធសាស្រ្តចំនួន ០៧ ដើម្បី គាំទ្រ និងជំរុញការអនុវត្តយន្តការពហុវិស័យស្តីពីការត្រួតពិនិត្យគ្រឿងញៀន អោយកាន់តែមានប្រសិទ្ធភាព ។

ផែនការនេះ បានទទួលការឯកភាពពីក្រសួង ស្ថាប័ន សមាជិក អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅក្នុងកិច្ចប្រជុំអាជ្ញាធរជាតិ កាល ពីថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១២ នៅទីស្តីការក្រសួងមហាផ្ទៃ ។

អាស្រ័យហេតុនេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ស្នើសុំ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាពិនិត្យ និងសំរេច លើផែនការជាតិ ០៣ ឆ្នាំ (២០១៣-២០១៥) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដូចមានជូនភ្ជាប់ ដើម្បីយកទៅអនុវត្ត និងធ្វើជាមូលដ្ឋានក្នុងការរៀបចំកម្មវិធីសុំជំនួយអន្តរជាតិនានាពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុត អំពីខ្ញុំបាទ ។

14-2.13

**ឧបនាយករដ្ឋមន្ត្រី**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

នាយឧត្តមសេនីយ៍ **កែ គីមយ៉ាន**

# អារម្ភកថា

ព្រះរាជាណាចក្រកម្ពុជាបាននិងកំពុងទទួលផលពីសន្តិភាព និងឯកភាពទឹកដីដ៏ពេញលេញដែលកើតចេញមកពីនយោបាយ "ឈ្នះ-ឈ្នះ" របស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ តាមរយៈកំណើនសេដ្ឋកិច្ចជាប្រចាំ និងការកាត់បន្ថយភាពក្រីក្រជាបណ្តើរៗ កម្ពុជាបានធ្វើសមាហរណកម្មខ្លួន និងកំពុងដើរតួនាទីយ៉ាងសកម្មក្នុងអនុតំបន់ តំបន់ និងពិភពលោក។

រាជរដ្ឋាភិបាលបានដាក់ចេញ និងប្តេជ្ញាអនុវត្តន៍ឱ្យបានជោគជ័យនូវ "យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២" ដែលជា "របៀបវារៈគោលនយោបាយសង្គមសេដ្ឋកិច្ច" ដើម្បីកំណើនការងារសមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា សំដៅសម្រេចឱ្យបាននូវគោលដៅជាអាទិភាព៤យ៉ាងនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤ នៃរដ្ឋសភា។

ផែនការជាតិ៣ឆ្នាំ ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ ២០១៣-២០១៥ ដែលបានរៀបរៀងឡើងនាពេលនេះ នឹងដើរតួជាត្រីវិស័យសម្រាប់ចង្អុលទិសដៅទៅដល់បណ្តាក្រសួង ស្ថាប័ន សមាជិក អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិដើម្បីយកទៅអនុវត្តន៍។

ផែនការជាតិនេះ នឹងបន្តជម្រុញឱ្យកាន់តែខ្លាំងក្លាថែមទៀតយន្តការត្រួតពិនិត្យសកម្មភាពគ្រឿងញៀនខុសច្បាប់នៅកម្ពុជា ដើម្បីកាត់បន្ថយនិងឈានទៅលុបបំបាត់ទាំងស្រុងនូវការដាំដុះ ការផលិត ការរក្សាទុក ការជួញដូរ ការចែកចាយ និងការប្រើបំពានគ្រឿងញៀននៅកម្ពុជា រួមចំណែកក្នុងការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលឱ្យទទួលបានជោគជ័យ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមវិភាគទានរបស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ជាសមាជិកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនទាំងអស់ ហើយសូមកោតសរសើរដល់ក្រុមការងារ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងក្រសួង ស្ថាប័ន ពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍នានា ដែលបានខិតខំយ៉ាងសកម្មរហូតធ្វើឱ្យសម្រេចបាននូវផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន (ឆ្នាំ២០១៣-២០១៥) នេះឡើង។

ជាពិសេសបំផុត ខ្ញុំសូមសំដែងនូវកតញ្ញូតាធម៌ដ៏ខ្ពង់ខ្ពស់បំផុតចំពោះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ដែលតែងតែយកចិត្តទុកដាក់ដឹកនាំ គាំទ្រ និង លើកទឹកចិត្តជាបន្តបន្ទាប់ដល់រាល់គ្រប់សកម្មភាពត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ ២០១៣

ឧបនាយករដ្ឋមន្ត្រី

ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន



នាយឧត្តមសេនីយ៍ កែ គឹមយ៉ាន

## មាតិកា

ទំព័រ


អារម្ភកថា..................................................................១

ពាក្យសង្ខេប និងអត្ថន័យពាក្យសង្ខេប..................................................................៥

ពន្យល់ពាក្យបច្ចេកទេស..................................................................៧

សេចក្តីផ្តើម..................................................................៩

**ជំពូកទី ១ ស្ថានភាពទូទៅ**..................................................................១៣

១. ស្ថានភាពភូមិសាស្ត្រ និងប្រជាជន..................................................................១៣

១.១. ទីតាំងភូមិសាស្ត្រ..................................................................១៣

១.២. ព្រំប្រទល់ប្រទេស..................................................................១៣

១.៣. សណ្ឋានដី..................................................................១៣

១.៤. អាកាសធាតុ..................................................................១៤

១.៥. ស្ថានភាពប្រជាជន សាសនា ទំនៀមទម្លាប់..................................................................១៤

២. របបនយោបាយ រចនាសម្ព័ន្ធរដ្ឋបាល សេដ្ឋកិច្ច និងសង្គមកិច្ច..................................................................១៤

២.១. របបនយោបាយ..................................................................១៤

២.២. រចនាសម្ព័ន្ធរដ្ឋបាល សេដ្ឋកិច្ច និងសង្គមកិច្ច..................................................................១៥

៣. ស្ថានភាពគ្រឿងញៀន..................................................................១៥

៣.១. ស្ថានភាពគ្រឿងញៀនក្នុងតំបន់ និងលើសកលលោក..................................................................១៥

៣.១.១. ការដាំដុះ និងការផលិតគ្រឿងញៀន..................................................................១៥

៣.១.២. ការជួញដូរ..................................................................១៦

៣.១.៣. ការប្រើប្រាស់..................................................................១៧

៣.២. ស្ថានភាពគ្រឿងញៀនក្នុងប្រទេស..................................................................១៧

៣.២.១. កញ្ឆា..................................................................១៧

៣.២.២. គ្រឿងញៀនសំយោគ..................................................................១៨

៣.២.៣. ហេរ៉ូអ៊ីន..................................................................១៨

៣.២.៤. សារធាតុគីមីផ្សំ..................................................................១៩

៣.២.៥. ការប្រើប៉ានគ្រឿងញៀន..................................................................១៩

ជំពូកទី ២ សមិទ្ធិផល ចំណុចខ្លាំង ចំណុចខ្សោយ និងចំណុចប្រឈម ក្នុងការអនុវត្តផែនការជាតិ ៥ឆ្នាំ ២០០៥-២០១០និងផែនការសកម្មភាព ឆ្នាំ២០១១-២០១២.....២១
១. សមិទ្ធិផល.....២១
១.១. ការងារពង្រឹងស្ថាប័ន.....២១
១.២. ការកាត់បន្ថយតម្រូវការគ្រឿងញៀន.....២៣
១.៣. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន.....២៧
១.៤. ការពង្រឹងប្រសិទ្ធភាពព្យាបាល ស្តារនីតិសម្បទា សមាហរណកម្ម.....២៨
១.៥. ការពង្រឹងប្រសិទ្ធភាពអនុវត្តន៍ច្បាប់.....៣០
១.៦. ការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ.....៣២
១.៦.១. កិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយប្រទេសជាប់ព្រំដែន.....៣២
១.៦.២. កិច្ចសហប្រតិបត្តិការជាមួយអន្តរជាតិ.....៣២
១.៦.៣. កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា.....៣៣
២. ចំណុចខ្លាំង.....៣៤
២.១. ការងារពង្រឹងស្ថាប័ន.....៣៤
២.២. ការកាត់បន្ថយតម្រូវការគ្រឿងញៀន.....៣៥
២.៣. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន.....៣៥
២.៤. ការពង្រឹងប្រសិទ្ធភាពព្យាបាល ស្តារនីតិសម្បទា សមាហរណកម្ម.....៣៥
២.៥. ការពង្រឹងប្រសិទ្ធភាពអនុវត្តន៍ច្បាប់.....៣៦
២.៦. ការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ.....៣៦
៣. ចំណុចខ្សោយ.....៣៦
៤. ចំណុចប្រឈម.....៣៨
ជំពូកទី ៣ គោលការណ៍ គោលបំណង យុទ្ធសាស្ត្រនិងវិធានការយុទ្ធសាស្ត្រ.....៣៩
ក. គោលការណ៍.....៣៩
ខ. គោលបំណង.....៣៩
គ. យុទ្ធសាស្ត្រ.....៣៩
ឃ. វិធានការយុទ្ធសាស្ត្រ.....៤០
ជំពូកទី ៤ កម្មវិធីសកម្មភាពសម្រាប់អនុវត្តន៍វិធានការយុទ្ធសាស្ត្រ.....៤១

**ជំពូកទី ៥ តម្រូវការធនធាន និងហិរញ្ញវត្ថុ**........................................៥៨
១. តម្រូវការធនធាន........................................៥៨
២. តម្រូវការហិរញ្ញវត្ថុ........................................៥៨
២.១. ការប៉ាន់ប្រមាណថវិកាសរុប........................................៥៨
**ជំពូកទី ៦ ការតាមដាន វាយតំលៃ និងការធ្វើវសោធនកម្មផែនការជាតិ**........៥៩
១. ការតាមដាន........................................៥៩
២. ការវាយតម្លៃ........................................៥៩
៣. ការធ្វើវិសោធនកម្មផែនការជាតិ........................................៥៩

**ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធទី១ តារាងកម្មវិធីសកម្មភាពសម្រាប់អនុវត្តនីតិវិធានការយុទ្ធសាស្រ្ត........................................៦១
ឧបសម្ព័ន្ធទី២ តម្រូវការថវិកាសម្រាប់ផែនការជាតិ ២០១៣-២០១៥........................................១២៦

# ពាក្យសង្ខេប និងអត្ថន័យពាក្យសង្ខេប

| | |
|---|---|
| ATS | Amphetamine Type Stimulant<br>អំហ្វេតាមីនប្រភេទលើកកំលាំង |
| AusAID | Australia Agency for International Development<br>ទីភ្នាក់ងារអូស្រ្តាលីដើម្បីអភិវឌ្ឍន៍ អន្តរជាតិ |
| BLO | Border Liaison Office<br>ការិយាល័យទំនាក់ទំនងព្រំដែន |
| CBT | Computer Based Training<br>យន្តការបណ្តុះបណ្តាលតាមកុំព្យូទ័រ |
| IO | International Organization<br>អង្គការអន្តរជាតិ |
| FHI | Family Health International<br>សុខភាពគ្រួសារអន្តរជាតិ |
| FI | Friend International<br>មិត្តសំឡាញ់អន្តរជាតិ |
| FREELAND | Foundation for Human Rights and Wildlife<br>មូលនិធិសម្រាប់សិទ្ធិមនុស្ស និងសត្វព្រៃ |
| FRIEND | Mith Samlanh<br>មិត្តសំឡាញ់ |
| HAARP | HIV/AIDS in Asia Regional Programe<br>កម្មវិធីស្តីពីជំងឺអេដស៍នៅក្នុងតំបន់អាស៊ី |
| JICA | Japan International Cooperation Agency<br>ទីភ្នាក់ងារដើម្បីកិច្ចសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| KHANA | Khmer HIV/AIDS NGO Alliance<br>អង្គការសម្ព័ន្ធភាពខ្មែរប្រយុទ្ធនឹងជំងឺអេដស៍ |
| KOICA | Korea International Cooperation Agency |

| | |
|---|---|
| | ទីភ្នាក់ងារដើម្បីកិច្ចសហប្រតិបត្តិការអន្តរជាតិកូរ៉េ |
| MoU | Memorandum of Understanding<br>អនុស្សារណៈនៃការយោគយល់គ្នា |
| NACD | National Authority for Combating Drugs<br>អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន |
| NGO | Non-Governmental Organization<br>អង្គការមិនមែនរដ្ឋាភិបាល |
| PATROL | Partnership against Transnational Crime through Regional Organized Law Enforcement<br>ភាពជាដៃគូនៃមន្ត្រីអនុវត្តច្បាប់ក្នុងតំបន់ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន |
| TOC | Transnational Organized Crime<br>ឧក្រិដ្ឋកម្មឆ្លងដែនដោយមានការចាត់តាំង |
| UNAIDS | United Nation Aids<br>អង្គការសហប្រជាជាតិទទួលបន្ទុកជម្ងឺអេដស៍ |
| UNEP | United Nations Environment Programme<br>កម្មវិធីបរិស្ថានសហប្រជាជាតិ |
| UNODC | United Nations Office on Drugs and Crimes<br>ការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្មសហប្រជាជាតិ |
| USAID | United States Agency for International Development<br>ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ |
| WHO | World Health Organization<br>អង្គការសុខភាពពិភពលោក |

# ពន្យល់ពាក្យបច្ចេកទេស

| | |
|---|---|
| Drug Supply Reduction<br>កាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន | - ការប្រើវិធានការនានា ដើម្បីទប់ស្កាត់ ការផលិត ការដាំដុះ ការ ចែកចាយ ការចរាចរ និងការស្តុកទុកគ្រឿងញៀនខុសច្បាប់ |
| Alternative Development | - ការអភិវឌ្ឍកែប្រែតំបន់ដែលមានដាំដំណាំគ្រឿងញៀនខុសច្បាប់ |
| Counseling Group<br>ក្រុមផ្តល់ប្រឹក្សាយោបល់ | - ក្រុមជំនាញពិគ្រោះ និងផ្តល់យោបល់ចំពោះសហគមន៍ គ្រួសារ និងអ្នកប្រើបំពានគ្រឿងញៀន។ |
| Cocaine<br>កូកាអ៊ីន | - គឺជាសារធាតុញៀនម្យ៉ាងដែលចំរាញ់ចេញពីស្លឹកកូកា។ |
| Priority Province<br>ខេត្តអាទិភាព | - ខេត្តគោលដៅដែលកំពុងទទួលរងនូវការគំរាមកំហែងដោយគ្រឿងញៀន។ |
| Synthetic Drugs<br>គ្រឿងញៀនសំយោគ | - គឺជាគ្រឿងញៀនដែលផលិតពីការសំយោគចេញពីសារធាតុគីមីផ្សំដោយពុំមានលាយគ្រឿងញៀនធម្មជាតិ។ |
| Golden Triangle<br>ត្រីកោណមាស | - តំបន់ដាំដំណាំអាភៀនដ៏ធំនៅតាមបណ្តោយព្រំប្រទល់បីប្រទេសភូមា ថៃ និង ឡាវ។ |
| Life-Skill<br>បំនិនជីវិត | - ការផ្តល់មុខជំនាញឯកទេសច្បាស់លាស់ដល់អ្នកញៀនគ្រឿងញៀន ដែលបានជាសះស្បើយ។ |
| Target Group<br>ក្រុមជនគោលដៅ | - ជាជនដែលងាយរងគ្រោះដោយសារគ្រឿងញៀន។ |
| Treatment Protocol<br>ពិធីសារស្តីពីការព្យាបាល | - ជាបែបបទណែនាំពីក្រមសីលធម៌ វិជ្ជាជីវៈក្នុងការព្យាបាល តាមក្បួនវេជ្ជសាស្រ្ត និងគាំពារអ្នកញៀន។ |
| Integration<br>សមាហរណកម្ម | - ការបញ្ចូលអ្នកញៀនគ្រឿងញៀនដែលបានជាសះស្បើយទៅក្នុង សហគមន៍វិញ។ |
| Precursors<br>សារធាតុគីមីផ្សំ | - ជាសារធាតុគីមីទាំងឡាយដែលមិនមែនជាសារធាតុញៀន(ទាំងរឹង ទាំងរាវ) ដែលត្រូវបានប្រើប្រាស់ក្នុងការផលិតគ្រឿងញៀន ហើយដែល មានចែងក្នុងតារាង៨នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា |
| Psychotropic Substances | - ជាសារធាតុដែលអាចមានឥទ្ធិពលលើប្រព័ន្ធវិញ្ញាណ ឬ និង សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទរបស់មនុស្ស សត្វ។ |

| | |
|---|---|
| Heroine<br>ហេរ៉ូអ៊ីន | - ជាគ្រឿងញៀនម្យ៉ាងដែលគេផលិតពីអាភៀន។ |
| Golden Crescent<br>អឌ្ឍចន្ទមាស | - តំបន់ដាំដុះដំណាំអាភៀនដ៏ធំដែលមានព្រំប្រទល់ប្រទេស អាហ្វហ្គានីស្ថាន ប៉ាគីស្ថាន អ៊ីរ៉ង់ ដែលមានរាងដូចជាចំណិតព្រះចន្ទ។ |
| Opium<br>អាភៀន | - គឺជាគ្រឿងញៀនធម្មជាតិម្យ៉ាងដែលកើតចេញពីជ័រនៃផ្លែអាភៀន វាជាវត្ថុធាតុដើមសម្រាប់ផលិតហេរ៉ូអ៊ីន។ |

## សេចក្តីផ្តើម

ឆ្លើយតបទៅនឹងសភាពការណ៍គ្រឿងញៀននៅក្នុងប្រទេស តំបន់ និងពិភពលោក រាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ១៩៩៥ បានបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន(អ.ជ.ប.គ.ញ) ដើម្បីធ្វើជាស្ថាប័នសម្របសម្រួល និងអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនសំដៅបង្ការ ទប់ស្កាត់ ប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀន ត្រួតពិនិត្យរាល់សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀនក្នុងព្រះរាជាណាចក្រកម្ពុជា និងធានាការអនុវត្តកាតព្វកិច្ចជាអន្តរជាតិនានារបស់ព្រះរាជាណាចក្រកម្ពុជាដែលទាក់ទងនឹងគ្រឿងញៀន លើកកម្ពស់សុខមាលភាពប្រជាពលរដ្ឋ រួមចំណែកការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងកាត់បន្ថយភាពក្រីក្រ។

ចាប់តាំងពីពេលនោះមកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយមានការចង្អុលបង្ហាញ ដឹកនាំ និងគាំទ្រជាប្រចាំពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានធ្វើឱ្យសម្រេចនូវលទ្ធផលជាច្រើនគួរឱ្យកត់សំគាល់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន។ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនមួយត្រូវបានបង្កើតឡើង ជាមជ្ឈមណ្ឌលកណ្តាលក្នុងការសម្របសម្រួលអនុវត្តន៍នូវសេចក្តីសម្រេចនានា ដែលបានដាក់ចេញដោយអាជ្ញាធរជាតិ។ ក្រសួង ស្ថាប័នរដ្ឋ អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល វិស័យឯកជន សប្បុរសជន ដៃគូអភិវឌ្ឍន៍នានា បានចូលរួមធ្វើសកម្មភាពយ៉ាងសកម្ម និងផុលផុសតាមគ្រប់រូបភាពគ្រប់ខ្លឹមសារ និងវិធីសាស្ត្រ ដើម្បីរួមជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន។

ក្នុងគោលដៅដើម្បីប្រមូលផ្តុំកម្លាំង ធនធាន និងតម្រង់ទិសក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យគ្រឿង-ញៀនឱ្យកាន់តែមានប្រសិទ្ធភាព ពិសេសដើម្បីជួយលើកកម្ពស់ការអនុវត្តកម្មវិធីនយោបាយរបស់ រាជរដ្ឋា-ភិបាលកម្ពុជាសម្រាប់នីតិកាលទី៣ នៃរដ្ឋសភាដែលមានយុទ្ធសាស្ត្រចតុកោណជំហាន១ជាស្នូល និងដើម្បីរួមចំណែកបង្ការ ទប់ស្កាត់បញ្ហាគ្រឿងញៀននៅក្នុងប្រទេស និងនៅក្នុងតំបន់ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវផែនការជាតិ៥ឆ្នាំស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០០៥-២០១០។ [1]

ផែនការនេះត្រូវបានរៀបចំឡើងដោយមានការចូលរួម និងគាំទ្របច្ចេកទេសពីបណ្តាក្រសួងស្ថាប័ន នៃរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ហើយបានក្លាយទៅជាឯកសារគោលតែមួយគត់គ្របដណ្តប់លើគ្រប់វិស័យនៃការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន សម្រាប់ធ្វើជាឯកសារយោង និងតម្រង់ទិសដល់ការធ្វើឱ្យសម្រេចនូវទិសដៅនិងសកម្មភាពទាំងឡាយសម្រាប់រយៈពេល៥ឆ្នាំ និងឆ្នាំបន្តបន្ទាប់ក្នុងកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនទាំងនៅក្នុង និងក្រៅប្រទេស ។

---

(1).ផែនការជាតិត្រូវចប់អាណត្តិនៅឆ្នាំ២០១០ប៉ុន្តែយុទ្ធសាស្ត្រសកម្មភាពមួយចំនួននៅតែមានតំលៃសំរាប់ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន អ.ជ.ប.គ.ញ បានរៀបចំផែនការសកម្មភាពសំរាប់អនុវត្តឆ្នាំ២០១១ និង២០១២ ដើម្បីបន្តអនុវត្តយុទ្ធសាស្ត្រផ្សេងៗស្តីពីការត្រួតពិនិត្យគ្រឿង-ញៀន និងកម្មវិធីសកម្មភាពដែលពុំទាន់បានសំរេចក្នុងការអនុវត្តផែនការ២០០៥-២០១០ ។

តាមរយៈផែនការនេះ និងអនុសាសន៍ណែនាំដ៏មានតម្លៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងដោយមានការគាំទ្រពី**លោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា និងជាប្រធានកិត្តិយសនៃគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌តម្លៃស្ត្រី និងគ្រួសារខ្មែរ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានដឹកនាំ និងបង្កើនកិច្ចសហប្រតិបត្តិការជាពហុវិស័យជាមួយនឹងស្ថាប័នជាតិ អន្តរជាតិ និងកម្លាំងសរុបរបស់សង្គមធ្វើឱ្យសម្រេចបាននូវសមិទ្ធផលមួយចំនួនគួរឱ្យកត់សម្គាល់ដូចជាៈ (១). ការលើកកម្ពស់ការយល់ដឹងពីបញ្ហាគ្រឿងញៀន (២). ការបង្ក្រាបបានទាន់ពេលវេលានូវការប៉ុនប៉ងប្រើប្រាស់ប្រទេសកម្ពុជាធ្វើជាកន្លែងផលិតគ្រឿងញៀន ព្រមទាំងការបង្ក្រាបការដាំដុះ ចរាចរ ជួញដូរ ចែកចាយ ស្តុកទុក និងប្រើប្រាស់គ្រឿងញៀន (៣). ការរៀបចំមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាលអ្នកញៀនគ្រឿងញៀនមួយចំនួនដោយមានការគាំទ្រពីគ្រប់មជ្ឈដ្ឋានប្រជាពលរដ្ឋទូទៅ និងសហគមន៍ អន្តរជាតិ និង (៤). ការរៀបចំ និងដាក់ឱ្យដំណើរការនូវយន្តការពហុវិស័យដើម្បីអនុវត្តន៍យុទ្ធសាស្ត្រទាំង៥ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ទន្ទឹមនឹងសមិទ្ធិផលគួរឱ្យកត់សំគាល់ខាងលើ អ.ជ.ប.គ.ញ នៅមានបញ្ហាមួយចំនួនដែលជាលទ្ធផលនៃការអនុវត្តផែនការជាតិ៥ឆ្នាំ២០០៥-២០១០ និងផែនការសកម្មភាពប្រចាំឆ្នាំ២០១១ និង ២០១២ សម្រាប់បន្តដោះស្រាយដូចជាៈ ការពង្រឹងស្ថាប័ន ការពង្រឹងការយល់ដឹង និងឥរិយាបថរបស់ជនដែលងាយរងគ្រោះដោយការប្រើប្រាស់គ្រឿងញៀន ការទប់ស្កាត់ និងការលប់បំបាត់ការប៉ុនប៉ងប្រើប្រាស់កម្ពុជាជាគោលដៅផលិត ចរាចរ គ្រឿងញៀនខុសច្បាប់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងការធ្វើសមាហរណកម្ម។ល។ ដើម្បីឱ្យសំរេចបានតាមស្មារតី នៃសេចក្តីថ្លែងការណ៍របស់ថ្នាក់ដឹកនាំកំពូលអាស៊ានស្តីពី "អាស៊ានគ្មានគ្រឿងញៀននៅឆ្នាំ២០១៥" នាថ្ងៃទី៤ ខែមេសា ឆ្នាំ២០១២ និងផែនការ ASOD ឆ្នាំ២០០៩-២០១៥ ។

ដើម្បីដោះស្រាយបញ្ហាទាំងនេះ ការរៀបចំផែនការជាតិឆ្នាំ២០១៣-២០១៥ ត្រូវបានរៀបចំក្នុងគោលដៅ (១). បន្តអនុវត្តន៍ទិសដៅទាំងឡាយដែលមិនទាន់បានសម្រេចនៅក្នុងកំឡុងពេលអនុវត្តន៍ផែនការជាតិ៥ឆ្នាំ ២០០៥-២០១០ និងផែនការប្រចាំឆ្នាំ២០១១-២០១២ របស់ អ.ជ.ប.គ.ញ (២). បន្តរួមចំណែកអនុវត្តន៍គោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល (៣). រួមចំណែកក្នុងការអនុវត្តឱ្យមានប្រសិទ្ធភាពនូវសេចក្តីថ្លែងការណ៍របស់ថ្នាក់ដឹកនាំអាស៊ាន ស្តីពីអាស៊ានគ្មានគ្រឿងញៀននៅឆ្នាំ២០១៥ ។

ការធ្វើផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៣-២០១៥ ត្រូវបានកែលម្អដើម្បីឱ្យស្របនឹងបរិបទនៃការងារប្រយុទ្ធប្រឆាំងគ្រឿងញៀននៅកម្ពុជា និងតំបន់ សម្រាប់រយៈពេល៣ឆ្នាំខាងមុខតាមចំណុចសំខាន់ៗដូចតទៅៈ

(១). ចាត់ទុកគោលការណ៍ និងយុទ្ធសាស្ត្រស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ ២០០៥-២០១០ ដែលរួមមាន ការកាត់បន្ថយតម្រូវការគ្រឿងញៀន ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន ការព្យាបាលស្តារនីតិសម្បទា ការពង្រឹងប្រសិទ្ធភាពអនុវត្តន៍ច្បាប់ និងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ នៅតែចាំបាច់និងមានប្រសិទ្ធភាពសម្រាប់ធ្វើជាមូលដ្ឋានគ្រឹះក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀននៅ ឆ្នាំ២០១៣-២០១៥ ។

(២). បង្កើតវិធានការយុទ្ធសាស្ត្រចំនួន៧ដើម្បីគាំទ្រ និងជម្រុញការអនុវត្តយន្តការពហុវិស័យ ដើម្បីឱ្យផែនការសកម្មភាពនីមួយៗឆ្លុះបញ្ចាំង និងជះឥទ្ធិពលឱ្យគ្នាទៅវិញទៅមកជាប្រព័ន្ធ និងជាបណ្តុំសកម្មភាពសម្រាប់ឆ្លើយតបនឹងបញ្ហាគ្រឿងញៀនសំដៅសម្រេចឱ្យបាននូវយុទ្ធសាស្ត្រទាំង៥។

(៣). កំណត់អំពីការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធទាំងអស់ ក្នុងការអនុវត្តផែនការសកម្មភាពជាក់លាក់ណាមួយក្នុងផែនការជាតិ។

(៤). ប៉ាន់ប្រមាណពីតម្រូវការធនធាន មធ្យោបាយ និងថវិកាសម្រាប់ក្រសួង ស្ថាប័ន និងដៃគូនានា ក្នុងការអនុវត្តផែនការសកម្មភាព ដើម្បីឱ្យក្រសួង ស្ថាប័ន ទាំងនោះមានមូលដ្ឋានក្នុងការធ្វើវិភាជថវិកា និងធ្វើគំរោងស្នើសុំហិរញ្ញប្បទានពីដៃគូនានា។

(៥). បង្កើតភាពជាម្ចាស់លើផែនការជាតិត្រួតពិនិត្យគ្រឿងញៀន តាមរយៈការចូលរួមរៀបចំតាក់តែង ការផ្តល់យោបល់ ការអនុម័ត និងការអនុវត្តផែនការជាតិត្រួតពិនិត្យគ្រឿងញៀនឆ្នាំ ២០១៣-២០១៥។

ការរៀបចំផែនការជាតិនេះ ក៏បានធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធដែលជាប្រតិបត្តិករ និងអ្នកគាំទ្រទាំងអស់ចាប់តាំងពីដំណាក់កាលដំបូងនៃការវាយតំលៃផែនការជាតិឆ្នាំ២០០៥-២០១០ និងដំណាក់កាលរៀបចំផែនការបន្ត ។ ផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៣-២០១៥ មាន៦ជំពូក និងឧបសម្ព័ន្ធ៖

- ជំពូកទី ១ : ស្ថានភាពទូទៅ
- ជំពូកទី ២ : សមិទ្ធិផល ចំណុចខ្លាំង ចំណុចខ្សោយ និងចំណុចប្រឈម ក្នុងការអនុវត្តផែនការជាតិឆ្នាំ២០០៥ - ២០១០ និងឆ្នាំ២០១១-២០១២
- ជំពូកទី ៣ : គោលការណ៍ គោលបំណង យុទ្ធសាស្ត្រ និងវិធានការយុទ្ធសាស្ត្រ
- ជំពូកទី ៤ : កម្មវិធី សកម្មភាព សម្រាប់អនុវត្តន៍វិធានការយុទ្ធសាស្ត្រ
- ជំពូកទី ៥ : តម្រូវការធនធាន និងហិរញ្ញវត្ថុ
- ជំពូកទី ៦ : ការតាមដាន វាយតម្លៃ និងការធ្វើវិសោធនកម្មផែនការជាតិ

ឧបសម្ព័ន្ធ :

ឧបសម្ព័ន្ធទី១ តារាងកម្មវិធីសកម្មភាពសម្រាប់អនុវត្តន៍វិធានការយុទ្ធសាស្ត្រ

ឧបសម្ព័ន្ធទី២ តម្រូវការថវិកាសម្រាប់ផែនការជាតិ៥ឆ្នាំ ២០១៣-២០១៧

# ជំពូកទី ១

## ស្ថានភាពទូទៅ

### ១. ស្ថានភាពភូមិសាស្ត្រ និងប្រជាជនៈ(2)

១.១. ទីតាំងភូមិសាស្ត្រ

ព្រះរាជាណាចក្រកម្ពុជាមានទីតាំងស្ថិតនៅអាស៊ីភាគអាគ្នេយ៍ ខាងត្បូងឧបទ្វីបឥណ្ឌូចិន មានផ្ទៃដី ១៨១.០៣៥គ.ម² ស្ថិតនៅចន្លោះខ្សែស្របទី១០ និង១៥ នៃរយៈទទឹងខាងជើង និងចន្លោះខ្សែបណ្តោយទី១០២ និង១០៨ នៃរយៈបណ្តោយខាងកើត។

១.២. ព្រំប្រទល់ប្រទេសៈ

ព្រះរាជាណាចក្រកម្ពុជាមានព្រំប្រទល់ប្រវែង២.៦០០គ.ម គឺព្រំប្រទល់ដីគោក៥/៦ និងឆ្នេរសមុទ្រ ១/៦ ដែលមានព្រំប្រទល់ខាងជើងជាប់នឹងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ខាងកើត និងខាងត្បូងជាប់ជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម ខាងលិចជាប់ជាមួយព្រះរាជាណាចក្រថៃ និងឈូងសមុទ្រថៃ ដែលមានឆ្នេរប្រវែង ៤៤០ គ.ម និងមានជម្រៅមធ្យម។

១.៣. សណ្ឋានដីៈ

ព្រះរាជាណាចក្រកម្ពុជា មានផ្ទៃដីរាងជាបាតខ្ទះ វាលទំនាបកណ្តាលព័ទ្ធជុំវិញទៅដោយភ្នំ ខ្ពង់រាប និងតំបន់សមុទ្រនៅទិសនិរតី ដោយបែងចែកជាបួនផ្នែកធំៗ ៖

- តំបន់វាលរាប ៖ ស្ថិតនៅវាលទំនាបកណ្តាលដែលមានដង់ស៊ីតេប្រជាជន ២៣៥នាក់/គ.ម² រួមមាន រាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ចាម ស្វាយរៀង ព្រៃវែង និងតាកែវ។
- តំបន់បឹងទន្លេសាប ៖ រួមមានខេត្តបាត់ដំបង កំពង់ធំ សៀមរាប បន្ទាយមានជ័យ ពោធិ៍សាត់ កំពង់ឆ្នាំង ដែលមានដង់ស៊ីតេប្រជាជន ៥៧នាក់/គ.ម² ។
- តំបន់ឆ្នេរសមុទ្រ ៖ រួមមាន ខេត្តព្រះសីហនុ កែប កំពត និងកោះកុង ដែលមានដង់ស៊ីតេប្រជាជន ៤៩ នាក់/គ.ម² ស្ថិតនៅប៉ែកនិរតីនៃប្រទេស។
- តំបន់ខ្ពង់រាប និងភ្នំ ៖ មានប្រជាជនរស់នៅតិចតួចដែលមានដង់ស៊ីតេ ១៧នាក់/គ.ម² ។ តំបន់នេះរួមមានខេត្តប៉ៃលិន កំពង់ស្ពឺ ឧត្តរមានជ័យ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនៈគិរី និងមណ្ឌលគិរី។

---

(2). ដកស្រង់ចេញពីសៀវភៅតំបន់ទេសចរណ៍ នៃប្រទេសកម្ពុជា ទំព័រទី ៥-៧

### ១.៤. អាកាសធាតុ:

ព្រះរាជាណាចក្រកម្ពុជាស្ថិតក្នុងតំបន់ត្រូពិកក្តៅហើយសើម និងស្ថិតក្នុងតំបន់អាស៊ីមូសុងសំបូរដោយទឹកភ្លៀង និងមានលក្ខណៈអំណោយផលដល់ការលូតលាស់នៃរុក្ខជាតិ និងដំណាំគ្រប់ប្រភេទ។ មានសីតុណ្ហភាពមធ្យមអតិបរមាពី ២៩,៥ ដល់ ៣២ អង្សាសេ និងសីតុណ្ហភាពមធ្យមអប្បបរមាចន្លោះពី ២៤ ដល់ ២៦,៥ អង្សាសេ អាកាសធាតុមានការប្រែប្រួលបន្តិចបន្តួចតាមតំបន់ និងតាមឆ្នាំដូចជានៅតំបន់ភ្នំ និងខ្ពង់រាប។

### ១.៥. ស្ថានភាពប្រជាជន សាសនា ទំនៀមទម្លាប់:

លទ្ធផលចុងក្រោយនៃការជំរឿនប្រជាជនទូទៅរបស់ប្រជាជនកម្ពុជាឆ្នាំ២០០៨ បង្ហាញថាប្រជាជនបានកើនឡើងក្នុងអត្រាមួយយឺតជាងការព្យាករណ៍ (១,៥៤ ភាគរយ ជំនួសឱ្យ ១,៨ ភាគរយ) ដោយមានកម្រិតខ្ពស់ជាងមធ្យមភាគប្រចាំតំបន់បន្តិចគឺ ១,៣ ភាគរយ ដែលជាលទ្ធផលចំនួនប្រជាជនសរុបនាឆ្នាំ២០០៨ មាន ១៤,៣ លាននាក់[3]។

ព្រះរាជាណាចក្រកម្ពុជា ប្រកាន់យកសាសនាព្រះពុទ្ធជាសាសនារបស់រដ្ឋ។ ក្រៅពីនេះក៏មានសាសនាផ្សេងៗទៀតផងដែរដូចជា សាសនាឥស្លាម គ្រីស្ទសាសនា។ល។ ប្រជាពលរដ្ឋកម្ពុជាមានទម្លាប់រស់នៅស្លូតបូត រាក់ទាក់ ប្រកាន់យករបរកសិកម្មជាមូលដ្ឋាន។ ប្រទេសកម្ពុជា ជាប្រទេសមួយក្នុងចំណោមប្រទេស ដែលក្រីក្រលើពិភពលោក ចំណែកឯតម្រូវការការងារ និងតម្រូវការសម្ភារបច្ចេកទេសនានាកំពុងតែកើនឡើងជាលំដាប់។

## ២. របបនយោបាយ រចនាសម្ព័ន្ធរដ្ឋបាល សេដ្ឋកិច្ច និងសង្គមកិច្ច:

### ២.១. របបនយោបាយ:

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានាឆ្នាំ១៩៩៣ បានប្រកាន់យករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញដែលមានព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ព្រះអង្គគ្រងរាជ្យ ប៉ុន្តែមិនកាន់អំណាចឡើយ។ ប្រទេសកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត្យ អចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ។ រដ្ឋធម្មនុញ្ញបានបែងចែកអំណាចជាបីដាច់ដោយឡែកពីគ្នាគឺ អំណាចនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ។

(3). ការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា បច្ចុប្បន្នភាព ឆ្នាំ២០១០ (ទំព័រទី៦)

អំណាចនីតិប្បញ្ញត្តិៈ រួមមានស្ថាប័ន ព្រឹទ្ធសភា និងរដ្ឋសភា។ រដ្ឋសភាកើតឡើងដោយការបោះឆ្នោតជាសកលក្នុងកំឡុងពេល៥ឆ្នាំម្តង។ ចំណែកព្រឹទ្ធសភាមានអាណត្តិ៦ឆ្នាំ ហើយត្រូវមានចំនួនស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភា កើតឡើងដោយការចាត់តាំងខ្លះ និងដោយការបោះឆ្នោតអសកលខ្លះ។

អំណាចនីតិប្រតិបត្តិៈ គឺជាស្ថាប័នរាជរដ្ឋាភិបាល ដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាសមាជិក។

អំណាចតុលាការៈ ជាស្ថាប័នឯករាជ្យដែលមានបីថ្នាក់គឺ សាលាដំបូងរាជធានី-ខេត្ត សាលាឧទ្ធរណ៍ និងតុលាការកំពូល ដើម្បីធានារក្សាការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។

**២.២. រចនាសម្ព័ន្ធរដ្ឋបាល សេដ្ឋកិច្ច និងសង្គមកិច្ច[(4)]**

ព្រះរាជាណាចក្រកម្ពុជាមានផ្ទៃដីសរុបចំនួន ១៨១.០៣៥គម^២ រាជធានីចំនួន១ ខេត្ត២៣ ស្រុក ១៥៩ ខណ្ឌ៩ ក្រុង២៦ ឃុំ១៤០៧ សង្កាត់២២៦ ភូមិ១៣៩១០ ប្រជាជនសរុប ១៤,៥លាននាក់ ដង់ស៊ីតេប្រជាជន (ក្នុង១គ.ម.^២) ៨៤នាក់ នៅឆ្នាំ២០០៨ ។ សេដ្ឋកិច្ចនៅក្នុងនីតិកាលទី៣ ឆ្នាំ២០០៣-២០០៨ បានកើនឡើងប្រមាណ១០ភាគរយជាមធ្យមប្រចាំឆ្នាំ។

រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ខ្ពស់ក្នុងការលើកកម្ពស់វិស័យសង្គមកិច្ចជាអាទិ៍ វិស័យអប់រំ និងសុខាភិបាល។ អត្រាចូលរៀនពិត និងអត្រាពិតនៃការសិក្សាស្ថិតនៅលើគន្លងត្រូវ ដើម្បីសម្រេចបានតាមចំណុចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាឆ្នាំ២០១៥។ ការផ្តល់សេវាសុខភាពត្រូវបានលើកកម្ពស់គួរជាទីមោទនៈចាប់ពីឆ្នាំ២០០៥។ អត្រាមេរោគអេដស៍បានថយចុះយ៉ាងខ្លាំងពីចំណុច ២,៤% ក្នុងឆ្នាំ១៩៩៨ មកចំណុច ១,២% ក្នុងឆ្នាំ២០០៥។ ជាអត្រាល្អប្រសើរជាងចំណុចដៅពីដំបូង ១,២ % ដែលបច្ចុប្បន្ននេះត្រូវបានកែប្រែមកនៅត្រឹម 0,៨%។

## ៣. ស្ថានភាពគ្រឿងញៀនៈ

**៣.១. ស្ថានភាពគ្រឿងញៀនក្នុងតំបន់ និងលើសកលលោកៈ[(5)]**

៣.១.១. ការដាំដុះ និងការផលិតគ្រឿងញៀនៈ

ផ្ទៃដីដែលកំពុងដាំដើមអាភៀននៅលើពិភពលោកបានកើនពី ១៥១.៥០០ហិកតានៅឆ្នាំ២០០៥ ដល់ ២០៦.៧០០ ហិកតា នៅឆ្នាំ២០១១ កើនឡើង ៣៦.៧% ក្នុងនោះការដាំដុះអាភៀននៅប្រទេសមីយ៉ាម៉ាស្មើនឹង២១% នៃការដាំដុះអាភៀនទូទាំងពិភពលោក ។ ផលិតផលអាភៀន នៅលើពិភពលោក

(4). របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០១១ ស្តីពីការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ (ទំព័រទីvi)

(5). UNODC –World drug Report 2012

២៨% គិតចាប់តាំងពីឆ្នាំ ២០០០។ គេបានប៉ាន់ស្មានថា ការផលិតកូកាអ៊ីន នៅ លើ សកលលោក បានថយចុះពី ១.០២៤តោន ក្នុងឆ្នាំ២០០៧ មកនៅត្រឹម៨៦៥តោន ក្នុងឆ្នាំ២០០៨ ថយចុះ ១៥.៥% ។

ចំពោះគ្រឿងញៀនប្រភេទកញ្ឆា និងគ្រឿងញៀនសំយោគ (ATS) មានការដាំដុះ និងផលិតយ៉ាងទូលំទូលាយនៅពាសពេញពិភពលោក។ វាជាការលំបាកក្នុងការបែងចែក និងកំណត់ពីទំហំនៃការផលិត ក៏ដូចជាការតាមដានពីនិន្នាការនៅទីផ្សារគ្រឿងញៀនទាំងនេះ។ កញ្ឆាក្រៀមក្នុងចន្លោះពី ១៣.០០០តោន ទៅ ៦៦.១០០ តោន ត្រូវបានផលិតនៅក្នុងឆ្នាំ ២០០៨ ដូចគ្នាទៅនឹងការផលិតជ័រកញ្ឆា ដែលមានបរិមាណពី២.២០០ តោន ទៅ ៩.៩០០ តោន ដែលបានផលិតនៅចន្លោះឆ្នាំ២០០៨ និង២០០៩ ។

ការផលិតគ្រឿងញៀនសំយោគ ATS (អំហ្វេតាមីន មេតំហ្វេតាមីន និងសារធាតុផ្សេងៗទៀត) មានចំនួនពី ១៦១តោន ទៅ ៥៨៨តោន និងអ៊ិចស្តាស៊ី មានចំនួនពី ៥៥តោន ទៅ១៣៣តោន នៅក្នុងឆ្នាំ២០០៩ ។ ដោយឡែកការរើបអូសគ្រឿងញៀនសំយោគ ATS នៅអាស៊ីអាគ្នេយ៍គឺស្មើពាក់កណ្តាលនឹងការរើបអូសគ្រឿងញៀន ATS នៅក្នុងសកលលោក ។

៣.១.២. ការជួញដូរ

ការជួញដូរឆ្លងកាត់តំបន់ និងទ្វីបភាគច្រើនគឺជាគ្រឿងញៀនប្រភេទ កូកាអ៊ីន ហេរ៉ូអ៊ីន និងបន្ទាប់មកគ្រឿងញៀនប្រភេទជ័រកញ្ឆា និងអ៊ិចស្តាស៊ី។ គ្រឿងញៀនប្រភេទផ្សេងទៀតដូចជាៈ កញ្ឆា មេតំហ្វេតាមីន និងអំហ្វេតាមីន ត្រូវបានគេជួញដូរ និងប្រើប្រាស់នៅក្បែរៗតំបន់ផលិត។

ការរើបអូសគ្រឿងញៀនប្រភេទកូកាអ៊ីននៅលើសកលលោក មានបរិមាណប្រហាក់ប្រហែលគ្នានៅប៉ុន្មានឆ្នាំចុងក្រោយនេះ។ ការរើបអូសកូកាអ៊ីន នៅតំបន់អាមេរិកខាងជើង និងតំបន់អឺរ៉ុបមានការថយចុះ ប៉ុន្តែមានការកើនឡើងនៅអាមេរិកខាងត្បូង និងអាមេរិកកណ្តាល។

ការរើបអូសគ្រឿងញៀនប្រភេទអាភៀន និងហេរ៉ូអ៊ីន មានការកើនឡើងនៅទូទាំងពិភពលោក តែផ្ទុយទៅវិញការរើបអូសគ្រឿងញៀនប្រភេទម៉ហ្វីនបានថយចុះនៅក្នុងឆ្នាំ២០០៨ និងឆ្នាំ២០០៩។

ការរើបអូសគ្រឿងញៀនសំយោគ ATS នៅលើសកលលោក ពិសេសនៅតំបន់អាស៊ីអាគ្នេយ៍ ដែលមានការកើនឡើងចាប់តាំងពីទសវត្សរ៍ ឆ្នាំ២០០០ មក ។

ការរើបអូសគ្រឿងញៀនប្រភេទកញ្ឆានៅលើសកលលោក មានការកើនឡើងក្នុងអំឡុងឆ្នាំ២០០៦ រហូតដល់ឆ្នាំ២០០៨ ស្មើនឹង២៣% ពិសេសនៅអាមេរិកខាងត្បូង។ ជាមួយគ្នានេះដែរ ការរើបអូសគ្រឿងញៀនប្រភេទជ័រកញ្ឆានៅលើសកលលោកមានការកើនឡើងគួរឱ្យកត់សំគាល់ក្នុងអំឡុងឆ្នាំ២០០៦ និង ២០០៨ ដែលការរើបអូសនេះបានកើនឡើងរហូតដល់ទៅ ៦២% ភាគច្រើននៃការរើបអូសមាននៅជិតតំបន់មជ្ឈិមបូព៌ា អឺរ៉ុប និងទ្វីបអាហ្វ្រិក។

៣.១.៣. ការប្រើប្រាស់:

តាមការប៉ាន់ស្មានរបស់អង្គការ UNODC បានឱ្យដឹងថា មានប្រជាជនប្រមាណ ១៥៣ ទៅ ៣០០លាននាក់ (៣,៤% ទៅ៦,៦% នៃប្រជាជនដែលមានអាយុចន្លោះពី១៥-៦៤ឆ្នាំ) បានប្រើប្រាស់សារធាតុញៀនខុសច្បាប់យ៉ាងហោចណាស់១ដងចាប់តាំងពីឆ្នាំ២០០៨មក ។ អ្នកប្រើប្រាស់គ្រឿងញៀនប្រភេទកញ្ឆាមានចំនួនច្រើនជាងគេគឺស្ថិតនៅក្នុងលំដាប់ទី១ ប្រហែលពី១១៩លានទៅ២២៤លាននាក់។ ចំនួនអ្នកប្រើប្រាស់សារធាតុញៀនប្រភេទសំយោគដូចជាពពួក អំហ្វេតាមីន ស្ថិតនៅក្នុងលំដាប់ទី២ មានចំនួន ១៤.៣៤០.០០០នាក់ ទៅ ៥២.៥៤០.០០០នាក់ ដែលមានអត្រាប្រេវ៉ាឡង់ពី ០.៣ ទៅ១.២% ក្នុងនោះមាន៥០% នៃអ្នកប្រើប្រាស់គឺនៅតំបន់អាស៊ីអាគ្នេយ៍ និងគ្រឿងញៀនប្រភេទកូកាអ៊ីន និងអាភៀនស្ថិតនៅលំដាប់ទី៣ ។

៣.២. ស្ថានភាពគ្រឿងញៀនក្នុងប្រទេស

កម្ពុជា ជាប្រទេសមួយក្នុងចំណោមប្រទេសជាច្រើននៅក្នុងតំបន់ ដែលទទួលរងគ្រោះដោយសារគ្រឿងញៀនគ្រប់ប្រភេទ ទាំងគ្រឿងញៀនធម្មជាតិនិងសំយោគ ដែលឆ្លងកាត់មកពីតំបន់ត្រីកោណមាសចូលមកក្នុងប្រទេស និងនាំចេញទៅកាន់ប្រទេសនានានៅក្នុងតំបន់។ ក្រុមឧក្រិដ្ឋជនគ្រឿងញៀនអន្តរជាតិដែលមានការចាត់តាំង បានប៉ុនប៉ងប្រើប្រាស់ភូមិសាស្ត្រកម្ពុជាធ្វើជាកន្លែងផលិត សំចត និងជួញដូរបន្តនូវគ្រឿងញៀនដែលមានប្រភពមកពីតំបន់អឌ្ឍច័ន្ទមាស និងអាមេរិកខាងត្បូងទៅកាន់ទីផ្សារនានាលើសកលលោក។

ក្រៅពីនោះ: ក្រុមឧក្រិដ្ឋជនគ្រឿងញៀនអន្តរជាតិបានប៉ុនប៉ងប្រើប្រាស់កម្ពុជាជាកន្លែងសម្រាប់ចម្រាញ់ ផលិតសារធាតុគីមីផ្សំគ្រឿងញៀនដើម្បីនាំចេញទៅបរទេស។

ដោយសារនិន្នាការនៃការផលិតគ្រឿងញៀនសំយោគនៅក្នុងតំបន់ និងលើសកលលោកមានការកើនឡើង ឧក្រិដ្ឋជនគ្រឿងញៀនត្រូវការចាំបាច់នូវសារធាតុគីមីផ្សំជាច្រើនប្រភេទថែមទៀតដើម្បីយកទៅផលិតគ្រឿងញៀន។ និន្នាការនេះបានធ្វើឱ្យកម្ពុជាទទួលរងនូវផលវិបាកជាច្រើនដូចជា ការជួញដូរឆ្លងកាត់ព្រំដែននូវសារធាតុគីមីផ្សំ ការជួញដូរឱសថដែលមានសារធាតុផ្សំអេហ្វេឌ្រីន ដើម្បីចម្រាញ់យកសារធាតុនេះនាំចេញទៅក្រៅប្រទេស ការយកគ្រឿងញៀនប្រភេទមេតំហ្វេតាមីនគ្រាប់មកកិនលាយជាមួយនឹងសារធាតុផ្សេងៗដើម្បីបង្កើនបរិមាណ ការកាប់បំផ្លាញរុក្ខជាតិកម្រប្រភេទម្រះព្រៅភ្នំដោយខុសច្បាប់ដើម្បីចម្រាញ់យកប្រេងដែលមានផ្ទុកសារធាតុសាហ្វ្រូលខ្ពស់ សម្រាប់ធ្វើការនាំចេញដោយខុសច្បាប់។ល។ ភូមិសាស្ត្រដែលទទួលរងនូវការកាប់បំផ្លាញខ្លាំងជាងគេគឺ ចន្លោះព្រំប្រទល់នៃខេត្តកោះកុង ពោធិ៍សាត់ និងបាត់ដំបង ហើយបន្តលួចដឹកជញ្ជូនទៅបរទេស។

៣.២.១. កញ្ឆា:

ចាប់តាំងពីការបង្ក្រាបក្នុងទ្រង់ទ្រាយធំនូវដំណាំកញ្ឆានៅតំបន់ថ្នាន់មួយរយៈនៅក្នុងឆ្នាំ២០០៧ មក គ្រឿងញៀន ប្រភេទកញ្ឆាត្រូវបានកាត់បន្ថយ និងលុបបំបាត់ស្ទើរទាំងស្រុង។ មន្ត្រីអនុវត្តច្បាប់កម្ពុជានៅតាមបណ្តារាជធានី-ខេត្តនានាបានរុករក និងបំផ្លាញដំណាំកញ្ឆាដែលដាំដុះជាលក្ខណៈគ្រួសារមានទ្រង់

ទ្រាយតូច លួចលាក់នៅតំបន់ព្រៃភ្នំ តំបន់ដាច់ស្រយាល ហើយទំហំនៃការដាំដុះនេះពុំមានលក្ខណៈជាអង្គការចាត់តាំង និងសម្រាប់ធ្វើពាណិជ្ជកម្មទេ។

៣.២.២. គ្រឿងញៀនសំយោគៈ

គ្រឿងញៀនសំយោគប្រភេទមេតំហ្វេតាមីន ដែលបានធ្វើចរាចរនៅកម្ពុជាភាគច្រើនគឺមានទម្រង់ជាគ្រាប់ដែលមានសញ្ញា (WY) ហើយមានភាពសុទ្ធមេតំហ្វេតាមីនពី១០-២៥% និងកាហ្វេអ៊ីនពី ៦០-៧០% នោះមិនមែនជាគ្រឿងញៀនដែលផលិតនៅកម្ពុជាទេ។ ប៉ុន្តែជារៀងរាល់ ឆ្នាំគេបានរកឃើញកន្លែងវាយថ្នាំគ្រាប់ក្នុងទ្រង់ទ្រាយតូចៗជាច្រើន ដោយការយកមេតំហ្វេតាមីនដែលផលិតនៅប្រទេសផ្សេងទៀតមកលាយជាមួយសារធាតុផ្សេងៗ ដើម្បីផលិតជាមេតំហ្វេតាមីនគ្រាប់ដែលមានគុណភាពអន់សម្រាប់លក់នៅទីផ្សារក្នុងប្រទេសកម្ពុជា។ និន្នាការថ្មីៗនេះបានបង្ហាញឱ្យឃើញនូវការកើនឡើងគ្រឿងញៀនមេតំ-ហ្វេតាមីនប្រភេទក្រាមម្សៅ (Ice) យ៉ាងគំហុកចូលមកផ្ទៃក្នុងប្រទេស ដើម្បីបន្តទៅកាន់ប្រទេសនានាក្នុងតំបន់។

នៅខែមេសា ឆ្នាំ២០០៧ កម្ពុជាបានបង្ក្រាបជាលើកដំបូងនូវកន្លែងផលិតសារធាតុញៀនសម្រាប់ផលិតមេតំហ្វេតាមីននៅក្នុងខេត្តកំពង់ស្ពឺ។ នៅខែមិនា ឆ្នាំ២០០៩ អង្គភាពអនុវត្តច្បាប់បានបង្ក្រាបទីតាំងចំនួន៣កន្លែងផ្សេងៗពីគ្នា នៅរាជធានីភ្នំពេញ និងខេត្តតាកែវ ជាទីតាំងផលិតសារធាតុគីមីផ្សំ និងខេត្តកំពង់ចាម ជាកន្លែងចម្រាញ់យកសារធាតុអេហ្វេឌ្រីន ពីស្មៅអេហ្វេដ្រា។ សារធាតុគីមីជាច្រើនតោនត្រូវបានដកហូតនៅនឹងកន្លែង រួមទាំងស្មៅអេហ្វេដ្រាស្ងួតចំនួនជាងបីតោន។ តាមការស្រាវជ្រាវបានបង្ហាញថាសារធាតុគីមី និងស្មៅអេហ្វេដ្រាមានប្រភពមកពីប្រទេសចិន ។ ការចរាចរគ្រឿងញៀនមេតំហ្វេតាមីន គឺភាគច្រើនចូលមកតាមព្រំដែនកម្ពុជា-ឡាវកាត់ខេត្តស្ទឹងត្រែង ព្រះវិហារ ក្រចេះ កំពង់ចាម ក្នុងគោលដៅមករាជធានីភ្នំពេញ និងបន្តចែកចាយទៅខេត្តមួយចំនួនទៀត ហើយគ្រឿងញៀនដែលនៅសេសសល់មួយភាគធំត្រូវបាននាំចេញទៅកាន់ប្រទេសជិតខាង។

៣.២.៣. ហេរ៉ូអ៊ីនៈ

កម្ពុជាមិនមែនជាប្រទេសដែលអាចផលិតអាភៀនបានទេ។ ហេរ៉ូអ៊ីនដែលបានជួញដូរដោយខុសច្បាប់នៅកម្ពុជា មានប្រភពមកពីតំបន់ត្រីកោណមាស និងអឌ្ឍច័ន្ទមាស។ ហេរ៉ូអ៊ីនភាគច្រើនត្រូវបានឈ្មួញគ្រឿងញៀនរៀបចំវេចខ្ចប់សារឡើងវិញ មុននឹងនាំចេញពីកម្ពុជាទៅកាន់ប្រទេសមួយចំនួននៅក្នុងតំបន់ និងពិភពលោក ហើយមួយចំនួនទៀតត្រូវបានគេវេចខ្ចប់ជាកញ្ចប់តូចៗសម្រាប់ផ្គត់ផ្គង់ដល់អ្នកប្រើប្រាស់នៅក្នុងប្រទេស។

ឈ្មួញគ្រឿងញៀនអន្តរជាតិមកពីកោះតៃវ៉ាន់ និងអាហ្វ្រិកខាងលិច និងបណ្ដាញចែកចាយនៅក្នុងតំបន់បានជួញដូរគ្រឿងញៀនប្រភេទហេរ៉ូអ៊ីនពីតំបន់ត្រីកោណមាស និងអឌ្ឍច័ន្ទមាសចូលមកកម្ពុជាឆ្លងកាត់តាមបណ្ដាខេត្តភាគឦសានតាមច្រកផ្លូវគោក តាមដងទន្លេមេគង្គ និងផ្លូវអាកាសមកទីក្រុងបាងកកឆ្លងព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ គេក៏សង្កេតឃើញមានការចរាចរតាមបញ្ញើក្រុមហ៊ុនដឹកជញ្ជូន រួចនាំបន្តទៅប្រទេសថៃ និងវៀតណាម។ ហេរ៉ូអ៊ីន ដែលបាននាំចូលមកដល់កម្ពុជាត្រូវគេលាក់ទុកតាមប្រភេទផ្សេងៗគ្នា រួចដាក់លាក់នៅក្នុងសម្ភារប្រើប្រាស់ផ្សេងៗ ឬលេបចូលទៅក្នុងពោះដើម្បីធ្វើការនាំចេញ

នាំបន្តទៅប្រទេសថៃ និងវៀតណាម។ ហេរ៉ូអ៊ីន ដែលបាននាំចូលមកដល់កម្ពុជាត្រូវបានគេវេចខ្ចប់តាមប្រភេទផ្សេងៗគ្នា រួចដាក់លាក់នៅក្នុងសម្ភារប្រើប្រាស់ផ្សេងៗ ឬលេបចូលទៅក្នុងពោះដើម្បីធ្វើការនាំចេញទៅកាន់ទីផ្សារគ្រឿងញៀនអន្តរជាតិ។ នៅក្នុងប្រទេសកម្ពុជា គ្រឿងញៀនប្រភេទនេះត្រូវបានគេធ្វើការជួញដូរភាគច្រើននៅរាជធានីភ្នំពេញ តែបរិមាណមានចំនួនតិចតួចជាងគ្រឿងញៀនប្រភេទមេតំហ្វេតាមីនគ្រាប់ និងមេតំហ្វេតាមីនក្រាមម្សៅ។

៣.២.៤. សារធាតុគីមីផ្សំ:

សារធាតុគីមីផ្សំភាគច្រើនបាននាំចូលមកពីបរទេសដោយស្របច្បាប់ សម្រាប់ប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម សុខាភិបាល កសិកម្ម និងសិប្បកម្ម។ ពុំមានសារធាតុគីមីផ្សំណាមួយដែលត្រូវបានផលិតនៅប្រទេសកម្ពុជាទេ។ នៅឆ្នាំ២០០៦គេបានរកឃើញសារធាតុគីមីផ្សំឈ្មោះសាហ្វ្រូលនៅក្នុងប្រេងរុក្ខជាតិកម្ពុជាដែលដុះនៅតំបន់ភ្នំក្រវាញគឺប្រេងម្រះព្រៅភ្នំ។ ការធ្វើវិភាគដោយមន្ទីរពិសោធន៍គ្រឿងញៀននៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ មន្ទីរពិសោធន៍នៃវិទ្យាស្ថានស្រាវជ្រាវព្រៃឈើនៃប្រទេសម៉ាឡេស៊ី និងមន្ទីរពិសោធន៍របស់ UNODC នៅទីក្រុងវីយែន ប្រេងរុក្ខជាតិនេះមានផ្ទុកសារធាតុសាហ្វ្រូលខ្ពស់រហូតដល់ជាង ៩៦%។ សាហ្វ្រូលគឺជាសារធាតុគីមីផ្សំ សម្រាប់ប្រើប្រាស់ក្នុងការផលិតឱសថ គ្រឿងសំអាង និងផលិតផលប្រើប្រាស់ផ្សេងៗទៀត។ ជាមួយគ្នានេះសាហ្វ្រូលក៏ជាសារធាតុគីមីផ្សំចាំបាច់សម្រាប់ផលិតគ្រឿងញៀនអ៊ិចស្តាស៊ី ផងដែរ។ គេបានធ្វើការប៉ាន់ស្មានថា ការលួចលាក់ផលិតប្រេងដែលមានផ្ទុកសារធាតុសាហ្វ្រូលខ្ពស់ បានចាប់ផ្តើមនៅឆ្នាំ២០០១នៅប្រទេសកម្ពុជា ដែលមានការផលិតបាន៤៨តោននៅឆ្នាំ២០០២-២០០៣ និងកើនឡើងដល់២៤៥តោន នៅឆ្នាំ២០០៤-២០០៥។ បន្ទាប់ពីមានការចម្រាញ់ប្រេងដែលមានផ្ទុកសារធាតុសាហ្វ្រូលខ្ពស់នេះត្រូវបានចាត់ទុកជាអំពើខុសច្បាប់ ការផលិតបានថយចុះមកនៅត្រឹម៣៨តោន នៅឆ្នាំ២០០៦(៦)។ នៅខែតុលាឆ្នាំ២០០៧ប្រេងរុក្ខជាតិដែលមានសារធាតុសាហ្វ្រូលខ្ពស់នេះត្រូវបានគេរឹបអូសបានជាង៥០តោន នៅកំពង់ផែសមុទ្រប្រទេសថៃ។ គេជឿជាក់ថាការដឹកជញ្ជូននេះគឺមានគោលដៅយកទៅប្រទេសចិន និងអាមេរិក(៦)។

៣.២.៥. ការប្រើបំពានគ្រឿងញៀន:

ការប៉ាន់ស្មានពីចំនួនអ្នកប្រើប្រាស់គ្រឿងញៀនគឺមានខុសៗគ្នា។ នៅឆ្នាំ២០០៤ អង្គការអេដស៍របស់សហប្រជាជាតិបានធ្វើការប៉ាន់ស្មានថាមានអ្នកប្រើប្រាស់គ្រឿងញៀននៅកម្ពុជាប្រហែល ៤៦.០០០ នាក់។ តួលេខផ្លូវការរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននៅឆ្នាំ២០០៧ [illegible] ក្រោមឥទ្ធិពលគ្រឿងញៀនមានចំនួន៦.៥០០នាក់ ហើយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងអេដស៍ [illegible]

(6). UNODC and Forest Research Institute Malaysia (2007). Essential Oils Rich in safrole: Survey on Production, Trade and Use in East Asia and the Pacific. UNODC, p.17.

(7). NACD (2008). Report on Illicit Drug Data and Routine Surveillance Systems in Cambodia. USAID, UNODC et al., p.32

និងកាមរោគប៉ាន់ស្មានថាមាន ១៣.០០០នាក់។ តែទោះជាយ៉ាងណាក៏ដោយ មានការឯកភាពគ្នាថា តួលេខជាក់ស្តែងអាចមានច្រើនជាងតួលេខដែលបានបង្ហាញដោយអង្គភាពផ្សេ។

អ្នកប្រើប្រាស់គ្រឿងញៀនភាគច្រើនស្ថិតនៅក្នុងអាយុពី១៨-២៥ ឆ្នាំ មាន ៦០,៣៥% អាយុពី ២៦-៤៥ ឆ្នាំ មាន ៣០,៩៧% និងអាយុពី៤៦ឆ្នាំឡើងមាន ២,៣៩%។ មេតំហ្វេតាមីនគ្រាប់ ដែលគេហៅថា យ៉ាម៉ា ជាប្រភេទគ្រាប់គឺជាគ្រឿងញៀនដែលមានការនិយមប្រើជាងគេ ប៉ុន្តែការប្រើប្រាស់មេតំហ្វេតាមីនប្រភេទក្រាមម្សៅ (Ice) គឺកំពុងមានការកើនឡើងក្នុងចំណោមយុវជន ពិសេសយុវជនដែលប្រើប្រាស់គ្រឿងញៀននៅរាជធានីភ្នំពេញ។

បញ្ហានៃការប្រើប្រាស់គ្រឿងញៀនគឺមានច្រើនចំពោះយុវជន ដែលមាន ៧៧% ជាអ្នកដែលមានអាយុក្រោម២៦ឆ្នាំ។ បញ្ហានៃការប្រើប្រាស់គ្រឿងញៀនមិនមានសម្រាប់តែនៅតំបន់ទីក្រុងទេ តែបានរីករាលដាលទៅដល់តំបន់ជនបទជាប់ព្រំដែនកម្ពុជា ថៃ និងកម្ពុជា ឡាវ។

អត្រានៃការប្រើប្រាស់គ្រឿងញៀនច្រើនជាងគេបើប្រៀបធៀបនឹងចំនួនប្រជាជន[illegible]នៅតាមទីក្រុង ទីប្រជុំជន និងបណ្តាក្រុង-ស្រុក ជាប់ព្រំដែន ដែលមានអត្រាពី ០.០៧% ទៅ០.១១% ។

អត្រាអ្នកផ្ទុកមេរោគអេដស៍នៅក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀនគឺមាន១,១%នៅឆ្នាំ២០០៨ អត្រានេះខ្ពស់ជាងអត្រាសម្រាប់មនុស្សទូទៅ ។ ដោយឡែកនៅក្នុងចំណោមអ្នកចាក់គ្រឿងញៀនគឺមានអត្រាអ្នកផ្ទុកមេរោគអេដស៍ចំនួន២៤,៤%[8]។

(8). អត្រាប្រេវ៉ាលង់អ្នកផ្ទុកមេរោគអេដស៍ក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀន ,មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនឹងកាមរោគ

# ជំពូកទី ២

## សមិទ្ធិផល ចំណុចខ្លាំង ចំណុចខ្សោយ និងចំណុចប្រឈម ក្នុងការអនុវត្តផែនការជាតិឆ្នាំ ២០០៥-២០១០ និងផែនការសកម្មភាព ឆ្នាំ២០១១ និង២០១២

### ១. សមិទ្ធិផល:

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនអនុវត្តន៍តាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ និងទី២ របស់រាជរដ្ឋាភិបាលនិងផែនការជាតិ៥ឆ្នាំ (២០០៥-២០១០) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងផែនការសកម្មភាពត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១និង២០១២ បានបន្តធ្វើការសម្របសម្រួល និងលើកកម្ពស់កិច្ចសហការពហុវិស័យជាមួយស្ថាប័នជាតិ អន្តរជាតិ ដោយប្រើប្រាស់កម្លាំងសរុបរបស់សង្គម និងមានការគាំទ្រពីសហគមន៍អន្តរជាតិ សម្រេចបាននូវលទ្ធផលមួយចំនួនគួរឱ្យកត់សំគាល់ ដូចខាងក្រោមៈ

#### ១.១. ការងារពង្រឹងស្ថាប័ន:

- ចាប់តាំងពីអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានបានបង្កើតនៅឆ្នាំ១៩៩៥មក មានការកែសម្រួលសមាសភាព និងតួនាទីភារកិច្ចរបស់អាជ្ញាធរជាតិដើម្បីឱ្យស្របតាមសភាពការណ៍គ្រឿងញៀននិងការអភិវឌ្ឍរបស់ប្រទេសជាតិដើម្បីធ្វើកិច្ចប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀនឱ្យកាន់តែមានប្រសិទ្ធភាព។
- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបច្ចុប្បន្នមានក្រសួង ស្ថាប័នជាសមាជិកចំនួន២២ និងមានអគ្គលេខាធិការដ្ឋានជាសេនាធិការ សម្រាប់ដាក់ឱ្យអនុវត្តន៍ និងអនុវត្តន៍នូវសេចក្តីសម្រេចទាំងឡាយរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងមានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនទាំង២៤ រាជធានី-ខេត្ត ជាខ្សែបណ្តោយ។ ក្រសួង ស្ថាប័នជាសមាជិកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចាត់តាំងតំណាង១រូប ចូលរួមជាមួយនឹងក្រុមការងារអន្តរក្រសួង របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីសម្របសម្រួលការងារជាអចិន្ត្រៃយ៍ រវាងអគ្គលេខាធិការដ្ឋាន និងក្រសួង ស្ថាប័ន។ ក្រសួង ស្ថាប័នសំខាន់ៗមួយចំនួនបានបង្កើតអង្គភាព ឬចាត់តាំងអង្គភាពនៅក្រោមឱវាទដើម្បីទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនដូចជា មន្ទីរប្រឆាំងគ្រឿងញៀននៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ការិយាល័យប្រឆាំងគ្រឿងញៀននៃស្នងការដ្ឋាន

នគរបាលរាជធានី-ខេត្ត ការិយាល័យប្រឆាំងគ្រឿងញៀនរបស់កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងរាជធានី-ខេត្ត ក្រសួងអប់រំយុវជននិងកីឡា ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ល។

- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយមានការគាំទ្រពី ក្រសួង ស្ថាប័ន ជាសមាជិក និងអង្គភាពជំនាញនានា បានអនុវត្តយ៉ាងពេញលេញនូវកាតព្វកិច្ចដែលមានចែងក្នុងអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីគ្រឿងញៀន ព្រមទាំងបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនស្របតាមស្មារតីនៃអនុសញ្ញាទាំងបីហើយដែលច្បាប់នេះត្រូវបានអនុម័ត និងប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០១២ ។
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានអង្គភាពជំនាញចំនួន៧ធ្វើជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន ក្នុងការអនុវត្តគោលនយោបាយដែលបានដាក់ចេញដោយអាជ្ញាធរជាតិ។ អង្គភាពទាំងនេះ ដើរតួនាទីជាអង្គភាពសម្របសម្រួលផង និងប្រតិបត្តិការដោយផ្ទាល់ផង ពិសេសលើការងារអប់រំ ផ្សព្វផ្សាយ និងការងារធ្វើកោសល្យវិច័យវត្ថុតាងគ្រឿងញៀនសម្រាប់យកទៅបំរើឱ្យការកាត់ក្តីនៅស្ថាប័នតុលាការ។ មន្ទីរពិសោធន៍គ្រឿងញៀនគឺជាមន្ទីរពិសោធន៍តែមួយគត់នៅព្រះរាជាណាចក្រកម្ពុជា ដែលទទួលបាន នីតិសម្បទាសម្រាប់ធ្វើកោសល្យវិច្ច័យលើសារធាតុសង្ស័យនានាដែលជាវត្ថុតាងក្នុងករណីគ្រឿងញៀន។
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត មានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ក្រុង ស្រុក និងឃុំ សង្កាត់ ជាខ្សែបណ្តោយ ដើម្បីអនុវត្តការប្រយុទ្ធប្រឆាំងគ្រឿងញៀននៅថ្នាក់ក្រោមជាតិ។ គណៈកម្មាធិការនេះមានលេខាធិការដ្ឋាន១ជាសេនាធិការ និងមានការិយាល័យទំនាក់ទំនងព្រំដែន (BLO) នៅតាមបណ្តាខេត្តដែលមានច្រកទ្វារព្រំដែនអន្តរជាតិ។
- រាជរដ្ឋាភិបាល បានធ្វើឱ្យសំរេចនូវលិខិតបទដ្ឋានក្រោមច្បាប់នានាដែលពាក់ព័ន្ធនឹងការរៀបចំកែសម្រួលសមាសភាពតួនាទីនិងភារកិច្ច របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ការរៀបចំនិងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ការបង្កើតមជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ការបង្កើតនិងចាត់តាំងអង្គភាពជំនាញប្រឆាំងគ្រឿងញៀនក្រោមបណ្តាក្រសួងស្ថាប័នជាសមាជិកមួយចំនួន ការបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ការបង្កើតការិយាល័យទំនាក់ទំនងព្រំដែន(BLO)នៅខេត្តជាប់ព្រំដែន ការចាត់តាំងអនុវត្តន៍ផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀននៅខេត្តបន្ទាយមានជ័យ ការបង្កើតក្រុម

ការងារជំនាញផ្សេងៗ ព្រមទាំងចាត់តាំងមន្ត្រីរាជការដើម្បីទទួលខុសត្រូវអនុវត្តន៍ការងារសម្រាប់ទ្រទ្រង់ដល់យន្តការអនុវត្តន៍យុទ្ធសាស្ត្រពហុវិស័យស្តីពីការត្រួតពិនិត្យគ្រឿងញៀនទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

- ជាមួយគ្នានេះក្រុមការងារឯកទេសមួយចំនួនត្រូវបានបង្កើតឡើងដូចជាក្រុមការងារគ្រឿង-ញៀន/អេដស៍ ក្រុមការងារត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន ក្រុមការងារប៉ាន់ប្រមាណចំនួនអ្នកប្រើប្រាស់គ្រឿងញៀននៅកម្ពុជា ក្រុមការងារទទួលខុសត្រូវក្នុងការអនុវត្តគោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន គណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តភាគឦសាន្ត ក្រុមការងាររៀបចំលិខិតបទដ្ឋានដើម្បីអនុវត្តច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងក្រុមការងារទទួលបន្ទុកអនុវត្តន៍គោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល។

១.២. ការកាត់បន្ថយតម្រូវការគ្រឿងញៀន:

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនដោយមានការគាំទ្រ និងដឹកនាំជាប្រចាំពីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានសម្របសម្រួលនិងបង្កើនកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័ន ជាសមាជិកគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិ និងដោយមានការចូលរួមគាំទ្រយ៉ាងសកម្មពីគ្រប់លំដាប់ថ្នាក់ ពិសេសពីសម្តេចព្រះអគ្គមហាសង្ឃរាជទាំងពីគណៈ និងព្រះសង្ឃគ្រប់ឋានានុក្រម ការចូលរួមគាំទ្រជាប្រចាំពី លោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា និងជាប្រធានកិត្តិយសនៃគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌តម្លៃស្ត្រី និងគ្រួសារខ្មែរ បានធ្វើការអប់រំផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងជាសាធារណៈពីគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប៉ាពានគ្រឿងញៀន ដល់គ្រប់ស្រទាប់មហាជន ដើម្បីឱ្យគ្រប់បុគ្គលម្នាក់ៗបដិសេធដាច់ខាតនូវគ្រឿងញៀនគ្រប់ប្រភេទ។ លទ្ធផលសំរេចបានក្នុងការងារកាត់បន្ថយតម្រូវការគ្រឿងញៀន ដែលអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនសំរេចបានគួរឱ្យកត់សំគាល់មានដូចខាងក្រោម ៖

- ការបញ្ជ្រាបការយល់ដឹងអំពីគ្រោះថ្នាក់នៃគ្រឿងញៀននៅក្នុងកម្មវិធីសិក្សាជាតិ: ការងារនេះគឺបានចាប់ផ្តើមអនុវត្តនៅចាប់តាំងពីឆ្នាំ២០០៤មក ដោយបានបញ្ចូលមេរៀនអំពីគ្រឿង-ញៀនទៅក្នុងកម្មវិធីសិក្សាថ្នាក់ បឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ។ ជាមួយគ្នានេះដែរសម្រាប់ថ្នាក់ឧត្តមសិក្សា គឺបានធ្វើការបញ្ចូលមុខវិជ្ជាចំណេះដឹងស្តីពីគ្រឿងញៀនទៅក្នុងឆ្នាំសិក្សាថ្នាក់មូលដ្ឋាន និងនៅតាមរយៈការរៀបចំ បាឋកថា សិក្ខាសាលា និងបទបង្ហាញនានា ដើម្បីឱ្យចេះបដិសេធ និងចាកចេញពីគ្រឿងញៀនផ្សេងៗ។

- ការបណ្តុះបណ្តាលគ្រូបង្គោលក្នុងវិស័យអប់រំៈ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការបណ្តុះបណ្តាល បំប៉នព័ត៌មានជូនដល់នាយកកម្រង នាយក គ្រូសាលាបឋមសិក្សា និងមធ្យមសិក្សា សិស្សានុសិស្ស ភ្នាក់ងារមិត្តអប់រំមិត្តក្នុង និងក្រៅប្រព័ន្ធសិក្សាស្តីពីការអនុវត្តកម្មវិធីបំនិនជីវិតសម្រាប់ការអប់រំបង្ការអំពីជំងឺអេដស៍ គ្រឿងញៀន និងប្រធានបទពាក់ព័ន្ធក្នុងខេត្តគោលដៅមួយចំនួន ដូចជាៈ ខេត្តព្រៃវែង កំពង់ចាម ក្រចេះ កំពង់ធំ សៀមរាប ព្រះវិហារ ឧត្តរមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ស្ពឺ កោះកុង ព្រះសីហនុ កំពត និងតាកែវ ។ល។ និងបានបណ្តុះបណ្តាលដល់គរុសិស្សខេត្តគោលដៅអំពីមេរៀនស្តីពីគ្រឿងញៀន។ វិធីសាស្ត្ររៀបចំផែនការបង្រៀន និងបញ្ជ្រាបមេរៀនគ្រឿងញៀនទៅក្នុងកម្មវិធីសិក្សាត្រូវបានបំប៉នដល់គ្រូបង្រៀន ដែលកត្តាទាំងនេះធ្វើឱ្យប្រសិទ្ធភាពនៃការផ្សព្វផ្សាយសារអប់រំអំពីគ្រឿងញៀន រឹតតែបានជ្រួតជ្រាបដល់សិស្សានុសិស្សគ្រប់ៗគ្នាដែល បានចូលសាលារៀន។
- ការអប់រំផ្សព្វផ្សាយនៅតាមសហគមន៍ឱ្យបដិសេធគ្រឿងញៀនៈ ការងារនេះបានអនុវត្តជាប់ជាប្រចាំ ដោយក្រសួង ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត និងអង្គការមិនមែនរដ្ឋាភិបាល ដោយបានរៀបចំអនុវត្តន៍កម្មវិធីអប់រំបង្ការដល់យុវជន និងប្រជាពលរដ្ឋទូទៅនៅតាមគោលដៅប្រឈមនានាទូទាំងប្រទេស។ ក្នុងនោះដែរ ក៏មានការរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយជាប្រចាំតាមរយៈក្រុមប្រឹក្សាយុវជន កុមារ យុវជនកាកបាទក្រហម ក្រុមកាយរិទ្ធ ក្នុងកម្មវិធីបោះជំរំ និងការអប់រំផ្សព្វផ្សាយបន្តពីគ្រោះថ្នាក់គ្រឿង-ញៀនដល់ក្រុមគ្រួសារក្នុងសហគមន៍។ នៅក្នុងផ្នែកសាសនា ក៏មានការរីកចំរើនគួរឱ្យកត់សំគាល់ដោយការចូលរួម និងធ្វើសកម្មភាពយ៉ាងខ្លាំងក្លាពីសំណាក់ព្រះសង្ឃគ្រប់ឋានានុក្រមពិសេស សម្តេចព្រះអគ្គមហាសង្ឃរាជ ទេព វង្ស ដែលបានណែនាំដល់ព្រះសង្ឃគ្រប់ព្រះអង្គ ឱ្យឆ្លៀតឱកាសប្រៀនប្រដៅតាមធម៌ព្រះពុទ្ធ ដើម្បីណែនាំដាស់តឿនឱ្យពុទ្ធបរិស័ទចាកផុត និងបដិសេធគ្រឿងញៀន។ តាមរយៈនេះ ក្រសួងធម្មការ និងកិច្ចការសាសនាក៏បានជម្រុញឱ្យគ្រប់វត្តអារាម យកចិត្តទុកដាក់ជួយផ្សព្វផ្សាយអំពីគ្រោះថ្នាក់នៃគ្រឿងញៀនដល់ប្រជាពលរដ្ឋ ហើយក៏បានធ្វើការផ្សព្វផ្សាយអប់រំ រៀងរាល់ថ្ងៃសីលនៅថ្នាក់ជាតិ និងផ្សព្វផ្សាយនៅគ្រប់បណ្តាញផ្សព្វផ្សាយនានា។ ជាមួយគ្នានេះដែរ ព្រះសង្ឃ ព្រះចៅអធិការ មេគណ អនុគណ បានយាង និមន្តចុះសួរសុខទុក្ខ និងផ្តល់ឱវាទដល់អ្នកញៀនកំពុងផ្តាច់គ្រឿងញៀននៅតាមមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាបនិងព្យាបាលអ្នកញៀន។
- ការអប់រំផ្សព្វផ្សាយនៅតាមបណ្តាញសារព័ត៌មានៈ បានសហការជាមួយប្រព័ន្ធផ្សព្វផ្សាយរដ្ឋនិងឯកជន ក្នុងការចាក់ផ្សាយជាប្រចាំថ្ងៃឱ្យកាន់តែទូលំទូលាយថែមទៀត

ដើម្បីឱ្យមហាជន ជាពិសេសយុវជន យុវនារី សិស្ស-និស្សិត បានជ្រួតជ្រាបនូវពុទ្ធឱវាទ។ ផលិតស្ពតវីដេអូខ្លីៗ "ទេសចរណ៍គ្មានគ្រឿងញៀន" និងស្ពតជាភាសាខ្មែរ ភាសាបរទេស សម្រាប់ចាក់ផ្សាយនៅតាមបណ្តាញទូរទស្សន៍ក្នុងព្រះរាជាណាចក្រកម្ពុជា និងឯកសារវីដេអូអប់រំខ្លីផ្សេងទៀតសម្រាប់ចាក់ផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន។ បានជម្រុញឱ្យប្រព័ន្ធផ្សព្វផ្សាយដូចជាវិទ្យុ ទូរទស្សន៍រដ្ឋ ឯកជន សារព័ត៌មាន បង្កើនការផ្សព្វផ្សាយអប់រំអំពីបញ្ហាគ្រឿងញៀនឱ្យកាន់តែសកម្មថែមទៀត ជាពិសេសការអប់រំតាមកម្មវិធីនានារបស់អគ្គនាយកដ្ឋានវិទ្យុនិងទូរទស្សន៍ជាតិកម្ពុជា (ការដាក់សារជាអក្សររត់លើកញ្ចក់ទូរទស្សន៍) និងបានជម្រុញការផ្សព្វផ្សាយដល់ថ្នាក់ក្រោមជាតិដោយពង្រីកស្ថានីយ៍វិទ្យុដល់ ១៦ ខេត្ត-រាជធានីដែលស្ថានីយ៍ទាំងនេះមានតួនាទីផ្សាយបន្តផ្ទាល់ពីព្រឹត្តិការណ៍សំខាន់ៗជាច្រើនទាក់ទងទៅនឹងការអប់រំអំពីសង្គម សិទ្ធិ ច្បាប់ សុខភាព និងគ្រឿងញៀន។ ជាមួយគ្នានេះដែរ ក៏បានរៀបចំការផ្សព្វផ្សាយផ្ទាល់អំពីកម្មវិធីកីឡានានា ដែលបានអប់រំឱ្យបដិសេធគ្រឿងញៀនគ្រប់ប្រភេទ។

- ការអប់រំផ្សព្វផ្សាយនៅក្នុងឱកាសបុណ្យៈ បានធ្វើការរៀបចំពិធីផ្សព្វផ្សាយនៅគ្រប់បុណ្យជាតិនិងអន្តរជាតិសំខាន់ៗអំពីគ្រោះថ្នាក់នៃគ្រឿងញៀន និងការបដិសេធគ្រឿងញៀន ដូចជានៅក្នុងពិធីបុណ្យភ្ជុំបិណ្ឌ បុណ្យអុំទូក អកអំបុក សំពះព្រះខែ ផ្សព្វផ្សាយសារគ្រឿង-ញៀន នៅក្នុងបុណ្យទិវាកុមារអន្តរជាតិ ០១ មិថុនា បុណ្យទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន២៦មិថុនា ទិវាអនក្ខរកម្មជាតិ ថ្ងៃបើកបវេស្សនកាល។ល។ ជាមួយគ្នានេះដែរ បានរៀបចំប្រគំតន្ត្រីនៅទីសាធារណៈក្នុងទិវាបុណ្យជាតិ ដើម្បីឃោសនាផ្សព្វផ្សាយពីគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប៉ពានគ្រឿងញៀន សំដៅធ្វើការលើកកម្ពស់ការយល់ដឹងរបស់ប្រជាជន ពិសេសយុវវ័យឱ្យមានការប្រុងប្រយ័ត្ន និងចៀសវាងឱ្យបានពីគ្រឿងញៀន។
- ការអប់រំផ្សព្វផ្សាយនៅលើផលិតផលៈ បានណែនាំដល់ម្ចាស់រោងចក្រ-សិប្បកម្មផលិតទឹកពិសាដប និងផលិតផលវេចខ្ចប់ផ្សេងៗទៀតឱ្យបោះពុម្ព និងបិទសារអប់រំពីគ្រឿងញៀនលើផលិតផលរបស់ខ្លួនដូចជានៅលើវិក្កយបត្រ ដបទឹកសុទ្ធ ធុង កេស រថយន្តក្រុង ។ល។ ដែលមានខ្លឹមសារចំនួនបី គឺ "ការប្រើប្រាស់គ្រឿងញៀនជាអំពើខុសច្បាប់" "គ្រឿងញៀនបំផ្លាញអនាគតអ្នក និងសង្គម" និង "គ្រឿងញៀនបំផ្លាញអាយុជីវិត និងទ្រព្យសម្បត្តិរបស់អ្នក"។ ជាមួយគ្នានេះដែរ អគ្គីសនីកម្ពុជាក៏បានដាក់សារអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀននៅក្នុងវិក្កយបត្រទូទាត់ ដែលសារទាំងនេះនឹងទៅដល់គ្រប់ទីកន្លែងដែលមានបណ្តាញអគ្គីសនីទៅដល់។

- ការអប់រំផ្សព្វផ្សាយតាមសេវាកម្មកំសាន្តៈ ក្រសួងទេសចរណ៍ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ រួមជាមួយនឹងអាជ្ញាធរមូលដ្ឋានបានសហការជាមួយសមាគមសណ្ឋាគារកម្ពុជា សមាគមដឹកជញ្ជូនទេសចរណ៍ សេវាក្លឹបកំសាន្ត ទេសចរណ៍ផ្ទះសំណាក់ រៀបចំសិក្ខាសាលា វគ្គផ្សព្វផ្សាយអប់រំអំពីច្បាប់គ្រឿង-ញៀន គ្រោះថ្នាក់ដែលបណ្តាលមកពីគ្រឿងញៀន និងបញ្ហាគ្រឿងញៀន/មេរោគអេដស៍ ដល់អ្នកគ្រប់គ្រងបុគ្គលិកដែលផ្តល់សេវាស្នាក់នៅ សេវាដឹកជញ្ជូន និងសេវាកំសាន្ត នៅតាមតំបន់គោលដៅដែលងាយប្រឈមមួយចំនួន។ ជាមួយគ្នានេះដែរ បានផលិតផ្ទាំងរូបភាពដែលមានសារអប់រំបញ្ហាគ្រឿងញៀន មេរោគអេដស៍/ជំងឺអេដស៍ ការបញ្ឈប់ការប្រើប្រាស់អាវុធខុសច្បាប់ ការបញ្ឈប់ការជួញដូរមនុស្ស សម្រាប់ផ្សព្វផ្សាយនិងបិទនៅតាមទីតាំងគោលដៅនានា ។
- ការអប់រំផ្សព្វផ្សាយតាមរយៈដាក់សារនៅក្នុង ស៊ីឌី វីស៊ីឌី ខាអ៊ូខៈ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានណែនាំ និងបានសំរេចឱ្យក្រុមហ៊ុនផលិតកម្មភាពយន្ត ស៊ីឌី ខាអ៊ូខេ ដាក់សារអប់រំស្តីពីគ្រឿងញៀននៅគ្រប់ផលិតកម្មទាំងអស់ និងបានធ្វើការផ្សព្វផ្សាយជាប្រចាំនៅតាមបណ្តាញផ្សាយព័ត៌មាន កន្លែងកំសាន្តនានា។ល។ ជាក់ស្តែងបានធ្វើការណែនាំដល់បណ្តាផលិតកម្មភាពយន្ត-វីដេអូ ក្រុមហ៊ុននាំចូល-នាំចេញខ្សែភាពយន្ត និងអង្គការចំនួនបី (មណ្ឌលព័ត៌មានស្ត្រីកម្ពុជា អង្គការឆេមស៍ អង្គការសុខភាពគ្រួសារ អន្តរជាតិ)ឱ្យដាក់សារអប់រំពីគ្រឿងញៀននៅលើផលិតផលខ្សែភាពយន្ត-វីដេអូបានចំនួន ១៣៤ ចំណងជើង និងព្រមទាំងបានជម្រុញឱ្យអង្គភាពជំនាញតម្លើង និងសំដែងជូនសាធារណជននូវទម្រង់សិល្បៈទស្សនីយ៍ភាពអប់រំពីគ្រឿងញៀន។
- ការអប់រំផ្សព្វផ្សាយតាមរយៈការប្រឡងកំណាព្យ ចម្រៀង គំនូរៈ ការងារនេះគឺបានធ្វើជាប្រចាំនៅតាមកម្មវិធីប្រគំតន្ត្រីនានានៅតាមវិទ្យុ និងទូរទស្សន៍ ដោយមានការសហការជាមួយនឹងក្រសួងព័ត៌មាន ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងបណ្តាស្ថានីយ៍ទូរទស្សន៍នៅកម្ពុជា ជាពិសេសការចូលរួមពីបណ្តាសិល្បករ ពិធីករ តារាកំប្លែងនានា។ ជាមួយនេះដែរ អគ្គលេខាធិការដ្ឋានអ.ជ.ប.គ.ញ ដោយមានការសហការជាមួយនឹងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្តមួយចំនួន បានរៀបចំការប្រឡងកំណាព្យ និងចម្រៀង គំនូរអំពីការយល់ដឹងពីគ្រោះថ្នាក់នៃគ្រឿងញៀនក្នុងចំណោមសិស្សសាលារៀន និងបានយកស្នាដៃទាំងនេះទៅធ្វើការផ្សព្វផ្សាយ និងលើកទឹកចិត្តយុវជនឱ្យយល់ដឹងអំពីគ្រោះថ្នាក់នៃគ្រឿងញៀនឱ្យកាន់តែច្បាស់ ។

- វិធានការផ្សេងៗជាច្រើនទៀតក៏ត្រូវបានប្រកាន់យក ដើម្បីធ្វើឱ្យប្រជាជនក្រុមគោលដៅកែតែបានយល់ច្បាស់ពីគ្រោះថ្នាក់នៃគ្រឿងញៀននិងបដិសេធគ្រឿងញៀន។ វិធានការនេះគឺអនុវត្តន៍តាមគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាពដែលបញ្ហាគ្រឿងញៀនគឺជាប្រធានបទទី២ នៅក្នុងប្រធានបទទាំង៥។ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់បានរៀបចំជាវេទិកាពិភាក្សា ការផ្សព្វផ្សាយ ការរៀបចំសិក្ខាសាលា ការណែនាំនានាពាក់ព័ន្ធនឹងការទប់ស្កាត់បញ្ហាគ្រឿងញៀននៅថ្នាក់មូលដ្ឋាននីមួយៗ។

**១.៣. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀនៈ**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានសម្របសម្រួល បង្កើនកិច្ចសហប្រតិបត្តិការជាមួយក្រសួង/ស្ថាប័ន ជាសមាជិកគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត និងស្ថាប័នអនុវត្តច្បាប់នានា ចាត់វិធានការបង្ក្រាបបទល្មើសបានទាន់ពេលវេលាទាំងករណីប៉ុនប៉ងផលិត ចរាចរឆ្លងកាត់ ការជួញដូរ ចែកចាយ ករណីបង្វែរសារធាតុគីមីផ្សំ ជាទ្រង់ទ្រាយធំ មធ្យម និងតូច ក្នុងនោះបានបង្ក្រាបបទល្មើស ចំនួន៣.៥០៨ករណី ឃាត់ខ្លួនជនល្មើស ចំនួន៧.៧៦៦នាក់ ដោយបានបំផ្លាញនិងដកហូតគ្រឿងញៀន ជាច្រើនប្រភេទដូចជាៈ

- បានបំផ្លាញដំណាំកញ្ឆាលើផ្ទៃដី ចំនួន ១.៤៣៦,៤ម$^{២}$
- កញ្ឆាក្រៀម ចំនួន ៥២៧.០១៧,៣១ក្រាម
- មេតំហ្វេតាមីនគ្រាប់ ចំនួន ១.៧៩៣.៩១៧គ្រាប់
- មេតំហ្វេតាមីនម្សៅ ចំនួន ៥២.៧៨៩,៨៩៣ ក្រាម
- ហេរ៉ូអ៊ីន ចំនួន ៧៨.៦៣៥,៣៧ក្រាម
- កូកាអ៊ីន ចំនួន ៣៨.៨៧៧,៨១ក្រាម
- អ៊ិកស្តាស៊ី ចំនួន ១៣.៧០៣គ្រាប់
- កេតាមីន ចំនួន ៣.០៩១.៩៦ ក្រាម និង៨៩៥ ដប
- កូដេអ៊ីន ចំនួន ១០.១៦១គ្រាប់
- សារធាតុគីមីផ្សំ ចំនួន ៦២.១៧៦,២៥ គ.ក្រ
- ប្រេងម្រេះព្រៅ ចំនួន ៧១.៣២៥,៥៨ គ.ក្រ
- ថ្នាំដែលមានសារធាតុ Phsuedo Ephedrine ចំនួន ១២,៨ លានគ្រាប់
- បង្ក្រាប និងបំផ្លាញទីតាំងផលិតគ្រឿងញៀនចំនួន ០៥ កន្លែង ព្រមទាំងរឹបអូសសារធាតុគីមីផ្សំ និងឧបករណ៍សម្ភារមួយចំនួន។

នៅខែមេសា ឆ្នាំ២០០៧ អង្គភាពអនុវត្តច្បាប់គ្រឿងញៀនកម្ពុជា បានរកឃើញនិងបង្ក្រាបបាននូវមន្ទីរពិសោធន៍លួចលាក់ដ៏ធំមួយជាលើកដំបូង ដែលរៀបចំផលិតមេតំហ្វេតាមីននៅកម្ពុជាក្នុងឆ្នាំ២០០៧

ដែលបញ្ហានេះបានគូសបញ្ជាក់ពីលទ្ធភាព ដែលអាចមានកន្លែងផលិតគ្រឿងញៀនលួចលាក់ក្នុងប្រទេសកម្ពុជា។ ប្រតិបត្តិការដ៏ធំនេះបានកើតឡើងនៅក្នុងកសិដ្ឋានចិញ្ចឹមគោមួយចំងាយ៨១គ.ម ពីរាជធានីភ្នំពេញ នៅខេត្តកំពង់ស្ពឺ ដែលមានផលិតសារធាតុគីមីផ្សំសម្រាប់គ្រឿងញៀនមេតំហ្វេតាមីន ដែលគេស្គាល់ថាជា ក្លរ៉ូអេហ្វេឌ្រីន (Chloro Ephedrine)។ តាមរយៈកាកសំណល់ និង វត្ថុតាងនានាដែលរកឃើញនៅទីនោះ ការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្មសហប្រជាជាតិ UNODC និងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានធ្វើការប៉ាន់ស្មានថា មានសារធាតុគីមីផ្សំប្រភេទក្លរ៉ូអេហ្វេឌ្រីនលើសពីមួយតោនអាចត្រូវបានគេផលិតនៅកន្លែងនោះមុនពេលដែលសមត្ថកិច្ចបង្ក្រាបបាន។ ប៉ុន្តែពុំមានភស្តុតាងបញ្ជាក់ថាមានការផលិតគ្រឿងញៀននៅទីនោះនៅឡើយទេ។

នៅខែសីហា ឆ្នាំ២០០៧ កន្លែងផលិតគ្រាប់ថ្នាំមេតំហ្វេតាមីនចំនួនពីរត្រូវបានរកឃើញនៅក្នុងរាជធានីភ្នំពេញ ជាមួយនឹងការរឹបអូសបាននូវម៉ាស៊ីនបោះពុម្ពថ្នាំគ្រាប់ស្វ័យប្រវត្តិជាលើកដំបូងនៅកម្ពុជា ដែលមានសមត្ថភាពក្នុងការផលិតគ្រាប់ថ្នាំចំនួន ១០.០០០ គ្រាប់ក្នុងមួយម៉ោង។

ក្រៅពីសមិទ្ធិផលដែលគួរឱ្យកត់សំគាល់ខាងលើ នៅខែមិនា ឆ្នាំ២០០៩ កំលាំងអនុវត្តច្បាប់កម្ពុជាបានរកឃើញជាបន្តបន្ទាប់នូវករណីប៉ុនប៉ងចម្រាញ់សារធាតុគីមីផ្សំចេញពីដើមស្មៅអេហ្វេដ្រាដែលករណីនេះមានជាប់ពាក់ព័ន្ធទៅនឹងគោលដៅក្នុងខេត្តកំពង់ចាម រាជធានីភ្នំពេញនិងខេត្តតាកែវ។ សារធាតុគីមីជាច្រើនមុខ និងម្សៅអេហ្វេដ្រា ត្រូវបានរឹបអូស និងបំផ្លាញចោលនៅពេលក្រោយមក។ ជនល្មើសមួយចំនួនត្រូវបានចាប់ឃុំខ្លួនបញ្ជូនទៅតុលាការ។ លើសពីនេះទៀតមន្ត្រីអនុវត្តច្បាប់បានរកឃើញនិងបង្ក្រាបបានការលួចចម្រាញ់យកសារធាតុព្សីដូអេហ្វេឌ្រីន ពីឱសថដែលមានផ្ទុកសារធាតុព្សីដូអេហ្វេឌ្រីនដើម្បីនាំចេញទៅក្រៅប្រទេស និងករណីការលួចនាំចូលឱសថដែលមានផ្ទុកសារធាតុនេះពីក្រៅប្រទេសមកកម្ពុជា ក្នុងគោលបំណងចម្រាញ់យកសារធាតុផ្សំព្សីដូអេហ្វេឌ្រីននៅក្នុងប្រទេសកម្ពុជារួចបន្តនាំទៅក្រៅប្រទេស។

**១.៤. ភាពផ្ទើងប្រសិទ្ធភាពព្យាបាល ស្តារនីតិសម្បទា សមាហរណកម្ម:**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានខិតខំពុះពារសម្រេចឱ្យបាននូវកិច្ចការមួយចំនួនគួរជាទីមោទនៈដូចជា ៖

- បានរៀបចំបង្កើតសៀវភៅគោលការណ៍ណែនាំស្តីពីការបន្សាប និងព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ-ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅតាមបណ្តារាជធានី-ខេត្ត។ សៀវភៅនេះគឺជាឯកសារមូលដ្ឋានសម្រាប់ឱ្យគ្រូពេទ្យ និងអ្នកមានភារកិច្ចក្នុងការព្យាបាល និងផ្តល់ប្រឹក្សាយោបល់បញ្ហាគ្រឿងញៀនយកទៅប្រើប្រាស់ និងចែកផ្សាយទៅអ្នកពាក់ព័ន្ធ។

- រាជរដ្ឋាភិបាលសម្រេចផ្តល់នូវរបបជីវភាពជូនដល់ជនរងគ្រោះដែលកំពុងសំរាកព្យាបាល នៅតាមមណ្ឌលបណ្តោះអាសន្ន អប់រំ ព្យាបាល អ្នកញៀនគ្រឿងញៀន និងមណ្ឌលស្តារនីតិសម្បទាដែលគ្រប់គ្រងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងបានជម្រុញកម្មវិធីបន្សាប ព្យាបាលអ្នកញៀនគ្រឿងញៀនតាមនិយាមវេជ្ជសាស្ត្រនៅតាមមណ្ឌលបណ្តោះអាសន្ន អប់រំ និងព្យាបាលអ្នកញៀនគ្រឿងញៀនទាំងរបស់រដ្ឋ និងឯកជន ព្រមទាំងការរៀបចំកម្មវិធីគំរូមួយចំនួន សម្រាប់ឱ្យមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាទាំងអស់អនុវត្តន៍តាម។
- ជាមួយនឹងគោលនយោបាយកាត់បន្ថយចំនួនមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តយកការអនុវត្តកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ដែលកម្មវិធីនេះអនុវត្តន៍ដោយសេវាសុខភាពផ្លូវចិត្ត និងគ្រឿងញៀននៃក្រសួងសុខាភិបាល ដោយបានដំណើរការបណ្តុះបណ្តាលជំនាញមន្ត្រីកម្មវិធីព្យាបាលតាមហគមន៍ទាក់ទងនឹងការពិគ្រោះយោបល់ ការបន្សាបជាតិញៀន និងការព្យាបាលអ្នកញៀនគ្រឿងញៀន។ បានដកពិសោធន៍ការងារព្យាបាលដោយផ្អែកលើសហគមន៍ នៅខេត្តបន្ទាយមានជ័យ ដោយយកមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកមួយចំនួនជាកន្លែងសម្រាប់អនុវត្តកម្មវិធីដោយមានការគាំទ្របច្ចេកទេស និងថវិកាពីការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្មសហប្រជាជាតិ។ ជាមួយនេះដែរបានធ្វើការបណ្តុះបណ្តាបុគ្គលិក និងគ្រូពេទ្យដើម្បីពង្រីកកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកសហគមន៍ទៅកាន់តំបន់គោលដៅមួយចំនួនរួមមានៈ រាជធានីភ្នំពេញ ខេត្តបាត់ដំបង សៀមរាប ព្រះសីហនុ ក្រចេះ ស្ទឹងត្រែង និងរតនៈគីរី ។
- ការអនុវត្តកម្មវិធីព្យាបាលអ្នកប្រើគ្រឿងញៀនប្រភេទអាភៀន ដោយឱសថមេតាដូន ក៏បានដំណើរការនៅមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត ដែលកម្មវិធីនេះបានជួយគាំទ្រដល់ការព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀនប្រភេទអាភៀន ដែលបានបញ្ជូនមកដោយអង្គការដៃគូអនុវត្តកម្មវិធីម្ជុលស៊ីរ៉ាំង ដើម្បីកាត់បន្ថយការឆ្លងរីករាលដាលនៃមេរោគអេដស៍ និងជំងឺឆ្លង ផ្សេងៗតាមឈាម។
- ការរៀបចំយុទ្ធសាស្ត្រជាតិឆ្លើយតបមេរោគអេដស៍/ជំងឺអេដស៍ ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀនឆ្នាំ២០០៨-២០១០សម្រាប់ធ្វើជាឯកសារគោលអន្តរាគមន៍កាត់បន្ថយគ្រោះថ្នាក់នៅកម្ពុជា និងបានរៀបចំគោលការណ៍ណែនាំស្តីពីការអនុវត្តកម្មវិធីម្ជុលស៊ីរ៉ាំងនៅកម្ពុជា ដើម្បីជួយទប់ស្កាត់ការរីករាលដាលមេរោគអេដស៍-ជំងឺអេដស៍ក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀន។ អង្គការចំនួនពីរដែលបានទទួលការអនុញ្ញាតឱ្យដំណើរ

ពិសោធន៍អនុវត្តន៍កម្មវិធីម្ទុលសីរ៉ាំង នៅរាជធានីភ្នំពេញ គឺអង្គការមិត្តសម្លាញ់ និង កសាង។ តែមកទល់នឹងពេលនេះ មានតែអង្គការមិត្តសម្លាញ់តែមួយគត់ដែលទទួលបាន ជោគជ័យក្នុងការអនុវត្តកម្មវិធីដល់ពេលបច្ចុប្បន្ននេះ ហើយនៅឆ្នាំ២០១០គឺមានអង្គការ (KHANA)ដែលបានទទួលការអនុញ្ញាតឱ្យអនុវត្តន៍កម្មវិធីនេះ។

- ក្រោមការគាំទ្រជាជំនួយបច្ចេកទេស និងថវិកាពីអង្គការ FHI 360 ការវាយតំលៃអំពីលទ្ធ-ផល និងអនុសាសន៍សម្រាប់ការពង្រីកសេវា និងលើកកម្ពស់គុណភាពសេវា កម្មវិធីម្ទុលស៊ីរ៉ាំងនៅកម្ពុជាត្រូវបានរៀបចំឡើងដោយបង្ហាញគ្រប់ទិដ្ឋភាពនៃការប្រឈម និងដំណោះស្រាយនានាសម្រាប់លម្អកម្មវិធីនេះឱ្យរឹតតែប្រសើរឡើង។

**១.៨. ការពង្រឹងប្រសិទ្ធភាពអនុវត្តន៍ច្បាប់:**

- រាជរដ្ឋាភិបាលកម្ពុជា ដែលមានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាសេនាធិការ បានចាត់ទុកមន្ត្រីអនុវត្តច្បាប់គឺជាកំលាំងស្នូលរបស់ជាតិក្នុងការបង្ការ ទប់ស្កាត់ និង បង្ក្រាបការជាំជុះ ផលិត ការចរាចរ ការជួញដូរ ការស្តុកទុក និងការប្រើប្រាស់គ្រឿង ញៀនខុសច្បាប់។ ដើម្បីឱ្យកំលាំងប្រតិបត្តិការទាំងនេះប្រកបដោយគុណភាពមានសីល ធម៌វិជ្ជាជីវៈ និងប្រសិទ្ធភាព រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំឱ្យមាននីតិវិធីសម្រាប់គាំទ្រ ដល់ប្រតិបត្តិការបង្ក្រាបគ្រឿងញៀនដូចជា ការរៀបចំនីតិវិធីស្តីពីការប្រគល់ដោយមានការ ឃ្លាំមើលនិងការញុះញ៉ង់ឱ្យលក់គ្រឿងញៀនដោយខុសច្បាប់ ការណែនាំឱ្យមន្ត្រីអនុវត្ត ច្បាប់អនុវត្តនីតិវិធីនៃការប្រមូលវត្ថុតាងធ្វើកោសល្យវិច័យ ការពង្រឹងស្ថាប័នធ្វើកោសល្យ វិច័យរបស់អាជ្ញាធរជាតិ ការពង្រឹងយន្តការទំនាក់ទំនងព្រំដែន ព្រមទាំងការចាត់តាំងមន្ត្រី អនុវត្តន៍ច្បាប់ទាំងនគរបាលជាតិ កងរាជអាវុធហត្ថឱ្យទទួលខុសត្រូវការងារបង្ក្រាបគ្រឿង-ញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- ការអនុវត្តវិធានការរដ្ឋបាលក៏បានធ្វើផងដែរ ដោយសហការជាមួយអាជ្ញាធរដែនដី មន្ទីរ ទេសចរណ៍រាជធានី-ខេត្ត ដើម្បីធ្វើកិច្ចសន្យាជាមួយម្ចាស់មូលដ្ឋានអាជីវកម្ម សេវាកម្ម ទេសចរណ៍នានា ទីកន្លែងកំសាន្ត សប្បាយ ស្តីពីការទប់ស្កាត់ ការជួញដូរ ការចែកចាយ ការប្រើប៉ានគ្រឿងញៀនខុសច្បាប់។
- ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ចំនួន១៨កន្លែងត្រូវបានបង្កើតឡើងនៅតាម បណ្តោយព្រំដែនប្រទេស និងតាមដងទន្លេមេគង្គដើម្បីត្រួតពិនិត្យ និងទប់ស្កាត់ការជួញដូរ គ្រឿងញៀន និងសារធាតុគីមីផ្សំឆ្លងកាត់ព្រំដែន។

- មន្ត្រីអនុវត្តច្បាប់គ្រឿងញៀននៅតាមរាជធានី-ខេត្តចំនួន១១ ត្រូវបានបណ្តុះបណ្តាលលើជំនាញការងារត្រួតពិនិត្យគ្រឿងញៀន និងការកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប៉ាន់គ្រឿងញៀន។
- ឯកសារបណ្តុះបណ្តាលស្តីពីការងារត្រួតពិនិត្យសារធាតុគីមីផ្សំបានផលិតឡើងជា (DVD) សម្រាប់បណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីត្រួតពិនិត្យ។ ចំពោះឧស្សាហកម្មគីមីយើងក៏បានផលិតឯកសារជា(DVD) សម្រាប់ធ្វើការបណ្តុះបណ្តាលពួកគេ ដើម្បីចូលរួមក្នុងការទប់ស្កាត់ការបង្វែរសារធាតុគីមីផ្សំពីជំនួញស្របច្បាប់ទៅផលិតគ្រឿងញៀនខុសច្បាប់។
- មន្ត្រីការិយាល័យ(BLO) និងមន្ត្រីអនុវត្តច្បាប់នៅតាមតំបន់ព្រំដែនទទួលបានការបណ្តុះបណ្តាលពីជំនាញគ្រឿងញៀន និងការត្រួតពិនិត្យសារធាតុគីមីផ្សំ។
- ការដាក់ចេញនូវគោលការណ៍ប្រៀបសមភូមិប្រឆាំងបទល្មើសគ្រឿងញៀន និងគោលការណ៍ភូមិ-ឃុំ មានសុវត្ថិភាព របស់រាជរដ្ឋាភិបាល បានជួយពង្រឹងបន្ថែមឱ្យការអនុវត្តច្បាប់ប្រយុទ្ធប្រឆាំងគ្រឿងញៀនឱ្យរឹតតែមានប្រសិទ្ធភាព។ មន្ត្រីអនុវត្តច្បាប់ប្រឆាំងគ្រឿង-ញៀនត្រូវបានពង្រាយបន្ថែមពីថ្នាក់ជាតិទៅដល់ថ្នាក់ប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់ ដែលមន្ត្រីនគរបាលម្នាក់នៅថ្នាក់មូលដ្ឋាន ត្រូវបានប្រគល់ភារកិច្ចបន្ថែមឱ្យទទួលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន។
- ការពង្រឹងសមត្ថភាពរបស់សមាជិកក្រុមការងារអន្តរក្រសួង ត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀនដែលបានបង្កើតឡើងដើម្បីត្រួតពិនិត្យនិងតាមដានការប្រើប្រាស់សារធាតុគីមីផ្សំនៅក្នុងប្រទេស។
- ការងារបណ្តុះបណ្តាលក៏ត្រូវបានយកចិត្តទុកដាក់ ដើម្បីបង្កើនសមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់ក្នុងការឆ្លើយតបទៅនឹងបញ្ហាគ្រឿងញៀន។ មន្ត្រីអនុវត្តច្បាប់ដែលបម្រើការនៅតាមស្រុក ក្រុង ជាប់ព្រំដែនជិតនឹងការិយាល័យទំនាក់ទំនងព្រំដែន (BLO) នៅទូទាំងប្រទេស និងនៅតាមរាជធានី-ខេត្ត បានទទួលការបណ្តុះបណ្តាលជំនាញរយៈពេលខ្លី និងបានចូលរួមសិក្ខាសាលា ស្តីពីការអនុវត្តច្បាប់គ្រឿងញៀន ។
- ការផ្លាស់ប្តូរបទពិសោធន៍ និងការបណ្តុះបណ្តាលជំនាញនៅបរទេសក៏ត្រូវបានផ្តល់បន្ថែមដល់មន្ត្រីអនុវត្តច្បាប់គ្រឿងញៀនកម្ពុជា ពិសេសសមត្ថភាពក្នុងការធ្វើកិច្ចសហប្រតិបត្តិការរួមគ្នាជាមួយប្រទេសជិតខាងជាប់ព្រំដែននិងក្នុងតំបន់ដើម្បីទប់ស្កាត់ការជួញដូរគ្រឿង-ញៀន។

### ១.៦. ការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ:

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានបន្តពង្រឹង និងពង្រីកឥតឈប់ឈរនូវកិច្ចសហប្រតិ-បត្តិការជាមួយអន្តរជាតិតាមច្រើនរូបភាព:

#### ១.៦.១. កិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយប្រទេសជាប់ព្រំដែន:

ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នា, កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿញៀនជាមួយនឹងប្រទេសជិតខាងដែលរួមមាន: សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងព្រះរាជាណាចក្រថៃ ។ តាមរយៈនៃកិច្ចសហប្រតិបត្តិការនេះ ធ្វើឱ្យយើងទទួលបានលទ្ធផលមួយចំនួនគួរឱ្យកត់សំគាល់:

- ការផ្លាស់ប្តូរទស្សនៈកិច្ចរវាងថ្នាក់ដឹកនាំកំពូលនៃស្ថាប័នត្រួតពិនិត្យគ្រឿងញៀនរវាងកម្ពុជាឡាវ និងវៀតណាមជារៀងរាល់ឆ្នាំ និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី ត្រីភាគី រវាងកម្ពុជាវៀតណាមឡាវ បាននាំមកនូវសមិទ្ធិផលនិងជាកម្លាំងចលករយ៉ាងសំខាន់សម្រាប់អនុវត្តន៍ផែនការកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនរវាងប្រទេសទាំងបី។
- បានពង្រឹងយន្តការកិច្ចសហប្រតិបត្តិការរវាងស្ថាប័នត្រួតពិនិត្យគ្រឿងញៀនថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ពិសេសនៅខេត្ត ក្រុង ស្រុកជាប់ព្រំដែន កម្ពុជា តាមរយៈការប្រជុំផ្លាស់ប្តូរបទពិសោធន៍ទស្សនៈកិច្ចសិក្សា វគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការជួបគ្នាជាប្រចាំតាមករណីនីមួយៗរវាងក្រុង ស្រុក ជាប់ព្រំដែន។
- ការបង្កើតបានយន្តការអចិន្ត្រៃយ៍សម្រាប់ផ្លាស់ប្តូរព័ត៌មាននៅថ្នាក់មូលដ្ឋានតាមការិយាល័យទំនាក់ទំនងព្រំដែន (BLO) ដែលមាននៅតាមច្រកព្រំដែនអន្តរជាតិ។ យន្តការនេះបានធ្វើឱ្យកិច្ចសហប្រតិបត្តិការបង្ក្រាបគ្រឿងញៀនរឹតតែមានប្រសិទ្ធភាព ដោយយើងអាចរួមគ្នាទប់ស្កាត់បានជាបណ្តើរៗ នូវការចរាចរគ្រឿងញៀនឆ្លងកាត់ព្រំដែនពីប្រទេសមួយទៅប្រទេសមួយ។

#### ១.៦.២. កិច្ចសហប្រតិបត្តិការជាមួយអន្តរជាតិ:

នៅឆ្នាំ២០១២ កម្ពុជាក្នុងនាមជាប្រធានអាស៊ានបានដាក់ចេញនូវសេចក្តីថ្លែងការណ៍របស់ថ្នាក់ដឹកនាំអាស៊ានស្តីពីអាស៊ានគ្មានគ្រឿងញៀននៅឆ្នាំ២០១៥ ដែលនេះជាកម្លាំងចលករជម្រុញការអនុវត្តផែនទីបង្ហាញនៃសហគមន៍អាស៊ាន ឆ្នាំ២០០៩-២០១៥ ស្តីពីសហគមន៍អាស៊ានគ្មានគ្រឿងញៀន ។ ក្រៅពីកិច្ចសហប្រតិបត្តិការជាមួយនឹងប្រទេសជិតខាង យើងបានធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងប្រទេសនានាក្នុងតំបន់ តាមរយៈនៃយន្តការអាស៊ាន។ កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីគ្រឿងញៀនត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំ ដោយការប្តូរវេនគ្នាធ្វើជាម្ចាស់ផ្ទះ។ នៅក្នុងយន្តការនេះមានវេទិកាផ្សេងៗដូចជា

ដែលពាក់ព័ន្ធនឹងគ្រឿងញៀនដែលកម្ពុជាបានចូលរួមរៀបចំដោយផ្ទាល់ និងចូលរួមក្នុងឋានៈជាសមាជិកអាស៊ាន។

ជាមួយគ្នានេះដើម្បីអនុវត្តន៍តាមផែនការអាស៊ានគ្មានគ្រឿងញៀននៅឆ្នាំ ២០១៥ ប្រទេសជាសមាជិកអាស៊ាន បានរៀបចំផែនការអាសូត (ASOD Work Plan) ដើម្បីធ្វើជាយន្តការជាក់លាក់ និងអចិន្ត្រៃយ៍ក្នុងកិច្ចប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន ទាំងនៅក្នុងផ្ទៃប្រទេស និងអន្តរជាតិ។

កិច្ចសហប្រតិបត្តិការជាមួយនឹងប្រទេសនានាក្រៅតំបន់អាស៊ានក៏ត្រូវបានយកចិត្តទុកដាក់ផងដែរ ដូចជាយើងបានចុះអនុស្សារណៈនៃការយោគយល់គ្នា ស្តីពីការត្រួតពិនិត្យគ្រឿងញៀនជាមួយនឹងសាធារណរដ្ឋប្រជាមានិតចិន និងសាធារណរដ្ឋកូរ៉េ កិច្ចព្រមព្រៀងជាមួយនឹងសហព័ន្ធរុស្ស៊ី និងអនុស្សារណៈនៃការព្រមព្រៀងគ្នាជាមួយនឹងនគរបាលសហព័ន្ធអូស្ត្រាលី ។ល។

បន្ថែមពីនេះ កិច្ចសហប្រតិបត្តិការជាមួយនឹងប្រទេសនានាលើសកលលោកក៏ត្រូវបានលើកកម្ពស់ ដែលមានជាអាទិ៍៖ សហរដ្ឋអាមេរិក បារាំង កាណាដា ជប៉ុន ក្នុងការផ្លាស់ប្តូរព័ត៌មានគ្នាអំពីសភាពការណ៍គ្រឿងញៀន និងការពង្រឹងសមត្ថភាពត្រួតពិនិត្យគ្រឿងញៀន។

កម្ពុជាបានរួមសហការជាមួយអន្តរជាតិ ក្នុងការបង្ក្រាបករណីជួញដូរគ្រឿងញៀនឆ្លងប្រទេស និងករណីប៉ុនប៉ងផលិតសារធាតុគីមីផ្សំនៅក្នុងប្រទេស ដើម្បីនាំចេញទៅបរទេសបានជាច្រើនលើក ដោយបានឃាត់ខ្លួនឧក្រិដ្ឋជនអន្តរជាតិបានជាច្រើននាក់។ ជាងនេះទៅទៀត កម្ពុជាតែងទទួលបានការគាំទ្រផ្នែកបច្ចេកទេសជាច្រើនពីអន្តរជាតិដូចជាការបណ្តុះបណ្តាល ការផ្តល់សម្ភារបរិក្ខារសម្រាប់ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ការផ្តល់ជំនួយក្នុងការបន្សាបសារធាតុគីមីនៅកន្លែងផលិតគ្រឿងញៀនលួចលាក់ និងការដុតបំផ្លាញប្រេងម្រេះព្រៅភ្នំនៅកម្ពុជា។ល។

១.៦.៣. កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា

ចាប់តាំងពីកម្ពុជាបានចុះអនុស្សារណៈនៃការយោគយល់គ្នា ស្តីពីការត្រួតពិនិត្យគ្រឿងញៀននៅក្នុងប្រទេសមហាអនុតំបន់ទន្លេមេគង្គចាប់ពីឆ្នាំ១៩៩៥ មកយើងបានទទួលនូវការគាំទ្របច្ចេកទេសយ៉ាងច្រើនពីអង្គការដៃគូ និងប្រទេសផ្តល់ជំនួយនានា ពិសេសការគាំទ្រផ្នែកបច្ចេកទេសលើការងារពង្រឹងស្ថាប័ន និងការបណ្តុះបណ្តាលធនធានមនុស្ស។

ជាមួយគ្នានេះកម្ពុជាក៏បានទទួលការគាំទ្រពីអង្គការជាតិ និងអន្តរជាតិ ដូចជាៈ អង្គការសុខភាពពិភពលោក អង្គការ (JICA) អង្គការ (KOICA) អង្គការ (AusAID), (USAID) និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិមួយចំនួនទៀត ដូចជា (FHI 360) អង្គការ (KHANA) មិត្តសំឡាញ់ កម្ពុជា សមាគមយុវជនខ្មែរ។ល។ ដែលបានធ្វើសកម្មភាពជួយអប់រំ និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅកម្ពុជា។ អង្គការដៃគូទាំងអស់នោះធ្វើសកម្មភាពលើវិស័យផ្សេងៗគ្នាដូចជាៈការកាត់បន្ថយគ្រោះថ្នាក់

គ្រឿងញៀន ការបង្ការការពារគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រឿងញៀន និងការពង្រឹងប្រសិទ្ធភាពអនុវត្តន៍ច្បាប់។

រយៈពេល នៃការអនុវត្តយុទ្ធសាស្ត្រពហុវិស័យទាំង៥ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន យើងទទួលបានលទ្ធផលគួរឱ្យកត់សំគាល់ ដែលបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំហានទីពីររបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ សមិទ្ធិផលទាំងនេះបានក្លាយទៅជាមូលដ្ឋានគ្រឹះយ៉ាងរឹងមាំ សម្រាប់ការរៀបចំឱកាសអន្តរាគមន៍ឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីធ្វើឱ្យសំរេចបាននូវឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាអាស៊ាន ទាំងមូលដែលបានប្តេជ្ញាកសាងសហគមន៍អាស៊ានមួយគ្មានគ្រឿងញៀននៅឆ្នាំ២០១៥។

តែទោះជាយ៉ាងណាក៏ដោយ ផ្អែកតាមសភាពការណ៍ និងលទ្ធផលការងារខាងលើ យើងបានពិនិត្យឃើញនូវចំណុចខ្លាំង ចំណុចខ្សោយ និងចំណុចប្រឈមមួយចំនួននៅក្នុងការអនុវត្តផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដូចតទៅ:

**២. ចំណុចខ្លាំង:**

២.១. ការងារពង្រឹងស្ថាប័ន:

ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញារបស់អង្គការសហប្រជាជាតិទាំង៣ ស្តីពីគ្រឿងញៀនៈ (១). អនុសញ្ញាទោលស្តីពីថ្នាំញៀនឆ្នាំ១៩៦១ ដែលបានធ្វើវិសោធនកម្មដោយពិធីសារឆ្នាំ១៩៧២ (២). អនុសញ្ញាស្តីពីសារធាតុដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ឆ្នាំ១៩៧១ និង(៣). អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរខុសច្បាប់នូវថ្នាំញៀន សារធាតុដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ និងការប្រើប៉ពានគ្រឿងញៀនឆ្នាំ១៩៨៨ និងបានក្លាយជាសមាជិកអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មឆ្លងដែនរបស់អង្គការសហប្រជាជាតិ។

ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនថ្មីបានក្លាយជាមូលដ្ឋានគ្រឹះដ៏រឹងមាំ ក្នុងការពង្រឹងស្ថាប័នអនុវត្តន៍ច្បាប់គ្រឿងញៀននៅកម្ពុជា ដើម្បីទប់ស្កាត់ បង្ក្រាប និងបន្ថែមទម្ងន់ទោសចំពោះបទល្មើសគ្រឿងញៀនឱ្យកាន់តែជាក់ស្តែងក្នុងការបំផ្លាញដល់ឫសគល់នៃពួកក្រុមឧក្រិដ្ឋជន។

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនមាន ក្រសួងស្ថាប័ន ពាក់ព័ន្ធជាសមាជិកមានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ មានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត និងក្រុមការងារជំនាញមួយចំនួនទៀតដើម្បីជួយការងារតាមផ្នែកជំនាញ ដែលបានធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងនាយកដ្ឋានជំនាញទាំង៧របស់អគ្គលេខាធិការដ្ឋានជាប្រចាំក្នុងការអនុវត្តន៍ និងសម្របសម្រួលយន្តការពហុ-វិស័យស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

### ២.២. ការកាត់បន្ថយតម្រូវការគ្រឿងញៀន:

តាមការអំពាវនាវរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងឱកាសទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ មិថុនា និងនៅក្នុងសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០០៩ និងលើកទិសដៅឆ្នាំ២០១០ របស់អាជ្ញាធរ ជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន គ្រប់ក្រសួងស្ថាប័ន សមាជិកពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ អង្គការសង្គមស៊ីវិល សាសនា វិស័យឯកជន ប្រជាពលរដ្ឋ បានយល់ច្បាស់ពីគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រឿងញៀន និងបានរួមគ្នាឃោសនា ផ្សព្វផ្សាយអប់រំ ទៅដល់ក្រុមគោលដៅដែលងាយប្រឈមមុខខ្ពស់ជាអាទិ៍ យុវជន សិស្សានុសិស្សស្ត្រីរកស៊ីផ្លូវភេទ ស្ត្រីប្រកបរបរនៅកន្លែង កំសាន្ត ក្រុមបុរសស្រឡាញ់បុរស កម្មករសំណង់ និងពលករឆ្លងដែន។ល។ ឱ្យយល់ដឹងអំពីគ្រោះថ្នាក់នៃគ្រឿងញៀន កាត់បន្ថយឥរិយាបថដែលងាយរងគ្រោះ ដែលនាំទៅដល់ការប្រើប្រាស់ សារធាតុញៀន ឱ្យចេះបដិសេធ និងចាកចេញពីគ្រឿងញៀន។

### ២.៣. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន:

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសម្របសម្រួល និងបង្កើនកិច្ចសហការជាមួយក្រសួង ស្ថាប័នជាសមាជិក និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ព្រមទាំងស្ថាប័នអនុវត្តន៍ច្បាប់ជាតិ និងអន្តរជាតិ ដោយមានការរួមចំណែកផ្តល់ព័ត៌មានពីការិយាល័យទំនាក់ទំនងព្រំដែន (BLO) នៅតាមព្រំដែន បង្ក្រាបបានបទល្មើសទាន់ពេលវេលាទាំងករណីផលិត ចរាចរឆ្លងកាត់ ការជួញដូរចែកចាយជាទ្រង់ទ្រាយធំ មធ្យម និងតូច បានសំរេចលទ្ធផលគួរជាទីមោទនៈ រួមចំណែកក្នុងការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល។

### ២.៤. ការពង្រឹងប្រសិទ្ធភាពព្យាបាល ស្តារនីតិសម្បទា សមាហរណកម្ម:

រាជរដ្ឋាភិបាល ក៏ដូចជាអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានយកចិត្តទុកដាក់និងខិតខំពុះពារ ធ្វើឱ្យប្រសើរឡើង នូវការងារព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម អ្នកញៀនគ្រឿងញៀន តាមរយៈការដាក់ចេញនូវៈ អនុក្រឹត្យស្តីពីការបង្កើតមជ្ឈមណ្ឌលជាតិសម្រាប់ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងការផ្តល់របបជីវភាពដល់ជនរងគ្រោះដែលកំពុងសំរាកព្យាបាលនៅតាមមណ្ឌលបណ្តោះអាសន្ន អប់រំ បន្សាប ព្យាបាលអ្នកញៀនគ្រឿងញៀនរបស់រដ្ឋ។ ការអនុវត្តកម្មវិធីឯកភាពគ្នាក្នុងការបន្សាប ព្យាបាល និងស្តារនីតិសម្បទារបស់មណ្ឌលបណ្តោះអាសន្នថ្នាក់ជាតិ និងឯកជនតាមគោលការណ៍ណែនាំវេជ្ជសាស្ត្ររបស់ក្រសួងសុខាភិបាល។ ការអនុវត្តកម្មវិធីព្យាបាលផ្អែកសហគមន៍នៅក្នុងខេត្តបន្ទាយមានជ័យ និងការផ្សព្វផ្សាយបទពិសោធន៍ទាំងនោះនៅខេត្តក្រុងផ្សេងៗ ទៀត។ការដាក់ឱ្យអនុវត្តន៍កម្មវិធីព្យាបាលអ្នកប្រើគ្រឿងញៀនប្រភេទអាភៀនដោយឱសថមេតា

ជូន នៅមន្ទីរពេទ្យ មិត្តភាពខ្មែរ-សូវៀត និងការអនុវត្តកម្មវិធីម្ទុលស៊ីវ៉ាំងសម្រាប់អ្នកប្រើប្រាស់គ្រឿងញៀន នៅរាជធានី ភ្នំពេញ ដើម្បីកាត់បន្ថយអត្រារាលដាលនៃមេរោគអេដស៍។

**២.៥. ការពង្រឹងប្រសិទ្ធភាពអនុវត្តន៍ច្បាប់:**

សមត្ថភាពមន្ត្រីអនុវត្តច្បាប់ត្រូវបានលើកកម្ពស់ ពីជំនាញ ឆន្ទៈ សីលធម៌ វិជ្ជាជីវៈ និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនធ្វើឱ្យគុណភាពនៃកិច្ចប្រតិបត្តិការត្រូវបានល្អប្រសើរទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិតាមរយៈការបណ្តុះបណ្តាលជំនាញទាំងក្នុង និងក្រៅប្រទេស ដល់មន្ត្រីនគរបាលជាតិ មន្ត្រីកងរាជអាវុធហត្ថ មន្ត្រីនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ព្រមទាំង មន្ត្រីអនុវត្តន៍ច្បាប់ពាក់ព័ន្ធផ្សេងៗទៀត។

**២.៦. ការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ:**

ព្រះរាជាណាចក្រកម្ពុជាបានក្លាយជាប្រទេសហត្ថលេខីនៃអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១ ឆ្នាំ១៩៧១ ឆ្នាំ១៩៨៨ ពិធីសារឆ្នាំ១៩៧២។ បានចុះអនុស្សារណៈយោគយល់គ្នាជាមួយការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្មសហប្រជាជាតិ និងបានចុះអនុស្សារណៈយោគយល់គ្នា និងកិច្ចព្រមព្រៀងជាមួយប្រទេសជិតខាង ក្នុងតំបន់ និងអន្តរជាតិ ទាំងទ្វេភាគី និងពហុភាគី ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន។

៣. ចំណុចខ្សោយ:

- នៅថ្នាក់ជាតិ អង្គភាពដែលត្រូវបង្កើតឡើងដើម្បីអនុវត្តន៍ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅមិនទាន់បានបង្កើតឱ្យបានគ្រប់គ្រាន់។ ការរឹបអូស និងគ្រប់គ្រងទ្រព្យសម្បត្តិដែលបានមកពីការជួញដូរគ្រឿងញៀននៅពុំទាន់ដំណើរការបានល្អ ពិសេសការរៀបចំ និងប្រព្រឹត្តទៅនៃមូលនិធិរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅមិនដំណើរការដែលធ្វើឱ្យមានការខ្វះចន្លោះក្នុងការបំពេញភារកិច្ចប្រយុទ្ធប្រឆាំងគ្រឿងញៀន។
- យន្តការតាមដានជាប្រចាំនូវសភាពការណ៍គ្រឿងញៀន ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងគ្រឿងញៀន ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការធ្វើសមាហរណកម្ម ចំនួនអ្នកប្រើប្រាស់គ្រឿងញៀន ការត្រួតពិនិត្យ និងវាយតំលៃពីប្រសិទ្ធភាពនៃសកម្មភាពផ្សព្វផ្សាយ អប់រំអំពីបញ្ហាគ្រឿងញៀន នៅមានកម្រិត។
- ការអនុវត្តយន្តការពហុវិស័យមិនទាន់បានពង្រឹងនៅគ្រប់រាជធានី-ខេត្ត។ រាជធានី-ខេត្តមួយចំនួនច្រើនដាក់បន្ទុកការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ទៅលើអង្គភាពអនុវត្តច្បាប់ ហើយមិនទាន់បានចាត់ទុកថាជាការងារពហុវិស័យនៅឡើយ។

- វិធីសាស្ត្រអប់រំ បន្សាប ព្យាបាល នៅមណ្ឌលបណ្ដោះអាសន្នពុំទាន់មានលទ្ធភាព និងសមត្ថភាពអនុវត្តន៍បានពេញលេញតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល ស្ដីអំពីការបន្សាបគ្រឿងញៀននៅតាមមណ្ឌលបណ្ដោះអាសន្ន និងកម្មវិធីប្រចាំថ្ងៃដែលបានដាក់ឱ្យអនុវត្តន៍ដោយ អ.ជ.ប.គ.ញ ។ ការផ្ដល់សេវាសុខភាពតិចតួចដែលភាគច្រើនផ្ដោតលើការហាត់ប្រាណ និងការអប់រំផ្លូវចិត្ត មិនទាន់ឆ្លើយតបបានចំពោះអ្នកញៀនដែលស្ថិតក្រោមឥទ្ធិពលគ្រឿងញៀន ទាំងបរិមាណ និងគុណភាព។
- កម្មវិធីព្យាបាលដោយផ្អែកសហគមន៍នៅមានការយឺតយ៉ាវ និងមិនទាន់បានអនុវត្តន៍ឱ្យបានពេញលេញនៅតាមគ្រប់ឃុំ-សង្កាត់គោលដៅនៅឡើយ ហើយអ្នកប្រើប្រាស់គ្រឿងញៀនមួយចំនួននៅពុំទាន់ភ្ញាក់រលឹក ចូលរួមសហការក្នុងសកម្មភាពកាត់បន្ថយការប្រើប្រាស់គ្រឿងញៀន
- ការឃោសនាផ្សព្វផ្សាយឱ្យចេះបដិសេធ និងចាកចេញពីគ្រឿងញៀន ការលើកកម្ពស់ការយល់ដឹងអំពីបញ្ហាគ្រឿងញៀន និងការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ ដែលបណ្ដាលមកពីការប្រើប្រាស់គ្រឿងញៀន ក្នុងស្រទាប់មហាជន យុវជន និងមន្ត្រីអនុវត្តច្បាប់ក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀននៅមានកម្រិត។
- សមត្ថភាពធនធានមនុស្ស និងលទ្ធភាពផ្នែកមធ្យោបាយ សម្ភារ និងថវិកា របស់ស្ថាប័នត្រួតពិនិត្យគ្រឿងញៀននៅមានកម្រិត។ ជាមួយគ្នានេះ ការយល់ដឹងរបស់មន្ត្រីអនុវត្តច្បាប់នៅមានកម្រិតទាំងសមត្ថភាព និងឧបករណ៍បច្ចេកទេស សម្រាប់ប្រើប្រាស់ក្នុងការរុករកគ្រឿងញៀនពិសេសមន្ត្រីនៅតាមតំបន់គោលដៅ និងច្រកព្រំដែន។
- ការសហការគ្នារវាងមន្ត្រីអនុវត្តច្បាប់ ព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេត អង្គការដៃគូដែលអនុវត្តន៍កម្មវិធីនៅគោលដៅ ជាមួយរដ្ឋអំណាចនៅមូលដ្ឋាន ក្នុងការអនុវត្តច្បាប់គ្រឿងញៀននៅកន្លែងខ្លះ និងករណីខ្លះ នៅមិនទាន់ស៊ីជំរៅ និងរលូននៅឡើយ។
- កិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនជាមួយប្រទេសជិតខាងនៅមិនទាន់បានពេញលេញតាមស្មារតីដែលបានព្រមព្រៀងគ្នានៅឡើយ។ ដំណើរការរបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) គឺមិនទាន់បានរលូន ធ្វើឱ្យថយចុះនូវប្រសិទ្ធភាពនៃកិច្ចសហការនិងការទប់ស្កាត់បញ្ហាគ្រឿងញៀនចូលមកក្នុងប្រទេស។

៤.ចំណុចប្រឈម:

ទន្ទឹមនឹងចំណុចខ្លាំង និងចំណុចខ្សោយខាងលើ យើងពិនិត្យឃើញមានបញ្ហាប្រឈមមួយចំនួន ដែលធ្វើឱ្យមានការលំបាកដល់ការអនុវត្តផែនការជាតិគឺ៖

- ប្រទេសកម្ពុជាស្ថិតនៅជិតតំបន់ត្រីកោណមាស ដែលជាប្រភពនៃការផលិតគ្រឿងញៀនគ្រប់ប្រភេទព្រមទាំងមានលក្ខណៈភូមិសាស្ត្រអំណោយផលដល់ពួកឧក្រិដ្ឋជនគ្រឿងញៀនធ្វើចរាចរ

ឆ្លងកាត់។ ពួកឧក្រិដ្ឋជនអន្តរជាតិនៅតែប៉ុនប៉ងយកគ្រឿងញៀនឆ្លងកាត់ ផលិត កែច្នៃ តាមរយៈបណ្តាញចាត់តាំង និងមានបច្ចេកទេសស្មុគ្រស្មាញជាងមុន។

- និន្នាការនៃការផលិតគ្រឿងញៀនសំយោគមានការកើនឡើង ស្របពេលនឹងតម្រូវការនៃសារធាតុគីមីផ្សំដ៏ច្រើនលើសលប់សម្រាប់បំរើឱ្យវិស័យឧស្សាហកម្ម គួបផ្សំនឹងសមត្ថភាពមន្រ្តីអនុវត្តច្បាប់ក្នុងការត្រួតពិនិត្យ និងគ្រប់គ្រងសារធាតុគីមីផ្សំទាំងនោះនៅមានកម្រិត ជាឱកាសឱ្យពួកឈ្មួញគ្រឿងញៀនលួចបង្វែរសារធាតុទាំងនេះទៅផលិតគ្រឿងញៀនខុសច្បាប់។
- ការប្រយុទ្ធប្រឆាំងគ្រឿងញៀនរបស់បណ្តាប្រទេសទាំងអស់ក្នុងតំបន់ពុំទាន់បានអនុវត្តន៍ព្រមៗគ្នា ស៊ីសង្វាក់គ្នានៅឡើយ ដោយផ្អែកលើកត្តាខុសៗគ្នាជាច្រើនដូចជា ច្បាប់ សមត្ថភាពមន្រ្តីអនុវត្តច្បាប់ ធនធាន សម្ភារ សីលធម៌វិជ្ជាជីវៈ ដែលជាហេតុបង្កឱកាសឱ្យឧក្រិដ្ឋជនគ្រឿងញៀនធ្វើសកម្មភាពបាន។
- ប្រទេសក្នុងតំបន់ និងលើសកលលោកពុំទាន់រកឃើញរូបមន្តដែលអនុវត្តន៍បានជាសកល ក្នុងការព្យាបាល ស្តារនីតិសម្បទា សមាហរណកម្ម ចាកចេញពីគ្រឿងញៀន និងការលាប់ឡើង វិញ។
- ការធ្វើអន្តោប្រវេសន៍ដោយខុសច្បាប់ជាច្រើនទៅប្រទេសជិតខាង។
- វិបត្តិហិរញ្ញវត្ថុពិភពលោក ធ្វើឱ្យកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀនមានកម្រិត។

ផ្អែកលើលទ្ធផលនៃការអនុវត្តផែនការជាតិ៥ឆ្នាំ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០០៥-២០១០ និងផែនការសកម្មភាពឆ្នាំ២០១១-២០១២ ព្រមទាំងតាមការវាយតម្លៃទៅលើចំណុចខ្លាំង ចំណុចខ្សោយ និងចំណុចប្រឈមខាងលើដើម្បីឱ្យមាននិរន្តរភាពប្រសិទ្ធភាពនៃការត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា រាជរដ្ឋាភិបាលបានសំរេចដាក់ចេញឱ្យអនុវត្តន៍បន្តនូវផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ ២០១៣-២០១៥ ដូចតទៅ:

# ជំពូកទី ៣
## គោលការណ៍ គោលបំណង យុទ្ធសាស្ត្រ និងទិសដៅការយុទ្ធសាស្ត្រ

### ក. គោលការណ៍:

ផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន ២០១៣-២០១៥ ប្រកាន់យកគោលការណ៍ប្រមូលកម្លាំងរបស់ជាតិទាំងមូលដើម្បីអនុវត្តនីតិវិធានការជាលក្ខណៈពហុវិស័យគ្រប់ជ្រុងជ្រោយ និងទូលំទូលាយដោយសមធម៌ មិនរើសអើង និងគោរពសិទ្ធិមនុស្ស។

### ខ. គោលបំណង

បន្តអនុវត្តន៍ឱ្យកាន់តែមានប្រសិទ្ធភាពនូវយុទ្ធសាស្ត្រទាំង៥ ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដើម្បីបង្ការទប់ស្កាត់ការប្រើប្រាស់បំពានគ្រឿងញៀន ប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀន និងត្រួតពិនិត្យរាល់សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀន និងធានាការអនុវត្តកាតព្វកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជាដែលជាភាគីនៃអនុសញ្ញា និងពិធីសាររបស់អង្គការសហប្រជាជាតិដែលទាក់ទងនឹងគ្រឿងញៀន រួមចំណែកក្នុងការលើកកម្ពស់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈសង្គម លើកស្ទួយសុខុមាលភាព និងឈានទៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ រួមចំណែកសម្រេចឱ្យបានតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២របស់រាជរដ្ឋាភិបាល និងគោលដៅអាស៊ានគ្មានគ្រឿងញៀនឆ្នាំ២០១៥។

### គ. យុទ្ធសាស្ត្រ:

រាជរដ្ឋាភិបាលកម្ពុជាបានបន្តអនុវត្តន៍នូវយុទ្ធសាស្ត្រទាំង៥ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដូចខាងក្រោម:

១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

៣. ការពង្រឹងប្រសិទ្ធភាពព្យាបាល ស្តារនីតិសម្បទា និងធ្វើសមាហរណកម្ម

៤. ការពង្រឹងប្រសិទ្ធភាពអនុវត្តន៍ច្បាប់

៥. ការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ

**ឃ. ទិសដៅការយុទ្ធសាស្ត្រ:**

ដើម្បីអនុវត្តន៍ការងារឱ្យសម្រេចបានតាមយុទ្ធសាស្ត្រទាំង៥ខាងលើ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានដាក់ចេញនូវទិសដៅការយុទ្ធសាស្ត្រចំនួន៧ មានដូចខាងក្រោមៈ

១ .ការអប់រំ ផ្សព្វផ្សាយ បង្ការទប់ស្កាត់ បដិសេធគ្រឿងញៀន

២. ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំនិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

៦. កិច្ចសហប្រតិបត្តិការអន្តរជាតិប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងក្រោមជាតិ

# ជំពូកទី ៤

# កម្មវិធីសកម្មភាពសម្រាប់អនុវត្តន៍ទិសដៅយុទ្ធសាស្ត្រ

<u>ទិសដៅយុទ្ធសាស្ត្រទី១៖</u> ការអប់រំ ផ្សព្វផ្សាយ បង្ការទប់ស្កាត់ បដិសេធគ្រឿងញៀន។

១. <u>កម្មវិធី:</u> ការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីគ្រឿងញៀននិងផលប៉ះពាល់នៃគ្រឿងញៀននៅក្នុងសង្គម។

<u>សកម្មភាព:</u>

១.១. ផ្សព្វផ្សាយដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីគ្រោះថ្នាក់ នៃគ្រឿងញៀន ដល់សាធារណៈជន ជាពិសេសយុវវ័យដើម្បីបង្ការទប់ស្កាត់ ការប្រើបំពានគ្រឿងញៀន ការបដិសេធ និងចាកចេញពីគ្រឿងញៀន និងការរីករាលដាលជំងឺអេដស៍ ដែលបណ្ដាលមកពីការប្រើបំពានគ្រឿងញៀនក្នុងចំណោមយុវវ័យ។

១.២ រៀបចំជាយន្តការច្បាស់លាស់នៅគ្រប់បណ្ដាស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន (រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ) ដើម្បីផ្សព្វផ្សាយពីផលប៉ះពាល់នៃគ្រឿងញៀន ជាពិសេសនៅតាមកន្លែងសំខាន់ៗមួយចំនួន ដូចជារោងភាពយន្ត ក្លឹបកំសាន្ត សាលារៀន រោងចក្រ ទីផ្សារ ទីប្រជុំជនសំខាន់ៗ និងគោលដៅដែលងាយកើតឡើងដោយគ្រឿងញៀន។

១.៣. រៀបចំកម្មវិធីប្រលងកំណាព្យ គំនូរ កីឡា ចំរៀង តន្ត្រី អប់រំអំពីគ្រឿងញៀននៅតាមបណ្ដាខេត្តគោលដៅ។

១.៤. រៀបចំកម្មវិធីផ្សព្វផ្សាយ អប់រំអំពីច្បាប់និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅក្នុងកម្មវិធីបុណ្យជាតិនិងអន្តរជាតិធំៗ។

១.៥. សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធនានាធ្វើសកម្មភាពលើកកម្ពស់ការយល់ដឹងអំពីការកាត់បន្ថយគ្រោះថ្នាក់ (Harm Reduction) ដែលបណ្ដាលមកពីការប្រើបំពានគ្រឿងញៀន ដើម្បីទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ ជំងឺអេដស៍ ដែលបណ្ដាលមកពីការប្រើបំពានគ្រឿងញៀនដល់ក្រុមអ្នកប្រើគ្រឿងញៀនដោយចាក់។

១.៦. សុំគោលការណ៍ពីរាជរដ្ឋាភិបាល ក្នុងការផ្សព្វផ្សាយអំពីបទពិសោធន៍ល្អៗ និងវិធីសាស្ត្រ ដែលធ្លាប់បានអនុវត្តន៍នៅបណ្ដាប្រទេសមួយចំនួនចំពោះក្រុមអ្នកប្រើគ្រឿងញៀនដោយចាក់។

១.៧. សម្របសម្រួលបង្កើតយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំស្ដីពីការរៀបចំឯកសារផ្សព្វផ្សាយនានាជាមួយស្ថាប័នពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីលើកកម្ពស់ការយល់ដឹងពីគ្រោះថ្នាក់នៃគ្រឿងញៀន និងការឆ្លងរាលដាលមេរោគអេដស៍ ជំងឺអេដស៍ ដែលបណ្ដាលមកពីការប្រើបំពានគ្រឿងញៀនចាប់ពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ។

១.៨.សម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ ប្រព័ន្ធផ្សព្វផ្សាយ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ដើម្បីឱ្យក្រុមឃោសនាចល័តមានលទ្ធភាពធ្វើយុទ្ធនាការដោយទៀងទាត់នៅតាមចំណុចគោលដៅ។

១.៩. វាយតម្លៃអំពីលទ្ធផលនៃសកម្មភាពលើកកម្ពស់ការយល់ដឹង ដើម្បីពិនិត្យឡើងវិញពីគុណសម្បត្តិ និងគុណវិបត្តិ។ បទពិសោធន៍ទាំងឡាយដែលបានមកពីការវាយតម្លៃនេះនឹងយកទៅអនុវត្តន៍សម្រាប់ការងារអប់រំ និងផ្សព្វផ្សាយនាពេលអនាគត។

២. <u>កម្មវិធី:</u> ការលើកទឹកចិត្តឱ្យមានការចូលរួមពីគ្រប់ផ្នែកនៃសង្គមក្នុងការប្រយុទ្ធប្រឆាំងគ្រឿង-ញៀន។

<u>សកម្មភាព:</u>

២.១. សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធបន្តចរចាឱ្យគ្រប់ផ្នែកនៃសង្គមទាំងអស់ ជាពិសេសប្រព័ន្ធឃោសនា ផ្សព្វផ្សាយ ទូរទស្សន៍-វិទ្យុរបស់រដ្ឋ និងឯកជន ក្រុមហ៊ុនទូរគមនាគមន៍ ចូលរួមអនុវត្តន៍កាតព្វកិច្ចក្នុងការឃោសនា ផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹងពីគ្រោះថ្នាក់នៃគ្រឿងញៀន និងទប់ស្កាត់ការរីករាលដាលនៃការប្រើបំពានគ្រឿងញៀន។

២.២. បន្តការដាក់ខ្លឹមសារអប់រំពីគ្រឿងញៀននៅលើផលិតផលប្រើប្រាស់ និង VCD/CD ភាពយន្ត ការ៉ាអូខេ។ល។

២.៣. រៀបចំឱ្យមានការប្រជុំជាទៀងទាត់ជាមួយអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល ព្រមទាំងអតីតអ្នកធ្លាប់ប្រើប្រាស់គ្រឿងញៀន ដើម្បីឱ្យពួកគេចូលរួមក្នុងសកម្មភាពលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីគ្រឿងញៀន។

២.៤. រៀបចំឱ្យមានការប្រគំតន្ត្រីអប់រំពីគ្រោះថ្នាក់នៃការប្រើបំពានគ្រឿងញៀនក្នុងកម្មវិធី[illegible] និងចម្លើយពីបញ្ហាគ្រឿងញៀន ការឆ្លើយឆ្លងតាមទូរស័ព្ទ [illegible] កម្មវិធីនេះ: ការផ្ដល់រង្វាន់លើកទឹកចិត្តដល់អ្នកដែលបានចូលរួម [illegible]

ទៀត ក្នុងការទាក់ទាញសាធារណជន ពិសេសដើម្បីបំផុសយុវវ័យឱ្យចូលរួមក្នុងកម្មវិធីសំខាន់ៗទាំងអស់ខាងលើនេះ។

២.៥. រៀបចំយន្តការអប់រំផ្សព្វផ្សាយពីគ្រោះថ្នាក់គ្រឿងញៀន ដល់ប្រតិបត្តិករទេសចរណ៍ និងអ្នកបំពីសេវាកម្មទេសចរណ៍ផ្សេងៗទៀតតាមរយៈការបញ្ច្រាបយ៉េនឌ័រ នៅតាមតំបន់ទេសចរណ៍សំខាន់ៗ និងគោលដៅដែលប្រឈមដល់បញ្ហាគ្រឿងញៀន។

៣. <u>កម្មវិធី:</u> ការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំផែនការក្នុងការបង្កើនកម្មវិធីអប់រំអំពីបញ្ហាគ្រឿងញៀន និងការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ដែលបណ្តាលមកពីការប្រើប៉ាន់គ្រឿងញៀនទៅក្នុងកម្មវិធីសិក្សាជាតិនៅគ្រប់កំរិតសិក្សាទាំងក្នុង និងក្រៅប្រព័ន្ធ។

<u>សកម្មភាព:</u>

៣.១. រៀបចំផែនការជាក់លាក់មួយក្នុងការបង្កើនកម្មវិធីអប់រំអំពីគ្រឿងញៀន និងការរីករាលដាលជំងឺអេដស៍ ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀនទៅក្នុងកម្មវិធីសិក្សាជាតិនៅគ្រប់កំរិតសិក្សាទាំងក្នុង និងក្រៅប្រព័ន្ធ ជាពិសេសចំពោះវិធីសាស្ត្រនានាដែលធ្វើឱ្យចេះបដិសេធ និងចាកចេញពីគ្រឿងញៀន ក្នុងចំណោមសិស្សនិស្សិត និងធ្វើយ៉ាងណាឱ្យពួកគេអាចក្លាយខ្លួនជាជនបង្គោល។

៣.២. រៀបចំយន្តការសាលារៀនបៃតងគ្មានគ្រឿងញៀនពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ។

៤. <u>កម្មវិធី:</u> ការជម្រុញរៀបចំយន្តការសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពបង្ការទប់ស្កាត់ការប្រើប៉ាន់គ្រឿងញៀន និងចងក្រងឯកសារស្តីពីបទពិសោធន៍អំពីសកម្មភាពត្រួតពិនិត្យគ្រឿងញៀន ដើម្បីធានាឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់នៅពេលអនាគត។

<u>សកម្មភាព:</u>

៤.១. សិក្សាស្រាវជ្រាវស្ទាបស្ទង់ជាទូទៅលើការប្រើប៉ាន់គ្រឿងញៀនក្នុងគោលបំណង:

ក/ ស្វែងយល់អំពីមូលហេតុ និងផលវិបាកនៃការប្រើប៉ាន់គ្រឿងញៀន និងការលាប់ឡើងវិញ។

ខ/ វាយតម្លៃប្រសិទ្ធភាពនៃកិច្ចអន្តរាគមន៍បង្ការទប់ស្កាត់ដែលកំពុងបានអនុវត្តន៍ ។

គ/ ស្វែងយល់ពីបញ្ហាថ្មីៗទាំងឡាយដែលពាក់ព័ន្ធនឹងការប្រើប៉ាន់គ្រឿងញៀននិងជំងឺអេដស៍ ដែលតម្រូវឱ្យមានកិច្ចអន្តរាគមន៍បន្ទាន់។

៤.២. ធ្វើការអង្កេតជាទៀងទាត់ដើម្បីតាមដាននិន្នាការនៃការប្រើប្រាស់គ្រឿងញៀន និងការរីករាលដាលជំងឺអេដស៍ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន។ តួលេខនៃការអង្កេតឆ្នាំដំបូងនឹងត្រូវបានប្រើប្រាស់ជាឯកសារយោង សម្រាប់ធ្វើការប្រៀបធៀបទៅអនាគត។

៤.៣. មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀនរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវចងក្រងឯកសារព្រមទាំងផ្លាស់ប្តូរព័ត៌មាន និងបទពិសោធន៍ស្តីពីសកម្មភាពត្រួតពិនិត្យគ្រឿងញៀនជាមួយស្ថាប័នអង្គភាពពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលដទៃទៀត។ អង្គភាពនោះនឹងសហការជាមួយនាយកដ្ឋាននីតិកម្ម អប់រំ និងស្តារនីតិសម្បទា ព្រមទាំងនាយកដ្ឋានពាក់ព័ន្ធនានា ដើម្បីស្វែងរកវិធីសាស្ត្រថ្មីៗដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការអប់រំសាធារណជន ជាពិសេសស្រទាប់យុវវ័យអំពីបញ្ហាគ្រឿងញៀន។

**<u>ឧបាយការយុទ្ធសាស្ត្រទី២៖</u>** ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំនិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន។

១. កម្មវិធី: ការព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍តាមរយៈសេវាសុខភាពផ្លូវចិត្ត និងគ្រឿងញៀនរបស់ក្រសួងសុខាភិបាល។

<u>សកម្មភាព:</u>

១.១. ពង្រីកកម្មវិធីព្យាបាលតាមសហគមន៍ តាមគំរូលទ្ធផលនៃការសិក្សានៅខេត្តបន្ទាយមានជ័យ ដោយមានការគាំទ្រពីសេវាសុខភាពផ្លូវចិត្ត និងគ្រឿងញៀនរបស់ក្រសួងសុខាភិបាល ក្នុងការព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមសហគមន៍។

១.២. បណ្តុះបណ្តាលមន្ត្រីអំពីជំនាញ ស្តីពីការព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមសហគមន៍ និងតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីនេះ ដោយសហការជាមួយដៃគូនានា។

១.៣. រាជរដ្ឋាភិបាលកម្ពុជា អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងអង្គការសហប្រជាជាតិ នឹងសកម្មក្នុងការស្វែងរកការគាំទ្រថវិកា ដើម្បីពង្រីកកម្មវិធីព្យាបាលតាមសហគមន៍ (CBTx) នៅគ្រប់កន្លែង អាទិភាពក្នុងប្រទេសកម្ពុជា។

២. <u>កម្មវិធី:</u> ការអនុវត្តកម្មវិធីថែទាំ ព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀនប្រភេទអាភៀនដោយឱសថមេតាដូន។

<u>សកម្មភាព:</u>

២.១.បន្តអនុវត្តន៍កម្មវិធីផ្តល់សេវាថែទាំព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀនប្រភេទអាភៀន រួមទាំងអ្នកដែលប្រើតាមរយៈការចាក់នឹងម្ជុលដោយឱសថមេតាដូន នៅទីក្រុងភ្នំពេញ និងពិចារណាក្នុងការពង្រីកសេវាទៅកាន់កន្លែងដែលមានអាត្រានៃអ្នកប្រើប្រាស់គ្រឿងញៀនប្រភេទអាភៀនខ្ពស់។

២.២.បន្តកម្មវិធីផ្តល់សេវាម្ជុល ស៊ីរ៉ាំង និងកម្មវិធីផ្តល់សេវាថែទាំ ព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀនប្រភេទអាភៀនដោយឱសថមេតាដូន ដើម្បីកាត់បន្ថយការឆ្លងមេរោគអេដស៍ ក្នុងចំណោមអ្នកប្រើគ្រឿងញៀននិងអ្នកដែលវិលទៅរកការប្រើគ្រឿងញៀនដោយការចាក់វិញ។

២.៣.បង្កើតប្រព័ន្ធមួយសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីផ្តល់សេវាថែទាំព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀនប្រភេទអាភៀន ដោយឱសថមេតាដូន និងប្រសិទ្ធភាពនៃកម្មវិធីនេះ។

៣. <u>កម្មវិធី:</u> ការរៀបចំសេចក្តីព្រាងគោលនយោបាយមួយ ស្តីពីការព្យាបាល ស្តារនីតិសម្បទា និងធ្វើសមាហរណកម្មអ្នកញៀនគ្រឿងញៀន។

<u>សកម្មភាព:</u>

៣.១. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ រួមជាមួយក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា និងស្ថាប័នពាក់ព័ន្ធនានារៀបចំសេចក្តីព្រាងគោលនយោបាយមួយស្តីពីការព្យាបាល ស្តារនីតិសម្បទា និងធ្វើសមាហរណកម្មអ្នកញៀនគ្រឿងញៀនដើម្បីដាក់ជូនរាជរដ្ឋាភិបាលអនុម័ត។ ថវិកាសម្រាប់ដំណើរការការព្យាបាល ស្តារនីតិសម្បទា និងធ្វើសមាហរណកម្មអ្នកញៀនគ្រឿងញៀនត្រូវស្នើទៅរាជរដ្ឋាភិបាល ដោយស្ថាប័នដែលទទួលបន្ទុកការងារនេះ។

៣.២. រៀបចំគោលនយោបាយស្តីពីការព្យាបាលអ្នកញៀនគ្រឿងញៀននៅក្នុងពន្ធនាគារ។

៣.៣.ធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំស្តីពីការអនុវត្តកម្មវិធីម្ជុលស៊ីរ៉ាំងនៅកម្ពុជាដើម្បីឱ្យកម្មវិធីនេះអាចអនុវត្តន៍បានតាមប្រព័ន្ធសុខាភិបាល។

៣.៤.រៀបចំផែនការឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍ ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន២០១៣-២០១៥។

៤. <u>កម្មវិធី:</u> ការរៀបចំបង្កើតរចនាសម្ព័ន្ធរបស់មជ្ឈមណ្ឌលព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន។

<u>សកម្មភាព:</u>

៤.១. ជម្រុញឱ្យដំណើរការនូវមជ្ឈមណ្ឌលជាតិសម្រាប់ព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅខេត្តព្រះសីហនុ ឈានទៅកាត់បន្ថយជាបណ្តើរៗនូវមណ្ឌលបណ្តោះអាសន្ន។

៤.២. រៀបចំចេនាសម្ព័ន្ធ និងបទប្បញ្ញត្តិនានា ដែលចាំបាច់សម្រាប់កិច្ចដំណើរការរបស់មជ្ឈមណ្ឌលដោយមានការចូលរួមពីក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ និងស្ថាប័នពាក់ព័ន្ធផ្សេងៗ។

៤.៣. បង្កើតក្រុមការងារផ្សេងៗដែលទទួលបន្ទុកលើវិស័យបច្ចេកទេសដូចជា វិធីសាស្រ្តនៃការព្យាបាល ការបន្សាបជាតិពុល។ ការពិភាក្សានិងការពិគ្រោះយោបល់ជាមួយនឹងអ្នកមានវិជ្ជាជីវៈក្នុង និងក្រៅប្រទេសនឹងត្រូវអនុវត្តន៍ដោយក្រុមការងារទាំងនោះដើម្បីស្វែងរកគោលការណ៍ឯកភាពជាតិទៅលើវិធីសាស្រ្តព្យាបាល ការបន្សាបជាតិពុលសម្រាប់ដាក់ឱ្យប្រើនៅតាមមជ្ឈមណ្ឌលជាតិ និងមណ្ឌលបណ្តោះអាសន្ន។

៤.៤ រៀបចំកម្មវិធីបណ្តុះបណ្តាលបំនិនជីវិតនៅតាមមណ្ឌលបណ្តោះអាសន្ននានា របស់រដ្ឋ និងឯកជន ព្រមទាំងតាមសហគមន៍ ។

៤.៥ រៀបចំយន្តការសម្រាប់តាមដានការធ្វើសមាហរណកម្មរបស់អ្នកចាកចេញពីគ្រឿង-ញៀនវិលត្រឡប់ទៅរស់នៅក្នុងសហគមន៍ និងគ្រួសារវិញ

៥. កម្មវិធី: ការរៀបចំបង្កើតក្រុមផ្តល់ប្រឹក្សានៅតាមសហគមន៍។

សកម្មភាព:

៥.១. បង្កើតក្រុមផ្តល់ប្រឹក្សានៅតាមសហគមន៍ សម្រាប់ចុះទៅជួយពន្យល់ណែនាំអ្នកញៀនគ្រឿងញៀន នៅតាមសហគមន៍ និងគ្រួសារឱ្យមកទទួលយកការព្យាបាល និងតាមដានអ្នកប្រើប្រាស់គ្រឿងញៀន ក្រោយពេលធ្វើសមាហរណកម្មដើម្បីបង្ការការលាប់ ។

៥.២. ក្រុមផ្តល់ប្រឹក្សាត្រូវលើកទឹកចិត្តឱ្យមានការចូលរួមពីសហគមន៍ ក្រុមគ្រួសារអ្នកធ្លាប់ប្រើគ្រឿងញៀន និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការព្យាបាលស្តារនីតិសម្បទា និងសមាហរណកម្ម។ ការចូលរួមនេះនឹងត្រូវបានចាត់ទុកជាផ្នែកសំខាន់មួយនៃកម្មវិធីព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍។

៦. កម្មវិធី: ការលើកកម្ពស់សមត្ថភាពមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។

<u>សកម្មភាព:</u>

៦.១. ជម្រុញកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌល ព្យាបាលនិងស្តារនីតិសម្បទាជាមួយនឹងមជ្ឈមណ្ឌលដទៃទៀតនៅក្នុងតំបន់ និងសកលលោក ដើម្បីលើកកម្ពស់សមត្ថភាពបច្ចេកទេសរបស់បុគ្គលិកមជ្ឈមណ្ឌលដោយមានការគាំទ្រពីក្រុមអង្គការសហប្រជាជាតិ។

៦.២. រៀបចំកម្មវិធីទស្សនកិច្ចសិក្សា ឬផ្លាស់ប្តូរបទពិសោធន៍នៅមជ្ឈមណ្ឌល ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាក្នុងតំបន់ដោយមានការគាំទ្រពីក្រុមអង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិ។

៦.៣. រៀបចំបណ្តុះបណ្តាលបុគ្គលិក ដែលបម្រើការក្នុងមជ្ឈមណ្ឌលនូវជំនាញសំខាន់ៗដូចជា: ការជួយជាបឋម ការពិគ្រោះយោបល់ ការបន្សាបជាតិពុល វិធីសាស្រ្តនៃការព្យាបាលបញ្ហាគ្រឿងញៀន និងជំងឺអេដស៍ ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាលជំងឺផ្លូវចិត្ត ការផ្តល់បំនិនជីវិត និងការធ្វើសមាហរណកម្មចូលក្នុងសង្គម។

៦.៤. បន្តរៀបចំគោលរបប និងផ្តល់ការគាំទ្រខាងផ្នែកវេជ្ជសាស្ត្រ ដើម្បីពង្រឹងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋដែលមានបច្ចុប្បន្ន។

**<u>ទិសដៅការយុទ្ធសាស្ត្រទី៣៖</u>** ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់។

១. <u>កម្មវិធី:</u> ការជម្រុញការអនុវត្តការងារនីតិកម្មឱ្យមានប្រសិទ្ធភាព។

<u>សកម្មភាព:</u>

១.១. ផ្សព្វផ្សាយ និងបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់អំពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១.២. សម្របសម្រួលជាមួយដៃគូនានា ដើម្បីស្វែងរកការគាំទ្រផ្នែកបច្ចេកទេសក្នុងការរៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងអនុសញ្ញាអន្តរជាតិនានា។

១.៣. អ.ជ.ប.គ.ញ ចាត់តាំងតំណាងស្របច្បាប់ ដើម្បីជម្រុញតាមដានការជំនុំជំរះក្តីរបស់តុលាការនៅគ្រប់ករណីដែលពាក់ព័ន្ធបញ្ហាគ្រឿងញៀន។

២. <u>កម្មវិធី:</u> ការជម្រុញការអនុវត្តអនុសញ្ញាអន្តរជាតិ ឆ្នាំ១៩៦១ ១៩៧១ ១៩៨៨ ពិធីសារឆ្នាំ១៩៧២ និងអនុសញ្ញាស្តីពីការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនឱ្យមានប្រសិទ្ធភាព។

<u>សកម្មភាព:</u>

២.១. ជម្រុញឱ្យបណ្តាស្ថាប័នពាក់ព័ន្ធនានា របស់រាជរដ្ឋាភិបាលអនុវត្តន៍តាមស្មារតីអនុសញ្ញាទាំងបី ១៩៦១ ១៩៧១ ១៩៨៨ ពិធីសារឆ្នាំ១៩៧២ និងអនុសញ្ញាស្តីពីការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនឱ្យមានប្រសិទ្ធភាព។

២.២. អ.ជ.ប.គ.ញ រាយការណ៍ជូនទៅរាជរដ្ឋាភិបាលកម្ពុជា និងក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ (INCB) អំពីភាពជឿនលឿននៃការអនុវត្តតាមស្មារតីនៃអនុសញ្ញាទាំងនោះ។

៣. __កម្មវិធី:__ ការរៀបចំតាក់តែងបទដ្ឋានគតិយុត្តិនានា និងការជម្រុញការអនុវត្តច្បាប់ទាំងឡាយដែលពាក់ព័ន្ធ នឹងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឱ្យមានប្រសិទ្ធភាព។

- __សកម្មភាព:__

៣.១. ការរៀបចំបទដ្ឋាននានាទាក់ទងនឹងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឱ្យឆាប់បានចូលជាធរមាន ដូចជា:

ក/ ព្រះរាជក្រឹត្យស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

ខ/ អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

គ/ អនុក្រឹត្យស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការត្រួតពិនិត្យសកម្មភាពស្របច្បាប់ទាក់ទងទៅនឹងគ្រឿងញៀន។

ឃ/អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

ង/ អនុក្រឹត្យស្តីពីនីតិវិធីលំអិតសម្រាប់វិធីសាស្ត្រព្យាបាល និងការគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន។

ច/ ប្រកាសស្តីពីបែបបទ នីតិវិធី និងលក្ខខណ្ឌលំអិតនៃការឃ្លាំមើលការឆ្លងកាត់ និងការញុះញង់ឱ្យលក់គ្រឿងញៀន និង

ឆ/ បទដ្ឋានគតិយុត្តផ្សេងៗទៀតទាក់ទងទៅនឹងការងារត្រួតពិនិត្យគ្រឿងញៀន

៣.២. សិក្សាលើការប្រើប្រាស់ច្បាប់នានាដែលមានជាធរមាន (ក្រៅពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន) ក្នុងការទប់ស្កាត់ឱ្យមានប្រសិទ្ធភាពចំពោះបទល្មើសដែលទាក់ទងទៅនឹងគ្រឿងញៀន។

៤. <u>កម្មវិធី:</u> ការបង្កើនកិច្ចសហប្រតិបត្តិការទប់ស្កាត់ការផលិត ការចរាចរ ការចែកចាយគ្រឿងញៀនខុសច្បាប់ និងពង្រឹងប្រសិទ្ធភាពការងារស៊ើបអង្កេតរបស់ស្ថាប័នអនុវត្តច្បាប់។

<u>សកម្មភាព:</u>

៤.១. បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយមន្ត្រីអនុវត្តច្បាប់ (នគរបាលជាតិ កងរាជអាវុធហត្ថជាតិ គយ កាំកុងត្រូល.. ) និងអាជ្ញាធររាជធានី-ខេត្ត ព្រមទាំងក្រុង ស្រុក-ខ័ណ្ឌ តាមរយៈការ រៀបចំកិច្ចប្រជុំជាទៀងទាត់ ដែលក្នុងពេលនោះអង្គភាពនីមួយៗនឹងត្រូវរាយការណ៍អំពីវឌ្ឍនភាពក្នុងការអនុវត្ត និងបទពិសោធន៍ដែលបានជួបប្រទះ ដើម្បីមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀនរក្សាទុកជាឯកសារសម្រាប់ធ្វើការវិភាគ និងផ្សព្វផ្សាយ។

៤.២. អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយមានការជួយគាំទ្រពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងសហគមន៍ផ្តល់ជំនួយនានា ធ្វើការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់គ្រឿងញៀន នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អំពីការងារស៊ើបអង្កេតប្រឆាំងបទល្មើសគ្រឿងញៀន។

៤.៣.ដោយមានការឧបត្ថម្ភគាំទ្រពីសហគមន៍ផ្តល់ជំនួយនានា អាជ្ញាធរជាតិ ត្រូវផ្តល់នូវមធ្យោបាយ សម្ភារ ដែលមានសារៈសំខាន់សម្រាប់ការងារស៊ើបអង្កេតដល់ស្ថាប័នអនុវត្តច្បាប់នានាពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។

៤.៤. ពង្រឹងសមត្ថភាពមន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់នានា (ចៅក្រម ព្រះរាជអាជ្ញា នគរបាល កងរាជអាវុធហត្ថ គយ) ដើម្បីអនុវត្តន៍ច្បាប់ត្រួតពិនិត្យគ្រឿងញៀនឱ្យមានប្រសិទ្ធភាព។

៤.៥. ជម្រុញកិច្ចសហប្រតិបត្តិការពហុវិស័យស្តីពីការត្រួតពិនិត្យគ្រឿងញៀនដើម្បីកសាងបានភូមិ ឃុំ សង្កាត់ស និងសាលារៀនបៃតងគ្មានគ្រឿងញៀន ។

៥. <u>កម្មវិធី:</u> ការបំផុសឱ្យមានការចូលរួមផ្តល់ព័ត៌មានពីសាធារណជនអំពីការផលិត ការចរាចរ ការជួញដូរគ្រឿងញៀនខុសច្បាប់។

<u>សកម្មភាព:</u>

៥.១. លើកទឹកចិត្តឱ្យមានការចូលរួមពីសាធារណជន ក្នុងការផ្តល់ព័ត៌មានដល់មន្ត្រីពាក់ព័ន្ធទៅនឹងការចរាចរ ការផលិត ការស្តុកទុក និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ដើម្បីរួមចំណែកអនុវត្តន៍គោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព[illegible]បាល។

៥.២. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវតាមដានគ្រប់ករណីគ្រឿងញៀនដែលបានបញ្ជូនទៅតុលាការវិនិច្ឆ័យទោស ហើយមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀនរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងត្រូវទទួលរ៉ាប់រងធ្វើរបាយការណ៍និងរក្សាទុកជាឯកសារចំពោះលទ្ធផលនៃវិនិច្ឆ័យលើករណីនិមួយៗ ។

៦. <u>កម្មវិធី:</u> ការពង្រឹង និងពង្រីកការិយាល័យទំនាក់ទំនងព្រំដែន (BLO)។

<u>សកម្មភាព:</u>

៦.១. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវស្វែងរកការគាំទ្រពីបណ្ដាប្រទេសផ្ដល់ជំនួយនានាពិសេសអង្គការ UN ដើម្បីបន្តពង្រឹងការិយាល័យទំនាក់ទំនងព្រំដែន (BLO) បច្ចុប្បន្ន ដោយសហប្រតិបត្តិការជាមួយប្រទេសជិតខាង និងពង្រីកទៅកាន់តំបន់ព្រំដែនយុទ្ធសាស្ត្រផ្សេងៗទៀតដូចជាកំពង់ផែអន្តរជាតិអាកាសយានដ្ឋានអន្តរជាតិ និងបណ្ដាខេត្តព្រំដែនតាមដងទន្លេមេគង្គ។

៦.២. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ដោយមានការឧបត្ថម្ភគាំទ្រពីអង្គការ UN ឬសហគមន៍អន្តរជាតិនានា ត្រូវបង្កើតប្រព័ន្ធផ្ដល់ព័ត៌មានរហ័ស (Early Warning Sysmtem) ដោយរាប់បញ្ចូលទាំងពិធីសារ និងគោលការណ៍ណែនាំសម្រាប់ការិយាល័យទំនាក់ទំនងព្រំដែន និងបណ្ដាញពាក់ព័ន្ធរបស់ខ្លួនរួមទាំងស្ថាប័នដែលពាក់ព័ន្ធនៅក្នុងនិងក្រៅប្រទេសសម្រាប់តាមដានករណីការប្រគល់ដោយមានការឃ្លាំមើល (Controlled Deliveries) និងករណីសង្ស័យដទៃទៀត។ កសាងមូលដ្ឋានទិន្នន័យស្ដីពីឧក្រិដ្ឋជន និងជនសង្ស័យដើម្បីធ្វើការផ្លាស់ប្ដូរព័ត៌មាន និងជូនដំណឹងដល់ដៃគូដែលពាក់ព័ន្ធទាំងក្នុងប្រទេស និងលើសកលលោក។

៦.៣. ពង្រឹងការដឹកនាំ និងសមត្ថភាពមន្ត្រីការិយាល័យទំនាក់ទំនងព្រំដែន (BLO)។

៧. <u>កម្មវិធី:</u> ការលើកកម្ពស់សមត្ថភាពជំនាញដល់មន្ត្រីមន្ទីរពិសោធន៍គ្រឿងញៀន។

<u>សកម្មភាព:</u>

៧.១. លើកកម្ពស់សមត្ថភាពអ្នកបច្ចេកទេសមន្ទីរពិសោធន៍គ្រឿងញៀនរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ តាមរយៈការបណ្ដុះបណ្ដាលនៅក្នុង និងក្រៅប្រទេស។

៧.២. លើកកំពស់សមត្ថភាពជំនាញ និងផ្ដត់ផ្គង់សម្ភារបរិក្ខារចាំបាច់ទៅនៅមន្ទីរពិសោធន៍គ្រឿងញៀនរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ដែលមានស្រាប់ ដោយគិតទាំងការធានាសុវត្ថិភាព និងសុខភាពរបស់មន្ត្រីដែលបំពេញការងារនៅទីនោះ។

៧.៣. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សហការជាមួយអង្គការដៃគូ ដើម្បីស្វែងរកការជួយគាំទ្រក្នុងការផ្តល់សារធាតុញៀនគំរូទាំងឡាយដល់មន្ទីរពិសោធន៍គ្រឿងញៀនរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ។

៧.៤. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សហការជាមួយអង្គការដៃគូ ដើម្បីស្វែងរកការជួយគាំទ្រក្នុងការផ្តល់នូវតេស្តបឋមគ្រឿងញៀន និងសារធាតុគីមីផ្សំគ្រឿងញៀនទាំងឡាយដល់មន្ទីរពិសោធន៍គ្រឿងញៀន ដើម្បីផ្តល់ជូនមន្ត្រីអនុវត្តច្បាប់។

៧.៥. អ.ជ.ប.គ.ញ ដោយមានការជួយគាំទ្រពីដៃគូនានា នឹងបង្កើតមន្ទីរពិសោធន៍ខ្នាតតូចនៅតាមតំបន់អាទិភាពមួយចំនួន។ មន្ទីរពិសោធន៍ទាំងនោះនឹងស្ថិតនៅក្រោមការណែនាំបច្ចេកទេសពីមន្ទីរពិសោធន៍ របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ។

៨. <u>កម្មវិធី:</u> ការបន្តប្រើប្រាស់យន្តការបណ្តុះបណ្តាលតាមកុំព្យូទ័រ (CBT) ដើម្បីពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់។

<u>សកម្មភាព:</u>

៨.១. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវស្វែងរកការគាំទ្រពីប្រទេសអ្នកផ្តល់ជំនួយនានាពិសេសអង្គការ UN ដើម្បីបន្តប្រើប្រាស់និងពង្រីកយន្តការបណ្តុះបណ្តាលដោយកុំព្យូទ័រ (CBT) សំដៅពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់។

៨.២. ការបណ្តុះបណ្តាលតាមវិធីផ្សេងៗទៀត នឹងត្រូវយកមកអនុវត្តន៍សម្រាប់មន្ត្រីអនុវត្តច្បាប់ និងអាជ្ញាធរមានសមត្ថកិច្ចទាំងអស់ផងដែរ ដើម្បីទប់ស្កាត់នូវការរីករាលដាលយ៉ាងឆាប់រហ័ស និងស្មុគស្មាញនៃបណ្តាញឧក្រិដ្ឋជន។ ការផ្តល់នូវឧបករណ៍សម្ភារ និងមធ្យោបាយទំនាក់ទំនងនឹងត្រូវបានយកចិត្តទុកដាក់។

៨.៣. វាយតម្លៃពីតម្រូវការរបស់បណ្តាស្ថាប័នអនុវត្តច្បាប់គ្រឿងញៀននានា ពិសេសនគរបាលប្រឆាំងគ្រឿងញៀននិងកសាងផែនការឆ្លើយតបទៅនឹងកង្វះខាតទាំងនេះ

៨.៤. ការវាយតំលៃពីប្រសិទ្ធភាពនៃការបណ្តុះបណ្តាលតាមកុំព្យូទ័រនឹងត្រូវធ្វើឡើងដោយទៀងទាត់តាមរយៈការពិនិត្យពិចារណាលើលទ្ធផលនៃការរឹបអូសគ្រឿងញៀន និងការចាប់ខ្លួនឧក្រិដ្ឋជន។

៩. <u>កម្មវិធី:</u> ការពង្រឹងការអនុវត្តច្បាប់ដើម្បីគាំទ្រដល់កម្មវិធីកាត់បន្ថយគ្រោះថ្នាក់។

<u>សកម្មភាព:</u>

៩.១. បង្កើតកម្មវិធីបណ្តុះបណ្តាលស្តីពីការកាត់បន្ថយគ្រោះថ្នាក់ ដើម្បីដាក់បញ្ចូលទៅក្នុងសាលានគរបាលភូមិភាគចំនួន៦កន្លែង។

៩.២.បង្កើតកម្មវិធីនៃនីតិវិធីប្រតិបត្តិការគំរូសម្រាប់មន្ត្រីអនុវត្តច្បាប់និងមន្ត្រីមូលដ្ឋានអំពីការកាត់បន្ថយគ្រោះថ្នាក់ និងការជួយគាំទ្រដល់កម្មវិធីកាត់បន្ថយគ្រោះថ្នាក់នៅសហគមន៍។

៩.៣.បង្កើតក្រុមការងារមួយដែលមានសមាសភាពមកពីអង្គភាពអនុវត្តច្បាប់ និង អង្គភាពនានាដើម្បីពិភាក្សាក្នុងការគាំទ្រ និងអនុវត្តសកម្មភាពកាត់បន្ថយគ្រោះថ្នាក់ រួមទាំងអន្តរាគមន៍ចំពោះកម្មវិធីផ្តល់សេវាថែទាំ ព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀនប្រភេទអាភៀនដោយឱសថមេតាដូន។

៩.៤.ធ្វើការសិក្សាជារួមអំពីលទ្ធភាពទូទៅនៃការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់នៅ ទីក្រុងភ្នំពេញ ដោយផ្តោតទៅលើការគាំទ្រពីមន្ត្រីអនុវត្តច្បាប់ ។

__ខឈានការយុទ្ធសាស្ត្រទី៤៖__ ការត្រួតពិនិត្យសារធាតុគីមីផ្សំ

១. __កម្មវិធី:__ ការបង្កើនការគ្រប់គ្រងសារធាតុគីមីផ្សំគ្រឿងញៀន និងសារធាតុញៀនដែលប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ។

__សកម្មភាព:__

១.១. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច (កងកំលាំងប្រដាប់អាវុធ គយ កាំកុងត្រូល) អាជ្ញាធរដែនដី ក្រសួងសុខាភិបាល ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល មន្ត្រី (BLO) និងគំរោងអនុតំបន់ដែលពាក់ព័ន្ធរបស់ UNODC ដើម្បីពង្រឹងការគ្រប់គ្រងសារធាតុគីមីផ្សំដែលបានផលិតនាំចូល-នាំចេញ ទាំងស្របច្បាប់ និងខុសច្បាប់ សម្រាប់ប្រើប្រាស់ ស្តុកទុក ដាក់លក់ និងចែកចាយ។ កិច្ចការនេះ មិនពាក់ព័ន្ធដល់នីតិវិធីនៃការសំរេចឱ្យនាំចូលសម្រាប់ក្រុមហ៊ុនវិនិយោគ ដែលមានក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំដោយឡែកនោះទេ។

១.២. បណ្តុះបណ្តាលជំនាញត្រួតពិនិត្យសារធាតុគីមីផ្សំដល់មន្ត្រីអនុវត្តច្បាប់ដែលបំពេញការងារនៅតាមច្រក និងតំបន់គោលដៅ។

១.៣.ពង្រឹងយន្តការអនុវត្តរបស់ក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន។

១.៤. ពង្រឹងការអនុវត្តយន្តការផ្តល់ព័ត៌មានជាមុនស្តីអំពីការ នាំចេញនាំចូលសារធាតុគីមីផ្សំនិងសារធាតុដែលប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទ(PreExport Notification)។

២. <u>កម្មវិធី:</u> ការជម្រុញការរៀបចំបទបញ្ញត្តិនានា និងកសាងផែនការស្តីពីការត្រួតពិនិត្យសារធាតុដែលប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទ ដើម្បីទប់ស្កាត់ការបង្វែរសារធាតុគីមីផ្សំពីជំនួញស្របច្បាប់ទៅផលិតគ្រឿងញៀនខុសច្បាប់ និងបណ្តុះបណ្តាលជំនាញដល់ស្ថាប័នអនុវត្តច្បាប់។

<u>សកម្មភាព:</u>

២.១. រៀបចំចងក្រងឯកសារ បទប្បញ្ញត្តិនានា ស្តីពីការត្រួតពិនិត្យសារធាតុគីមីផ្សំ និងសារធាតុដែលប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទ។

២.២.បង្កើតនិងអនុវត្តផែនការត្រួតពិនិត្យសារធាតុគីមីផ្សំសម្រាប់ក្រសួង ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ និងឧស្សាហកម្មគីមីដើម្បីទប់ស្កាត់ការបង្វែរសារធាតុគីមីផ្សំពីជំនួញស្របច្បាប់ទៅផលិតគ្រឿងញៀនខុសច្បាប់។

២.៣. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានារៀបចំសិក្ខាសាលាកម្មវិធីបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់អំពីគោលការណ៍បទដ្ឋាននានា ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងជំនាញក្នុងការត្រួតពិនិត្យសារធាតុគីមីផ្សំ និងសារធាតុដែលប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទ។

៣. <u>កម្មវិធី:</u> ការរៀបចំផែនការគ្រប់គ្រង និងត្រួតពិនិត្យការផលិត និងការចរាចរប្រេងរុក្ខជាតិដែលមានផ្ទុកសារធាតុសាហ្វ្រូលខ្ពស់ចម្រាញ់ចេញពីដើមម្រះព្រៅភ្នំ និងរុក្ខជាតិផ្សេងៗទៀត។

<u>សកម្មភាព:</u>

៣.១.ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរៀបចំយន្តការដាក់លាក់ ដើម្បីគ្រប់គ្រងនិងត្រួតពិនិត្យតំបន់មានដុះដើមម្រះព្រៅភ្នំក្នុងគោលបំណង និងសមកម្មភាពបង្ការទប់ស្កាត់ការកាប់បំផ្លាញ ការផលិត ការចរាចរប្រេងម្រះព្រៅភ្នំ និងអភិវឌ្ឍន៍កម្មវិធីដំណាំជំនួស។

៣.២. រៀបចំទស្សនកិច្ចសិក្សាសម្រាប់មន្ត្រីជំនាញពាក់ព័ន្ធនានា ដើម្បីស្វែងយល់ពីបទពិសោធន៍ជាក់ស្តែងរបស់បណ្តាប្រទេសក្នុងតំបន់ពាក់ព័ន្ធនឹងកម្មវិធីដំណាំជំនួស។

៣.៣. មជ្ឈមណ្ឌលព័ត៌មានរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ដោយមានការជួយគាំទ្រពីអង្គការ UN និងដៃគូអភិវឌ្ឍន៍នានា ធ្វើការស្រាវជ្រាវពី[illegible]

ប្រសិទ្ធភាពបំផុតស្ដីពីការអភិវឌ្ឍដំណាំជំនួស និងធ្វើការចែករំលែកបទពិសោធន៍ទាំងនេះជូនដល់សហគមន៍ និងក្រុមគ្រួសារដែលពាក់ព័ន្ធ។

**ទិសដៅការយុទ្ធសាស្ត្រទី៥៖** កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន។

១. កម្មវិធី: ការជម្រុញយន្តការភូមិ - ឃុំ បៃតងគ្មានគ្រឿងញៀននៅតាមតំបន់ព្រំដែន។

សកម្មភាព:

១.១. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត រៀបចំយន្តការភូមិ ឃុំ បៃតងគ្មានគ្រឿងញៀននៅតាមបណ្ដោយព្រំដែន ដើម្បីជម្រុញការអនុវត្តយន្តការ ភូមិ ឃុំ មានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល។

១.២. អគ្គលេខាធិការដ្ឋានអ.ជ.ប.គ.ញ រួមជាមួយខេត្តជាប់ព្រំដែន ធ្វើការជ្រើសរើសភូមិ ឃុំអាទិភាពនិងកំណត់ខ្លឹមសារសម្រាប់ការអនុវត្តដកបទពិសោធន៍ ភូមិ ឃុំ បៃតង នៅតាមបណ្ដោយព្រំដែន ដើម្បីកំណត់បានជាគោលដៅក្នុងការអនុវត្តកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនជាមួយប្រទេសជិតខាង។

១.៣. អគ្គលេខាធិការដ្ឋានអ.ជ.ប.គ.ញ ពង្រឹងយន្តការដោះស្រាយ និងសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនទ្វេភាគី និងត្រីភាគីជាមួយប្រទេសជិតខាង ដើម្បីស្វែងរកការគាំទ្រសម្រាប់សកម្មភាពត្រួតពិនិត្យគ្រឿងញៀន។

២. កម្មវិធី: ការពង្រឹងយន្តការទំនាក់ទំនងព្រំដែន (BLOs)។

សកម្មភាព:

២.១. រៀបចំកិច្ចប្រជុំ (BLOs) ឱ្យបានទៀងទាត់ជាមួយនឹងប្រទេសជិតខាង។

២.២. ពង្រឹងសមត្ថភាពរបស់មន្ត្រីដែលធ្វើការនៅតាមការិយាល័យ (BLOs) នីមួយៗ ពង្រឹងយន្តការដោះស្រាយ និងសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនទ្វេភាគី និងត្រីភាគី ជាមួយប្រទេសជិតខាង ដើម្បីស្វែងរកការគាំទ្រសម្រាប់សកម្មភាពត្រួតពិនិត្យគ្រឿងញៀន។

២.៣. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត ត្រូវដឹកនាំកិច្ចប្រតិបត្តិការនៃការិយាល័យទំនាក់ទំនងព្រំដែន (BLO) ហើយត្រូវរាយការណ៍ជូនអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ។

**ទិសដៅការយុទ្ធសាស្ត្រទី៦:** កិច្ចសហប្រតិបត្តិការអន្តរជាតិប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

១.កម្មវិធី: ការពង្រឹង និងពង្រីកការអនុវត្តកាតព្វកិច្ចដែលមានចែងក្នុងកិច្ចព្រមព្រៀង និងអនុសញ្ញាគ្រឿងញៀនអន្តរជាតិ និងបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសនានាដើម្បីស្វែងរកការគាំទ្រសម្រាប់សកម្មភាពត្រួតពិនិត្យគ្រឿងញៀន។

សកម្មភាព:

១.១. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវសហការជាមួយដៃគូអភិវឌ្ឍន៍នានា រៀបចំសិក្ខាសាលាស្តីពីការអនុវត្តអនុសញ្ញាអន្តរជាតិទាំង៣ស្តីពីបញ្ហាគ្រឿងញៀន (១៩៦១ ,១៩៧១ និង១៩៨៨) ។

១.២. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ កៀរគរប្រទេសផ្តល់ជំនួយ និងដៃគូអភិវឌ្ឍន៍នានា ឱ្យគាំទ្រសកម្មភាពត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា ទាំងក្នុងរូបភាពទ្វេភាគី និងពហុភាគី។

១.៣. អ.ជ.ប.គ.ញ ត្រូវគាំទ្រចំពោះអង្គការ UN ក្នុងការស្វែងរកជំនួយទាំងក្នុងរូបភាពទ្វេភាគី និង ពហុភាគី ។

១.៤. អ.ជ.ប.គ.ញ ត្រូវចូលរួមគ្រប់វេទិកាទាំងតំបន់ និងអន្តរជាតិ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការទប់ស្កាត់ការជួញដូរគ្រឿងញៀនខុសច្បាប់ឆ្លងកាត់កម្ពុជាទៅកាន់បណ្តាប្រទេសនានាក្នុងតំបន់។

១.៥. អ.ជ.ប.គ.ញ ចូលរួមក្នុងយន្តការត្រួតពិនិត្យគ្រឿងញៀនជាមួយបណ្តាប្រទេសអាស៊ាន។

១.៦. អ.ជ.ប.គ.ញ ត្រូវបង្កើនកិច្ចសហការជាមួយអង្គការ UNODC ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន តាមយន្តការប្រទេសមហាអនុតំបន់ទន្លេមេគង្គ។

១.៧. អ.ជ.ប.គ.ញ ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនជាមួយប្រទេសនានា នៅលើសកលលោក។

១.៨. អ.ជ.ប.គ.ញ ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនជាមួយនឹងអង្គការជាតិ និងអន្តរជាតិនានានៅក្នុងតំបន់ និងពិភពលោក។

**ទិសដៅការយុទ្ធសាស្ត្រទី៧:** ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

១. កម្មវិធី: ការពង្រឹងរចនាសម្ព័ន្ធអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

<u>សកម្មភាព:</u>

១.១. អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ពង្រឹងសមត្ថភាពមន្ត្រីរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីឱ្យមានសមត្ថភាពពេញលេញក្នុងការអនុវត្តការងារ តាមតួនាទី និងភារកិច្ច។

១.២. ពង្រឹងមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀនរបស់អគ្គលេខាធិការដ្ឋានអ.ជ.ប.គ.ញ។

១.៣. ក្រសួង និងស្ថាប័នដែលជាសមាជិកនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវមាន ផ្នែកមួយសម្រាប់ធ្វើការងារត្រួតពិនិត្យគ្រឿងញៀនតាមតួនាទី និងភារកិច្ចរបស់ខ្លួន។

១.៤. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ត្រូវពង្រឹងឱ្យមានប្រសិទ្ធភាពនូវលេខាធិការដ្ឋានរបស់ខ្លួន និងឈានទៅបង្កើតឱ្យបានគណៈកម្មាធិការត្រួត ពិនិត្យគ្រឿងញៀនក្រុង-ស្រុក-ខ័ណ្ឌ ឃុំ-សង្កាត់ ។ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត ត្រូវមានកញ្ចប់ថវិកាសម្រាប់ដំណើរការការងាររបស់ខ្លួន យោងតាមសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ០៩សសរ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤ ។

១.៥. អគ្គលេខាធិការដ្ឋានត្រូវមានយន្តការមួយសម្រាប់តាមដាន និងជម្រុញការងាររបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត។

១.៦. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវពង្រឹងក្រុមការងារអន្តរក្រសួងដែលមានស្រាប់តាមរយៈការពង្រឹងយន្តការការងារ និងការបណ្តុះបណ្តាល។ ជាមួយគ្នានេះដែរក្រុមការងាររបស់ អ.ជ.ប.គ.ញ ក៏នឹងត្រូវរៀបចំឱ្យមានតួនាទីភារកិច្ចនិងបែបបទការងារដើម្បីដំណើរការឱ្យមានប្រសិទ្ធភាព។

២. <u>កម្មវិធី:</u> ជម្រុញការរៀបចំបង្កើតក្រុមការងារ និងគណៈកម្មការជំនាញដទៃទៀតដែលមានសារៈសំខាន់ដល់សកម្មភាពត្រួតពិនិត្យគ្រឿងញៀន។

<u>សកម្មភាព:</u>

២.១. រៀបចំបង្កើត និងដំណើរការក្រុមការងារផ្សេងៗទៀតដែលមានសារៈសំខាន់ដល់ដំណើរការត្រួតពិនិត្យគ្រឿងញៀន ដើម្បីឆ្លើយតបទៅនឹងការវិវឌ្ឍន៍នៃស្ថានភាពគ្រឿងញៀន។

២.២. រៀបចំបង្កើត និងដំណើរការគណៈកម្មការជំនាញមួយចំនួនតាមការចាំបាច់ដើម្បីជួយគាំទ្រដល់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្តដែលមានករណីគ្រឿង

នៅក្នុងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

៣. <u>កម្មវិធី:</u> ការរៀបចំគោលនយោបាយលើកទឹកចិត្តដល់បុគ្គល និងអង្គភាពដែលមានស្នាដៃក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន។

<u>សកម្មភាព:</u>

៣.១. រៀបចំបង្កើត និងដំណើរការក្រុមការងារដែលមានសមាសភាពមកពីស្ថាប័នពាក់ព័ន្ធ និងអង្គភាពពាក់ព័ន្ធ ដើម្បីធ្វើការតាមដាន វាយតម្លៃលើបុគ្គល និងអង្គភាព ដែលមានស្នាដៃក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន។

# ជំពូកទី ៥
# តម្រូវការធនធាន និងហិរញ្ញវត្ថុ

## ១-តម្រូវការធនធាន:

កម្រូវការធនធានមនុស្ស និងការលើកកម្ពស់សមត្ថភាពមន្ត្រីជំនាញរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននៅតែជាកិច្ចការដ៏សំខាន់មួយ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ ដើម្បីធានាថាសកម្មភាពត្រួតពិនិត្យគ្រឿងញៀនបានស្ថិតក្រោមការចាត់ចែង គ្រប់គ្រងនិងសម្របសម្រួលរបស់ អ.ជ.ប.គ.ញ ដំណើរការបានដោយរលូន និងមានប្រសិទ្ធភាព ។ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ មានបុគ្គលិកបំរើការងារនៅតាមបណ្តានាយកដ្ឋាន និងការិយាល័យរបស់ខ្លួនដែលភាគច្រើននៃបុគ្គលិកទាំងនោះត្រូវការបណ្តុះបណ្តាលជំនាញជាច្រើន ដូចជាៈ កុំព្យូទ័រ ភាសាអង់គ្លេស ការងារគ្រប់គ្រង ការតាមដាន និងវាយតម្លៃការបណ្តុះបណ្តាលអំពីច្បាប់នីតិវិធីស៊ើបអង្កេត ការកសាងសំណុំឯកសារករណីការរក្សាវត្ថុតាង ការគ្រប់គ្រងសារធាតុគីមីផ្សំ និងជំនាញ ទាក់ទងនឹងការសំអាតប្រាក់ ។ល។

បន្ថែមលើនេះទៀតកាំបាច់ត្រូវកំណត់នូវតួនាទី និងភារកិច្ចនិងការទទួលខុសត្រូវរបស់ក្រសួងស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យបានច្បាស់លាស់។ ប្រការនេះក៏ត្រូវការពង្រឹងផងដែរ និងធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការ ការទំនាក់ទំនង ការចែករំលែកព័ត៌មាន និងការរាយការណ៍។ ការបណ្តុះបណ្តាលជំនាញផ្សេងៗទាំងក្នុង និងក្រៅប្រទេសដល់មន្ត្រីដែលពាក់ព័ន្ធជាតម្រូវការចាំបាច់បំផុត ។

## ២- តម្រូវការហិរញ្ញវត្ថុ:

២.១. ការប៉ាន់ប្រមាណថវិកាសរុប:

ការអនុវត្តផែនការយុទ្ធសាស្ត្រនេះនឹងប្រព្រឹត្តទៅបានប្រកបដោយប្រសិទ្ធភាព ចាំបាច់ត្រូវមានថវិកាចំនួន ១១៧.៧៨២.៩៦០.០០០រៀល (មួយរយដប់ប្រាំពីរពាន់ប្រាំពីររយប៉ែតសិបពីរលានប្រាំបួនរយហុកសិបពាន់រៀលគត់) ស្មើនឹង $ ២៩.៤៤៥.៧៤០ ( ម្ភៃប្រាំបួនលាន បួនរយសែសិបប្រាំពាន់ ប្រាំពីររយសែសិបដុល្លារគត់)ដែលក្នុងនោះថវិកាមួយភាគបានមកពីថវិកាជាតិ និងមួយផ្នែកទៀតតម្រូវឱ្យមានការគាំទ្រពីដៃគូអភិវឌ្ឍន៍នានា សំដៅអនុវត្តឱ្យបានជោគជ័យនូវផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន(២០១៣-២០១៥) និងរួមចំណែកក្នុងការអនុវត្តឱ្យបានជោគជ័យនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២របស់រាជរដ្ឋាភិបាលកម្ពុជា។ ថវិកានិងជំនួយបច្ចេកទេសបានមកពីសហគមន៍អន្តរជាតិផងដែរ ដើម្បីទ្រទ្រង់សកម្មភាពប្រយុទ្ធប្រឆាំងគ្រឿងញៀនជាប្រការសំខាន់បំផុតរបស់អគ្គលេខាធិការដ្ឋាន និង អ.ជ.ប.គ.ញ និងការបំពាក់មធ្យោបាយ ឧបករណ៍សម្ភារបច្ចេកទេសជំនាញផ្សេងៗទៀតដើម្បីជំរុញដំណើរការប្រយុទ្ធប្រឆាំងគ្រឿងញៀនឱ្យមានប្រសិទ្ធភាព។

# ឧបសម្ព័ន្ធទី ៦

## ការតាមដាន វាយតម្លៃ និងការធ្វើវិសោធនកម្មផែនការជាតិ

### ១. ការតាមដាន:

កិច្ចការតាមដាននឹងត្រូវធ្វើឡើងដោយអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ដែលមាននាយកដ្ឋានផែនការនិងបណ្តុះបណ្តាលជាអ្នកសម្របសម្រួល។ ការរៀបចំកិច្ចប្រជុំប្រចាំឆ្នាំរបស់ អ.ជ.ប.គ.ញ ការរៀបចំសន្និបាទបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនប្រចាំឆ្នាំ និងកិច្ចប្រជុំរវាងមន្ត្រីជំនាញសំខាន់ៗនៃ អ.ជ.ប.គ.ញ ជាមួយអ្នកជំនាញការក្នុងស្រុកនិងបរទេសជាការចាំបាច់ដើម្បីរៀបចំឱ្យមានការឯកភាពគ្នាទៅលើបញ្ជីសន្ទស្សន៍លទ្ធផល ដែលនឹងត្រូវយកទៅប្រើប្រាស់សម្រាប់ការតាមដាន និងផ្ទៀងផ្ទាត់ដំណើរការអនុវត្តផែនការជាតិ។

ផ្អែកលើផែនការលំអិតប្រចាំឆ្នាំ ព្រមទាំងបញ្ជីសន្ទស្សន៍លទ្ធផលគ្រប់គ្រាន់ហើយនោះ អង្គភាពដែលទទួលខុសត្រូវសម្រាប់ការងារនេះ អាចមានលទ្ធភាពក្នុងការតាមដាន និងត្រួតពិនិត្យនូវការអនុវត្ត។ របាយការណ៍ជាខ្សែសង្វាក់មួយ ដើម្បីគូសបញ្ជាក់ឱ្យដឹងថាអ្វីបានដំណើរការ និងអ្វីមិនបានដំណើរការទាន់ពេលវេលា និងជួយជម្រុញល្បឿនព្រមទាំងទម្រង់ទិសដៅក្នុងការអនុវត្តផែនការជាតិ។ ការបណ្តុះបណ្តាលបន្ថែមសម្រាប់មន្ត្រីទាំងឡាយដែលទទួលរ៉ាប់រងក្នុងការអនុវត្តការងារនេះគឺជាតម្រូវការចាំបាច់។

### ២. ការវាយតម្លៃ:

ការវាយតម្លៃលទ្ធផលអនុវត្តន៍ផែនការជាតិពាក់កណ្តាលអាណត្តិនៃផែនការជាតិ នឹងត្រូវធ្វើឡើងនៅក្នុងពាក់កណ្តាលឆ្នាំ២០១៨។ ការវាយតម្លៃបញ្ចប់គម្រោងក៏នឹងត្រូវបានព្រាងទុកផងដែរនៅចុងឆ្នាំ ២០១៩ ដោយអ្នកជំនាញការផ្នែកវាយតម្លៃដែលជ្រើសរើសដោយអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងដោយមានការជួយគាំទ្រពីដៃគូអភិវឌ្ឍន៍នានា។

ការវាយតម្លៃទាំងពីរខាងលើនេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍នានានឹងបង្កើតតារាងលក្ខខណ្ឌការងារទូលំទូលាយ និងច្បាស់លាស់មួយ។ អ្នកវាយតម្លៃនឹងធ្វើសេចក្តីព្រាងរបាយការណ៍អំពីការវាយតម្លៃដែលរួមបញ្ចូលនូវអនុសាសន៍គន្លឹះនានា ដើម្បីដាក់ជូនអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ពិនិត្យនិងសម្រេច។

អនុសាសន៍សមស្របទាំងឡាយ ដែលបានមកពីការវាយតម្លៃទាំងពីរនឹងត្រូវបានអនុវត្តន៍យ៉ាងហ្មឺងម៉ាត់ទៅតាមពេលវេលាដែលបានកំណត់ហើយនឹងត្រូវបានប្រើជាគំនិតគន្លឹះសំខាន់ក្នុងការរៀបចំផែនការជាតិសម្រាប់គំរោងបន្តនៃកម្មវិធីត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា។

### ៣. ការធ្វើវិសោធនកម្មផែនការជាតិ:

ផែនការជាតិបច្ចុប្បន្នអាចនឹងត្រូវបានកែសម្រួលដោយកត្តាជាច្រើនដូចខាងក្រោម:

ក/ អនុសាសន៍នានារបស់រាជរដ្ឋាភិបាលទាក់ទងទៅនឹងការត្រួតពិនិត្យគ្រឿងញៀន និងរបាយការណ៍បានមកពីការវាយតម្លៃពាក់កណ្តាលគម្រោងនាឆ្នាំ២០១៤។

ខ/ ស្ថានភាពប្រែប្រួលនៃបញ្ហាគ្រឿងញៀននៅក្នុងប្រទេសកម្ពុជា ដែលនឹងត្រូវបង្ហាញតាមរយៈការស្ទាបស្ទង់ថ្នាក់ជាតិ។

គ/ បម្រែបម្រួលថវិកាចាំបាច់សម្រាប់អនុវត្តន៍ផែនការជាតិទាំងមូល។

ឃ/ ការបន្សុីផែនការជាតិទៅនឹងអាណត្តិរបស់រាជរដ្ឋាភិបាល។

ដោយមានគាំទ្រពីដៃគូអភិវឌ្ឍន៍នានា អគ្គលេខាធិការដ្ឋានអ.ជ.ប.គ.ញ នឹងដំណើរការកែសម្រួលផែនការ ដើម្បីធានាថាកិច្ចការនេះនឹងត្រូវបានបំពេញយ៉ាងត្រឹមត្រូវ។ ជាមួយគ្នានេះដែរ ការចូលរួមផ្តល់យោបល់យ៉ាងជិតស្និទ្ធពីដៃគូសំខាន់ៗ គឺជាតម្រូវការចាំបាច់។

ក្នុងករណីដែលមានបញ្ហាពិសេសសំខាន់ណាមួយ និងមានថវិកាគ្រប់គ្រាន់ការកែសម្រួលផែនការជាតិនេះគួរត្រូវបានធ្វើនៅពាក់កណ្តាលគម្រោង។ ការកែសម្រួលនេះត្រូវបានធ្វើឡើងដោយគួបផ្សំជាមួយនឹងអនុសាសន៍ទាំងឡាយនៃការវាយតម្លៃនៅពាក់កណ្តាលផែនការ។ សិក្ខាសាលាជាផ្លូវការមួយដើម្បីអនុម័តលើផែនការជាតិដែលបានកែប្រែនេះនឹងត្រូវបានរៀបចំឡើង ដើម្បីធានាថាគ្រប់ដៃគូទាំងអស់នឹងត្រូវបានយល់ដឹងយ៉ាងច្បាស់ពីកំណែផែនការជាតិនេះ។ ជម្រើសដែលគួរពិចារណាមួយទៀត ជៀសវាងការកែសម្រួលបែបនេះ នោះគឺការបង្កើតគម្រោងដាច់ដោយឡែកមួយ ដើម្បីដោះស្រាយបញ្ហាថ្មីជាក់លាក់មួយដែលមិនបានចែងក្នុងផែនការជាតិ។ គម្រោងដាច់ដោយឡែកមួយចំនួនឬគំនិតផ្តួចផ្តើមនានាត្រូវបានរៀបចំឡើងមុនការវាយតម្លៃនៅពាក់កណ្តាលផែនការ។ បញ្ហាទាំងអស់នេះអាចត្រូវបានដាក់បញ្ចូលក្នុងពេលតែមួយទៅក្នុងផែនការជាតិដែលបានកែសម្រួល បន្ទាប់ពីការវាយតម្លៃពាក់កណ្តាលផែនការ (២០១៤) ដោយរៀបចំសិក្ខាសាលាផ្លូវការមួយដើម្បីឯកភាពលើផែនការជាតិដែលបានកែសម្រួល។

# ឧបសម្ព័ន្ធទី១

## តារាងកម្មវិធីសកម្មភាពសម្រាប់អនុវត្តន៍ទិសដៅយុទ្ធសាស្ត្រ

**<u>ទិសដៅយុទ្ធសាស្ត្រទី១៖</u>** ការអប់រំ ផ្សព្វផ្សាយ បង្ការទប់ស្កាត់ បដិសេធគ្រឿងញៀន

ត្រូវការថវិកាចំនួន: ៛ ៤.៣៧៦.០៨០ ✓

| កម្មវិធី | សកម្មភាព | សូចនាករ | ស្ថាប័នទទួលខុសត្រូវ | ពេលវេលា | | | តម្រូវការធនធាន |
|---|---|---|---|---|---|---|---|
| | | | | ២០១៣ | ២០១៤ | ២០១៥ | |
| ១.ការលើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីគ្រឿងញៀននិងផលប៉ះពាល់នៃគ្រឿងញៀន នៅក្នុងសង្គម។ | ១.១. ផ្សព្វផ្សាយដើម្បីលើកកំពស់ការយល់ដឹងជាសាធារណៈ អំពីគ្រោះថ្នាក់នៃគ្រឿងញៀន ដល់សាធារណៈជនជាពិសេស យុវវ័យដើម្បីបង្ការទប់ស្កាត់ ការប្រើប៉ំពានគ្រឿងញៀន ការបដិសេធ និងចាកចេញពីគ្រឿងញៀន និងការរីករាលដាលជំងឺអេដស៍ ដែលបណ្តាលមកពីការប្រើប៉ំពានគ្រឿងញៀនក្នុងចំណោមយុវវ័យ។ | - កំរិតយល់ដឹង ពីផលប៉ះពាល់នៃគ្រឿងញៀន និងការចម្លងជំងឺអេដស៍ ដែលបណ្តាលមកពីការប្រើប៉ំពានគ្រឿងញៀនខ្ពស់ ជាពិសេសក្នុងចំណោមយុវវ័យ។ | អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ជាអ្នកដឹកនាំ សម្របសម្រួល រួមជាមួយ៖<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងសុខាភិបាល<br>- ក្រសួងព័ត៌មាន<br>- ក្រសួងធម្មការ និងសាសនា<br>- ក្រសួងកិច្ចការនារី<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា<br>$ ៣៦៣.[illegible] |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ១.២ រៀបចំដាយន្តការច្បាស់លាស់នៅគ្រប់បណ្តាស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន (រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ) និងផ្សព្វផ្សាយពីផលប៉ះពាល់នៃគ្រឿងញៀន ជាពិសេសនៅតាមកន្លែងសំខាន់ៗមួយចំនួន ដូចជារោងភាពយន្ត ក្លឹបកំសាន្ត សាលារៀន រោងចក្រ ទីផ្សារ ទីប្រជុំជនសំខាន់ៗ និងគោលដៅដែលងាយកើតឡើងដោយគ្រឿងញៀន។ | យន្តការច្បាស់លាស់មួយបានរៀបចំនៅគ្រប់ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីផ្សព្វផ្សាយពីផលប៉ះពាល់នៃគ្រឿងញៀន នៅតាមគោលដៅសំខាន់ៗ។ | អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ជាអ្នកដឹកនាំ សម្របសម្រួល រួមជាមួយៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងសុខាភិបាល<br>- ក្រសួងព័ត៌មាន<br>- ក្រសួងទេសចរណ៍<br>- ក្រសួងការងារ<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ១៨៦.០០០ |
| | ១.៣. រៀបចំកម្មវិធីប្រឡងកំណាព្យ គំនូរ កីឡា ចំរៀង តន្ត្រី អប់រំអំពីគ្រឿងញៀននៅតាមបណ្តាខេត្តគោលដៅ។ | កម្មវិធីប្រឡងកំណាព្យ គំនូរ កីឡា ចំរៀង តន្ត្រី អប់រំអំពីគ្រឿងញៀននៅតាមបណ្តាខេត្តគោលដៅបានដំណើរការរៀបចំ។ | - ក្រសួងអប់រំ យុវជន និងកីឡា ជាអ្នកដឹកនាំ សម្របសម្រួល រួមជាមួយៈ<br>- អគ្គលេខាធិការដ្ឋាន<br>- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ១៨៣.០០០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ១.៤. រៀបចំកម្មវិធីផ្សព្វផ្សាយអប់រំអំពីច្បាប់ និងគ្រោះថ្នាក់នៃគ្រឿងញៀននៅក្នុងកម្មវិធីបុណ្យជាតិ និងអន្តរជាតិធំៗ។ | កម្មវិធីផ្សព្វផ្សាយអប់រំអំពីច្បាប់ និងគ្រោះថ្នាក់នៃគ្រឿងញៀននៅក្នុងកម្មវិធីបុណ្យជាតិនិងអន្តរជាតិធំៗ បានដំណើរការរៀបចំ។ | ក្រសួងយុត្តិធម៌ជាអ្នកដឹកនាំ សម្របសម្រួលរួមជាមួយៈ<br>- ក្រសួងសុខាភិបាល<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងព័ត៌មាន<br>- ក្រសួងទេសចរណ៍<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ១៧៧.០០០ |
| | ១.៥.សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធនានាធ្វើសកម្មភាពលើកកម្ពស់ការយល់ដឹងអំពីការកាត់បន្ថយគ្រោះថ្នាក់ (Harm Reduction) ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន ដើម្បីទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ ជំងឺអេដស៍ ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀនដល់ក្រុមអ្នកប្រើគ្រឿងញៀនដោយចាក់។ | - អគ្គលេខាធិការដ្ឋាន បានសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធនានាធ្វើសកម្មភាពកាត់បន្ថយគ្រោះថ្នាក់ (Harm Reduction) ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន ដើម្បីទប់ស្កាត់ ការរីករាលដាលជំងឺអេដស៍ ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន។<br>- ការប្រើបំពានគ្រឿងញៀន និងការរីករាលដាលមេរោគ | ក្រសួងសុខាភិបាល ជាអ្នកដឹកនាំ សម្របសម្រួលរួមជាមួយៈ<br>- ក្រសួងមហាផ្ទៃ<br>- អគ្គលេខាធិការដ្ឋាន<br>- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ៩៣.០០០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | អេដស៍/ជំងឺអេដស៍ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀនបានទប់ស្កាត់ និងកាត់បន្ថយ។ | | | | | |
| | ១.៦.សុំគោលការណ៍ពីរាជរដ្ឋាភិបាលក្នុងការផ្សព្វផ្សាយអំពីបទពិសោធន៍ល្អៗ និងវិធីសាស្ត្រ ដែលធ្លាប់បានអនុវត្តន៍នៅបណ្តាប្រទេសមួយចំនួនចំពោះក្រុមអ្នកប្រើគ្រឿងញៀនដោយចាក់។ | - បានពិចារណាអំពីវិធីសាស្ត្រនិងបទពិសោធន៍ល្អៗ ដែលធ្លាប់បានអនុវត្តនៅតាមបណ្តាប្រទេសមួយចំនួនចំពោះក្រុមដែលប្រើបំពានគ្រឿងញៀនដោយការចាក់។<br>- បានស្នើសុំគោលការណ៍ពីរាជរដ្ឋាភិបាលក្នុងការប្រើប្រាស់នូវវិធីសាស្ត្រ និងបទពិសោធន៍ល្អៗរបស់បណ្តាប្រទេសមួយចំនួន។<br>- ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តកម្មវិធី ដើម្បីផ្តល់អនុសាសន៍ និងកែលម្អ។<br>- សិក្ខាសាលាផ្សព្វផ្សាយពិបទពិសោធន៍ល្អៗពីបណ្តាប្រទេសនានា បានរៀបចំ | ក្រសួងសុខាភិបាល ជាអ្នកដឹកនាំ សម្របសម្រួលរួមជាមួយ៖<br>- ក្រសួងមហាផ្ទៃ<br>- អគ្គលេខាធិការដ្ឋាន<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ១៥០.០០០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ១.៧. សម្របសម្រួលបង្កើតយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំស្តីពីការរៀបចំឯកសារផ្សព្វផ្សាយនានាជាមួយស្ថាប័នពាក់ព័ន្ធនិងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីលើកកម្ពស់ការយល់ដឹងពីគ្រោះថ្នាក់នៃគ្រឿងញៀន និងការឆ្លងរាលដាលមេរោគអេដស៍ ជំងឺអេដស៍ ដែល បណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន ចាប់ពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ។ | - អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញបានសម្របសម្រួល និងសហការជាមួយស្ថាប័នពាក់ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ដើម្បីកសាងផែន ការយុទ្ធសាស្ត្រនិងគោលការណ៍ណែនាំស្តីពីការកសាងឯកសារផ្សព្វផ្សាយនានា។ | - អគ្គលេខាធិការដ្ឋាន អ្នកដឹកនាំ សម្របសម្រួល រួមជាមួយ៖<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងសុខាភិបាល<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ៤២០.០០០ |
| | ១.៨. សម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ ប្រព័ន្ធផ្សព្វផ្សាយ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដើម្បីឱ្យក្រុមឃោសនាចល័តមានលទ្ធភាពធ្វើយុទ្ធនាការដោយផ្ទាល់នៅតាមចំណុចគោលដៅ។ | - ក្រុមឃោសនាចល័តនៅតាមចំណុចគោលដៅសំខាន់ៗបានដំណើរការកម្មវិធីឃោសនាអប់រំ ផ្សព្វផ្សាយជាប់ជាប្រចាំ។<br>- ការយល់ដឹងអំពីគ្រោះថ្នាក់ និងផលប៉ះពាល់ដែលបណ្តាលមកពីគ្រឿងញៀនបានលើកកម្ពស់។ | អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ជាអ្នកដឹកនាំ សម្របសម្រួល រួមជាមួយ៖<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងព័ត៌មាន<br>- ក្រសួងសុខាភិបាល<br>- ក្រសួងអប់រំ យុវជន និងកីឡា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ៣៧០.៥០០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | - ក្រសួងការងារ<br>- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | | | | | |
| | ១.៩.វាយតម្លៃអំពីលទ្ធផលនៃសកម្មភាពលើកកម្ពស់ការយល់ដឹងដើម្បីពិនិត្យឡើងវិញពីគុណសម្បត្តិ និងគុណវិបត្តិ។ បទពិសោធន៍ទាំងឡាយដែលបានមកពីការវាយតម្លៃនេះនឹងយកទៅអនុវត្តន៍សម្រាប់ការងារអប់រំ និងផ្សព្វផ្សាយនាពេលអនាគត។ | - បានត្រួតពិនិត្យវាយតម្លៃលើ កម្មវិធីលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីគ្រឿងញៀន។<br>- បទពិសោធន៍ទាំងឡាយដែលបានមកពីការវាយតំលៃនេះ ត្រូវបានកែលំអសម្រាប់យកទៅអនុវត្តន៍លើការងារអប់រំនិងផ្សព្វផ្សាយនាពេលអនាគត។ | អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ជាអ្នកដឹកនាំ សម្របសម្រួល រួមជាមួយ៖<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងព័ត៌មាន<br>- ក្រសួងសុខាភិបាល<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងការងារ<br>- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ៣៥.៥០០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២. ការលើកទឹកចិត្តឱ្យមានការចូលរួមពីគ្រប់ផ្នែកនៃសង្គមក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន។ | ២.១.សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ បន្តចចាឱ្យគ្រប់ផ្នែកនៃសង្គមទាំងអស់ ជាពិសេសប្រព័ន្ធឃោសនាផ្សព្វផ្សាយ (ទូរទស្សន៍-វិទ្យុ) របស់រដ្ឋ និងឯកជន និងក្រុមហ៊ុនទូរគមនាគមន៍ចូលរួមអនុវត្តន៍ភារកិច្ចក្នុងការឃោសនាផ្សព្វផ្សាយ លើកកំពស់ការយល់ដឹងពីគ្រោះថ្នាក់នៃគ្រឿងញៀន និងទប់ស្កាត់ការរីករាលដាលនៃការប្រើប្រាស់គ្រឿងញៀន។ | ប្រព័ន្ធឃោសនាផ្សព្វផ្សាយរបស់រដ្ឋនិងឯកជន(ទូរទស្សន៍-វិទ្យុ ក្រុមហ៊ុនទូរគមនាគមន៍) បានជួយឃោសនាផ្សព្វផ្សាយ ដល់សាធារណៈជនឱ្យមានការយល់ដឹងអំពីបញ្ហាគ្រឿងញៀន និងទប់ស្កាត់ការរីករាលដាលនៃការប្រើប្រាស់គ្រឿងញៀន។ | ក្រសួងព័ត៌មាន ជាអ្នកដឹកនាំ សម្របសម្រួលរួមជាមួយ៖<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងសុខាភិបាល<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងការងារ<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងធម្មការ និងសាសនា<br>- អគ្គលេខាធិការដ្ឋាន<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ២៤៨៥០០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២.២. បន្តដាក់ខ្លឹមសារអប់រំពីគ្រឿងញៀននៅលើផលិតផលប្រើប្រាស់ និង CD/VCD ភាពយន្ត ខារ៉ាអូខេ ។ល។ | - បានដាក់ខ្លឹមសារអប់រំពីគ្រឿងញៀននៅលើផលិតផលប្រើប្រាស់ VCD/CD ខារ៉ាអូខេ ភាពយន្ត។ល។ និងលើផលិតផលនានានៅក្នុងស្រុក អំពីការយល់ដឹងផលប៉ះពាល់នៃគ្រឿងញៀនក្នុងចំណោមសាធារណជនមានការកើនឡើង។ | ក្រសួងពាណិជ្ជកម្ម ជាអ្នកដឹកនាំ សម្របសម្រួល រួមជាមួយ៖<br>- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ<br>- ក្រសួងព័ត៌មាន<br>- អគ្គលេខាធិការដ្ឋាន<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ១៩៨.០០០ |
| | ២.៣. រៀបចំឱ្យមានការប្រជុំជាទៀងទាត់ជាមួយ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល ព្រមទាំងអតីតអ្នកធ្លាប់ប្រើប្រាស់គ្រឿងញៀនដើម្បីឱ្យពួកគេចូលរួមក្នុងសកម្មភាពលើកកំពស់ការយល់ដឹងជាសាធារណៈអំពីគ្រឿងញៀន។ | អង្គការមិនមែនរដ្ឋាភិបាលសង្គមស៊ីវិលនិងអ្នកធ្លាប់ប្រើគ្រឿងញៀន បានគាំទ្រ និងចូលរួមក្នុងសកម្មភាពលើកកម្ពស់ការយល់ដឹងអំពីបញ្ហាគ្រឿងញៀន។ | អគ្គលេខាធិការដ្ឋានជាអ្នកដឹកនាំ សម្របសម្រួលរួមជាមួយ៖<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងសុខាភិបាល<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ២៦២.៥០០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២.៤.រៀបចំឱ្យមានការប្រគំតន្ត្រីអប់រំពីគ្រោះថ្នាក់នៃការប្រើប៊ពានគ្រឿងញៀនកម្មវិធីសំណួរ និងចម្លើយពីបញ្ហាគ្រឿងញៀនការឆ្លើយឆ្លងតាមទូរស័ព្ទដោយមិនបង់ថ្លៃសម្រាប់កម្ម វិធីនេះ: ការផ្តល់រង្វាន់លើកទឹកចិត្តដល់អ្នកដែលបានចូលរួមនិងវិធីសាស្ត្រដទៃទៀតក្នុងការទាក់ទាញសាធារណជនពិសេសដើម្បីបំផុសយុវវ័យឱ្យចូលរួមក្នុងកម្មវិធីសំខាន់ៗទាំងអស់ខាងលើនេះ។ | - បានសហការជាមួយស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជនរៀបចំការប្រគំតន្ត្រីវេទិកាសំណួរចម្លើយ និងការឆ្លើយឆ្លងតាមទូរស័ព្ទដោយមិនបង់ថ្លៃដល់សាធារណជន ជាពិសេសយុវជនដើម្បីទទួលបានព័ត៌មាន និងមានការយល់ដឹងអំពីគ្រោះថ្នាក់នៃការប្រើប៊ពានគ្រឿងញៀន។<br>- បានរៀបចំកម្មវិធីផ្តល់រង្វាន់លើកទឹកចិត្តដល់អ្នកដែលបានចូលរួម។<br>- បានរៀបចំវិធីសាស្ត្រផ្សេងៗទៀតក្នុងការទាក់ទាញសាធារណជនដើម្បីបំផុសយុវវ័យឱ្យចូលរួម។ | អគ្គលេខាធិការដ្ឋាន ជាអ្នកដឹកនាំ សម្របសម្រួលរួមជាមួយ៖<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងព័ត៌មាន<br>- ក្រសួងសុខាភិបាល<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ២៦២៥០០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២.៥. រៀបចំយន្តការអប់រំផ្សព្វផ្សាយពីគ្រោះថ្នាក់គ្រឿងញៀនដល់ប្រតិបត្តិករទេសចរណ៍និងអ្នកបំរើសេវាកម្មទេសចរណ៍ផ្សេងៗទៀតតាមរយៈការបញ្ជ្រាបយ៉ែនឌ័រ នៅតាមតំបន់ទេសចរណ៍សំខាន់ៗនិងគោលដៅដែលប្រឈមដល់បញ្ហាគ្រឿងញៀន។ | យន្តការអប់រំផ្សព្វផ្សាយពីគ្រោះថ្នាក់គ្រឿងញៀនដល់ប្រតិបត្តិករទេសចរណ៍ និងអ្នកបំរើសេវាកម្មទេសចរណ៍ផ្សេងៗទៀតតាមរយៈការបញ្ជ្រាបយ៉ែនឌ័រ នៅតាមតំបន់ទេសចរណ៍សំខាន់ៗ និងគោលដៅដែលប្រឈមដល់បញ្ហាគ្រឿងញៀន បានរៀបចំ។ | ក្រសួងទេសចរណ៍ ជាអ្នកដឹកនាំ សម្របសម្រួល រួមជាមួយ៖<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងទេសចរណ៍<br>- ក្រសួងព័ត៌មាន<br>- ក្រសួងសុខាភិបាល<br>- ក្រសួងកិច្ចការនារី<br>- អគ្គលេខាធិការដ្ឋាន<br>- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ១៦៥.០០០ |
| ៣. ការសម្របសម្រួលជាមួយ ក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំផែនការក្នុងការបង្កើនកម្មវិធីអប់រំអំពីបញ្ហាគ្រឿងញៀន និងការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ដែលបណ្តាល | ៣.១.រៀបចំផែនការជាក់លាក់មួយក្នុងការបង្កើនកម្មវិធីអប់រំអំពីគ្រឿងញៀន និងការរីករាលដាលជំងឺអេដស៍ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀនទៅក្នុងកម្មវិធីសិក្សាជាតិនៅគ្រប់កំរិតសិក្សាទាំងក្នុង និងក្រៅប្រព័ន្ធជាពិសេសចំពោះ: | - បានសម្របសម្រួលជាមួយក្រសួងអប់រំ យុវជននិងកីឡា និងអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ដាក់បញ្ចូលសារអប់រំពីបញ្ហាគ្រឿងញៀននិងការរីករាលដាលនៃមេរោគអេដស៍ជម្ងឺអេដស៍ទៅក្នុងកម្មវិធីសិក្សា | ក្រសួងសុខាភិបាល ជាអ្នកដឹកនាំ សម្របសម្រួល រួមជាមួយ៖<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងព័ត៌មាន<br>- អគ្គលេខាធិការដ្ឋាន<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ២៨៥.០០០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| មកពីការប្រើបំពានគ្រឿងញៀនទៅក្នុងកម្មវិធីសិក្សាជាតិនៅគ្រប់កំរិតសិក្សាទាំងក្នុង និងក្រៅប្រព័ន្ធ។ | វិធីសាស្ត្រនានាដែលធ្វើឱ្យចេះបដិសេធ និងចាកចេញពីគ្រឿងញៀន ក្នុងចំណោមសិស្ស និស្សិត និងធ្វើយ៉ាងណាឱ្យពួកគេអាចក្លាយខ្លួនជាជនបង្គោល | ជាតិទាំងក្នុង និងក្រៅប្រព័ន្ធ<br>- កម្មវិធីអប់រំបានផ្តល់ដល់សិស្ស និងនិស្សិតនូវវិធីសាស្ត្រដែលធ្វើឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយាល្អជាវិជ្ជមានប្រកបដោយភាពជឿជាក់ខ្លួនឯងនិងម្ចាស់ការក្នុងការដោះស្រាយបញ្ហា។ | | | | | |
| | ៣.២ រៀបចំយន្តការសាលារៀនបៃតងគ្មានគ្រឿងញៀនពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ។ | យន្តការសាលារៀនបៃតងគ្មានគ្រឿងញៀននៅតាមរាជធានី ខេត្តគោលដៅមួយចំនួនបានរៀបចំនិងអនុវត្តន៍ពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ។ | ក្រសួងអប់រំ យុវជន និងកីឡា ជាអ្នកដឹកនាំសម្របសម្រួល រួមជាមួយ៖<br>- ក្រសួងសុខាភិបាល<br>- អគ្គលេខាធិការដ្ឋាន<br>- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ [illegible] អភិវឌ្ឍន៍នានា) $ ២៣៧.៧៥[illegible] |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤.ការជម្រុញរៀបចំយន្តការសម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពបង្ការទប់ស្កាត់ការប្រើបំពានគ្រឿងញៀន និងចងក្រងឯកសារស្តីពីបទពិសោធន៍អំពីសកម្មភាពត្រួតពិនិត្យគ្រឿងញៀនដើម្បីធានាឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់នៅពេលអនាគត។ | ៤.១.សិក្សាស្រាវជ្រាវស្ទាបស្ទង់ជាទូទៅលើការប្រើបំពានគ្រឿងញៀនក្នុងគោលបំណង:<br>ក/ ស្វែងយល់អំពីមូលហេតុ និងផលវិបាកនៃការប្រើបំពានគ្រឿងញៀន និងការលោបឡើងវិញ។<br>ខ/វាយតម្លៃប្រសិទ្ធភាពនៃកិច្ចអន្តរាគមន៍បង្ការទប់ស្កាត់ដែលកំពុងបានអនុវត្តន៍ ។<br>គ/ ស្វែងយល់ពីបញ្ហាថ្មីៗទាំងឡាយដែលពាក់ព័ន្ធនឹងការប្រើបំពានគ្រឿងញៀននិងជំងឺអេដស៍ ដែលតម្រូវឱ្យមានកិច្ចអន្តរាគមន៍ជាបន្ទាន់។ | - បានរៀបចំយន្តការនិងបែបបទរដ្ឋបាល ចាត់តាំងជាគណៈកម្មការ និងនាយកដ្ឋានជំនាញទទួលខុសត្រូវក្នុងការតាមដាននិងវាយតម្លៃ សកម្មភាពទប់ស្កាត់ការប្រើបំពានគ្រឿងញៀន។<br>- ធ្វើការស្រាវជ្រាវនិងស្ទាបស្ទង់អំពីការប្រើបំពានគ្រឿងញៀននៅកម្ពុជា។<br>- បញ្ហា និងមូលហេតុនានាដែលនាំឈានទៅដល់ការប្រើបំពានគ្រឿងញៀន និងការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ត្រូវបានរកឃើញ ហើយដំណោះស្រាយសមស្រប និងមានប្រសិទ្ធភាពមួយបានកំណត់យកជាយុទ្ធសាស្ត្រ។<br>- បានដាក់ចេញនូវវិធានការណ៍ថ្មីៗទៀត ដើម្បីឱ្យ | អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ជាអ្នកដឹកនាំ សម្របសម្រួលរួមជាមួយៈ<br>- ក្រសួងសុខាភិបាល<br>- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ១៨៣,៥០០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ស្របតាមសភាការណ៍គ្រឿងញៀននៃដំណាក់កាលថ្មី។ | | | | | |
| | ៤.២.ធ្វើការអង្កេតជាទៀងទាត់ដើម្បីតាមដាននិន្នាការនៃការប្រើបំពានគ្រឿងញៀន និងការរីករាលដាលជំងឺអេដស៍ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន។ តួលេខនៃការអង្កេតឆ្នាំដំបូងនឹងត្រូវបានប្រើប្រាស់ជាឯកសារយោងសម្រាប់ធ្វើការប្រៀបធៀបទៅអនាគត។ | - យន្តការត្រួតពិនិត្យ តាមដាន វាយតម្លៃសកម្មភាពបង្ការទប់ស្កាត់ការប្រើបំពានគ្រឿងញៀនបានរៀបចំឡើង<br>-បានសហការជាមួយដៃគូពាក់ព័ន្ធធ្វើការអង្កេតតាមដានពីនិន្នាការនៃការប្រើបំពានគ្រឿងញៀនដើម្បីកែលំអកម្មវិធីអប់រំ និងបង្ការទប់ស្កាត់ការប្រើបំពានគ្រឿងញៀន និងការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ | អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ជាអ្នកដឹកនាំ សម្របសម្រួល រួមជាមួយ៖<br>- ក្រសួងសុខាភិបាល<br>- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ២៨៥.០០០ |
| | ៤.៣. មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀនរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវចងក្រងឯកសារព្រមទាំងផ្លាស់ប្តូរព័ត៌មាន និងបទពិសោធន៍ស្តីពី | - មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀនទទួលបាននូវព័ត៌មាន និងបទពិសោធន៍ស្តីពីសកម្មភាពត្រួតពិនិត្យគ្រឿងញៀនពីស្ថាប័ន | អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ជាអ្នកដឹកនាំ សម្របសម្រួល រួមជាមួយ៖<br>- ក្រសួងមហាផ្ទៃ | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ២៦[illegible].០០០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | សកម្មភាពត្រួតពិនិត្យគ្រឿងញៀនជាមួយស្ថា ប័នអង្គភាពពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលដទៃទៀត។អង្គភាពនោះនឹងសហការជាមួយនាយកដ្ឋាននីតិកម្ម អប់រំ និងស្តារនីតិសម្បទា ព្រមទាំងនាយកដ្ឋានពាក់ព័ន្ធនានា ដើម្បីស្វែងរកវិធីសាស្ត្រថ្មីៗដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការអប់រំសាធារណជន ជាពិសេសស្រទាប់យុវវ័យអំពីបញ្ហាគ្រឿងញៀន។ | អង្គភាពពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលនានា។<br>- មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន របស់អគ្គលេខាធិការដ្ឋានបានចងក្រង និងផ្សព្វផ្សាយឯកសារ និងវិធីសាស្ត្រថ្មីៗទាក់ទងនឹងការអប់រំសាធារណជន។ | - ក្រសួងសុខាភិបាល<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | | | | |

<u>ទិសដៅយុទ្ធសាស្ត្រទី២៖</u> ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំនិនជីវិត ការសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

ត្រូវការថវិកាចំនួន: ៛ ១៨.៨០៨.៧០០

| កម្មវិធី | សកម្មភាព | សូចនាករ | ស្ថាប័នទទួលខុសត្រូវ | ពេលវេលា | | | ប្រភពធនធាន |
|---|---|---|---|---|---|---|---|
| | | | | ២០១៦ | ២០១៧ | ២០១៨ | |
| ១.ការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍តាមរយៈសេវាសុខភាពផ្លូវចិត្ត និងគ្រឿងញៀនរបស់ក្រសួងសុខាភិបាល។ | ១.១.ពង្រីកកម្មវិធីព្យាបាលផ្អែកលើសហគមន៍តាមគំរូលទ្ធផលនៃការសិក្សានៅខេត្តបន្ទាយមានជ័យ ដោយមានការគាំទ្រពីសេវាសុខភាពផ្លូវចិត្ត និងគ្រឿងញៀនរបស់ក្រសួងសុខាភិបាលក្នុងការព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមសហគមន៍។ | - កម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍បានដាក់ឱ្យដំណើរការនៅតាមបណ្តាខេត្តនានា។<br>- អ្នកញៀនគ្រឿងញៀនមានភាពងាយស្រួលក្នុងការមកទទួលយកសេវានៅនឹងមូលដ្ឋាន។<br>- ការគ្រប់គ្រងស្ថិតិអ្នកប្រើប្រាស់គ្រឿងញៀនមានភាពល្អប្រសើរជាងមុន។ | ក្រសួងសុខាភិបាល ជាអ្នកដឹកនាំ សម្រប សម្រួល រួមជាមួយ៖<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- អគ្គលេខាធិការដ្ឋាន<br>- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ៩៨៣០.០០០ |
| | ១.២. បណ្តុះបណ្តាលមន្ត្រីអំពីជំនាញ ស្តីពីការព្យាបាលអ្នកញៀនគ្រឿងញៀននៅតាម | បុគ្គលិកជំនាញនានា ដែលពាក់ព័ន្ធនឹងការព្យាបាលផ្អែកលើសហគមន៍បាន | ក្រសួងសុខាភិបាល ជាអ្នកដឹកនាំ សម្រប សម្រួល រួមជាមួយ៖ | ✓ | ✓ | ✓ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | សហគមន៍និងតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីនេះ ដោយសហការជាមួយដៃគូនានា។ | ទទួលការបណ្តុះបណ្តាលជំនាញ។ | - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- អគ្គលេខាធិការដ្ឋាន<br>- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | | | | |
| | ១.៣. រាជរដ្ឋាភិបាលកម្ពុជា អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងអង្គការសហប្រជាជាតិ នឹងធ្វើសកម្មក្នុងការស្វែងរកការគាំទ្រថវិកាដើម្បីពង្រីកកម្មវិធីព្យាបាលតាមសហគមន៍ (CBTx) នៅគ្រប់កន្លែងអាទិភាពក្នុងប្រទេសកម្ពុជា។ | កម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ទទួលការគាំទ្រពីដៃគូអភិវឌ្ឍន៍និងបានដំណើរការ។ | អ.ជ.ប.គ.ញ ជាអ្នកដឹកនាំ សម្របសម្រួលរួមជាមួយៈ<br>- ក្រសួងសុខាភិបាល<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- អគ្គលេខាធិការដ្ឋាន<br>- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២. អនុវត្តន៍កម្មវិធីថែទាំព្យាបាលអ្នកប្រើគ្រឿងញៀនប្រភេទអាភៀនដោយឱសថមេតាដូន។ | ២.១. បន្តអនុវត្តន៍កម្មវិធីផ្តល់សេវាថែទាំព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀនប្រភេទអាភៀនរួមទាំងអ្នកដែលប្រើតាមរយៈការចាក់នឹងម្ជុលដោយឱសថមេតាដូននៅទីក្រុងភ្នំពេញ និងពិចារណាក្នុងការពង្រីកសេវាទៅកាន់កន្លែងដែលមានអាត្រានៃអ្នកប្រើប្រាស់គ្រឿងញៀនប្រភេទអាភៀនខ្ពស់។ | - កម្មវិធីផ្តល់សេវាថែទាំព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀនប្រភេទអាភៀន ដោយឱសថមេតាដូនបានពង្រីកនៅទីក្រុងភ្នំពេញ និងពង្រីកសេវាទៅកាន់កន្លែងដែលមានអាត្រានៃអ្នកប្រើប្រាស់គ្រឿងញៀនប្រភេទអាភៀនខ្ពស់។<br>- កម្មវិធីផ្តល់សេវាថែទាំព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀនប្រភេទអាភៀនដោយឱសថមេតាដូនបានពង្រីកទៅកាន់បណ្តាខេត្ត ដែលមានអាត្រានៃអ្នកប្រើប្រាស់គ្រឿងញៀនប្រភេទអាភៀនខ្ពស់។<br>- ចំនួនប្រជាជនដែលប្រើប្រាស់សេវាថែទាំព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀនប្រភេទអាភៀនដោយ ឱសថមេតាដូនមានការកើនឡើង | ក្រសួងសុខាភិបាល ជាអ្នកដឹកនាំ សម្រប សម្រួល រួមជាមួយៈ<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- អគ្គលេខាធិការដ្ឋាន<br>- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋនិងដៃគូអភិវឌ្ឍន៍នានា)<br>$ ១៥០.០០០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | - របាយការណ៍អំពីសេវារៀងរាល់៣ខែម្តងបានចងក្រង និងរាយការណ៍ឱ្យក្រសួងសុខាភិបាល និងម្ចាស់ជំនួយ។ | | | | | |
| | ២.២. បន្តកម្មវិធីផ្តល់សេវាម្ចុល និងស៊ីរ៉ាំង និងកម្មវិធីផ្តល់សេវាថែទាំ ព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀនប្រភេទអាភៀន ដោយឱសថមេតាដូន ដើម្បីកាត់បន្ថយការឆ្លងមេរោគអេដស៍ ក្នុងចំណោមអ្នកប្រើគ្រឿងញៀន និងអ្នកដែលវិលទៅរកការប្រើគ្រឿងញៀនដោយការចាក់វិញ។ | - កម្មវិធីផ្តល់សេវាម្ចុល និងស៊ីរ៉ាំង និងកម្មវិធីផ្តល់សេវាថែទាំ ព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀនប្រភេទអាភៀន ដោយឱសថមេតាដូនបានបន្ត។<br>- របាយការណ៍រៀងរាល់៣ខែម្តងបានរាយការណ៍ជូនក្រសួងសុខាភិបាល និងម្ចាស់ជំនួយតាមការចាំបាច់ | ក្រសួងសុខាភិបាល ជាអ្នកដឹកនាំ សម្រប សម្រួល រួមជាមួយ៖<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- អគ្គលេខាធិការដ្ឋាន<br>- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ១៩៥.០០០ |
| | ២.៣. បង្កើតប្រព័ន្ធមួយសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីផ្តល់សេវាថែទាំព្យាបាលអ្នកប្រើគ្រឿងញៀនប្រភេទអាភៀន ដោយឱសថមេតាដូន និងប្រសិទ្ធភាពនៃកម្មវិធីនេះ។ | - តាមការត្រួតពិនិត្យ និងវាយតម្លៃ នៃប្រធានបទនៃការបណ្តុះបណ្តាលជំនាញបានកំណត់។<br>- អន្តរាគមន៍នានាបានលើកឡើងសម្រាប់ធ្វើការកែលម្អ។ | | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ១[illegible].០០០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣. ការរៀបចំសេចក្ដីព្រាងគោលនយោបាយមួយស្ដីពីការព្យាបាលស្ដារនីតិសម្បទា និងធ្វើសមាហរណកម្មអ្នកញៀនគ្រឿងញៀន។ | ៣.១. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ រួមជាមួយក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងស្ថាប័នពាក់ព័ន្ធនានា រៀបចំសេចក្ដីព្រាងគោលនយោបាយមួយស្ដីពីការព្យាបាល ស្ដារនីតិសម្បទា និងធ្វើសមាហរណកម្មអ្នកញៀនគ្រឿងញៀន ដើម្បីដាក់ជូនរាជរដ្ឋាភិបាលអនុម័ត។ ថវិកាសម្រាប់ដំណើរការ ការព្យាបាលស្ដារនីតិសម្បទា និងធ្វើសមាហរណកម្មអ្នកញៀនគ្រឿងញៀនត្រូវស្នើទៅរាជរដ្ឋាភិបាលដោយស្ថាប័នដែលទទួលបន្ទុកការងារនេះ។ | សេចក្ដីព្រាងគោលនយោបាយមួយស្ដីពីការព្យាបាលស្ដារនីតិសម្បទា និងធ្វើសមាហរណកម្មអ្នកញៀនគ្រឿងញៀន បានរៀបចំ និងដាក់ជូនរាជរដ្ឋាភិបាលដើម្បីអនុម័ត។ | ក្រសួងសុខាភិបាល ជាអ្នកដឹកនាំ សម្របសម្រួល រួមជាមួយៈ<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- អគ្គលេខាធិការដ្ឋាន<br>- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងម្ចាស់ជំនួយដៃគូអភិវឌ្ឍន៍នានា)<br>$ ១២៨.៥០០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ៣.២. រៀបចំគោលនយោបាយស្តីពីការព្យបាលអ្នកញៀនគ្រឿងញៀននៅក្នុងពន្ធនាគារ។ | គោលនយោបាយស្តីពីការព្យាបាលអ្នកញៀនគ្រឿងញៀននៅក្នុងពន្ធនាគារបានរៀបចំ និងដំណើរការ។ | ក្រសួងសុខាភិបាល ជាអ្នកដឹកនាំ សម្រប សម្រួល រួមជាមួយ៖<br>- ក្រសួងមហាផ្ទៃ<br>- អគ្គលេខាធិការដ្ឋាន<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ១៣៥.០០០ |
| | ៣.៣. ធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំស្តីពីការអនុវត្តកម្មវិធីម្មុលស៊ីរ៉ាំងនៅកម្ពុជា ដើម្បីឱ្យកម្មវិធីនេះអាចអនុវត្តន៍បានតាមប្រព័ន្ធសុខាភិបាល។ | គោលការណ៍ណែនាំស្តីពីការអនុវត្តកម្មវិធីម្មុលសីរ៉ាំងនៅកម្ពុជា ដើម្បីឱ្យកម្មវិធីនេះអាចអនុវត្តន៍បានតាមប្រព័ន្ធសុខាភិបាលបានរៀបចំដំណើរការអនុវត្តន៍។ | ក្រសួងសុខាភិបាល ជាអ្នកដឹកនាំសម្រប សម្រួល រួមជាមួយ៖<br>- ក្រសួងមហាផ្ទៃ<br>- អគ្គលេខាធិការដ្ឋាន<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍ នានា)<br>$ ៧៨.០០០ |
| | ៣.៤. រៀបចំផែនការឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀនឆ្នាំ២០១៣-២០១៥ | ផែនការឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍ ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀនឆ្នាំ២០១៣-២០១៥ បានរៀបចំ និងដាក់ឱ្យដំណើរការ។ | ក្រសួងសុខាភិបាល ជាអ្នកដឹកនាំ សម្រប សម្រួល រួមជាមួយ៖<br>- អគ្គលេខាធិការដ្ឋាន<br>- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ២០.០០០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤.ការរៀបចំបង្កើតរចនាសម្ព័ន្ធរបស់មជ្ឈមណ្ឌលព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន។ | ៤.១.ជម្រុញឱ្យដំណើរការនូវមជ្ឈមណ្ឌលជាតិសម្រាប់ព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅខេត្តព្រះសីហនុឈានទៅកាត់បន្ថយជាបណ្តើរៗនូវមណ្ឌលបណ្តោះអាសន្ន។ | មជ្ឈមណ្ឌលព្យាបាលស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀនផ្លូវការរបស់រដ្ឋបានរៀបចំបង្កើតឡើងនៅខេត្តព្រះសីហនុ។ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាអ្នកដឹកនាំសម្របសម្រួល រួមជាមួយៈ<br>- ក្រសួងសុខាភិបាល<br>- អគ្គលេខាធិការដ្ឋាន<br>- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ២.៨២០.០០០ |
| | ៤.២. រៀបចំរចនាសម្ព័ន្ធនិងបទប្បញ្ញត្តិនានាដែលចាំបាច់សម្រាប់កិច្ចដំណើរការរបស់មជ្ឈមណ្ឌល ដោយមានការចូលរួមពី ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និង យុវនីតិសម្បទា ក្រសួងយុត្តិធម៌ និងស្ថាប័នពាក់ព័ន្ធផ្សេងៗ។ | ឯកសារបទដ្ឋាននានាទាក់ទងនឹងបទបញ្ញត្តិ សម្រាប់កិច្ចដំណើរការ របស់ការបង្កើតមជ្ឈមណ្ឌលអប់រំព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនត្រូវ បានបង្កើត។ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាអ្នកដឹកនាំសម្របសម្រួល រួមជាមួយៈ<br>- ក្រសួងសុខាភិបាល<br>- ក្រសួងយុត្តិធម៌<br>- អគ្គលេខាធិការដ្ឋាន<br>- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ១៦៧.[illegible] |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ៤.៣. បង្កើតក្រុមការងារផ្សេងៗ ដែលទទួលបន្ទុកលើវិស័យ បច្ចេកទេសដូចជា វិធីសាស្ត្រនៃការព្យាបាល ការបន្សាបជាតិពុល។ ការពិភាក្សានិងការពិគ្រោះយោបល់ជាមួយនឹងអ្នកមានវិជ្ជាជីវៈក្នុងនិងក្រៅប្រទេស នឹងត្រូវអនុវត្តន៍ដោយក្រុមការងារទាំងនោះដើម្បីស្វែងរកគោលការណ៍ឯកភាពជាតិទៅលើវិធីសាស្ត្រព្យាបាល ការបន្សាបជាតិពុលសម្រាប់ដាក់ឱ្យប្រើនៅតាមមជ្ឈមណ្ឌលជាតិ និងមណ្ឌលបណ្ដោះអាសន្ន។ | ក្រុមការងារផ្សេងៗដែលទទួលបន្ទុកលើវិស័យបច្ចេកទេសដូចជាវិធីសាស្ត្រនៃការព្យាបាល ការបន្សាបជាតិពុលដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍នានា បានបង្កើត និងដំណើរការអនុវត្តន៍ការងារ។ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាអ្នកដឹកនាំ សម្របសម្រួល រួមជាមួយ៖<br>- ក្រសួងសុខាភិបាល<br>- ក្រសួងយុត្តិធម៌<br>- អគ្គលេខាធិការដ្ឋាន<br>- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ៨៧.០០០ |
| | ៤.៤. រៀបចំកម្មវិធីបណ្ដុះបណ្ដាលបំនិនជីវិតនៅតាមមណ្ឌលបណ្ដោះអាសន្ននានារបស់រដ្ឋ និងឯកជន ព្រមទាំងតាមសហគមន៍ ។ | រៀបចំកម្មវិធីបណ្ដុះបណ្ដាលបំនិនជីវិតនៅតាមមណ្ឌលបណ្ដោះអាសន្ននាន របស់រដ្ឋ និងឯកជន ព្រមទាំងតាមសហគមន៍បានបង្កើត។ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាអ្នកដឹកនាំ សម្របសម្រួល រួមជាមួយ៖<br>-ក្រសួងសុខាភិបាល<br>-ក្រសួងយុត្តិធម៌<br>-អគ្គលេខាធិការដ្ឋាន | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ៩២.៤០០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | -គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត<br>-ដៃគូអភិវឌ្ឍន៍នានា | | | | |
| | ៤.៥ រៀបចំយន្តការសម្រាប់តាមដានការធ្វើសមាហរណកម្មរបស់អ្នកចាកចេញពីគ្រឿងញៀនវិលត្រឡប់ទៅរស់នៅក្នុងសហគមន៍ និងគ្រួសារវិញ។ | យន្តការសម្រាប់តាមដានការធ្វើសមាហរណកម្មរបស់អ្នកចាកចេញពីគ្រឿងញៀនវិលត្រឡប់ទៅរស់នៅក្នុងសហគមន៍ និងគ្រួសារវិញ បានបង្កើត ។ | អគ្គលេខាធិការដ្ឋានជាអ្នកសម្របសម្រួល រួមជាមួយៈ<br>-ក្រសួងសង្គមកិច្ច អតិតយុទ្ធជន និងយុវនីតិសម្បទា<br>-ក្រសួងមហាផ្ទៃ<br>-ក្រសួងសុខាភិបាល<br>-ក្រសួងអប់រំ យុវជន និងកីឡា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ៩៧.៤០០ |
| ៥.ការរៀបចំបង្កើតក្រុមផ្តល់ប្រឹក្សានៅតាមសហគមន៍។ | ៥.១. បង្កើតក្រុមផ្តល់ប្រឹក្សានៅតាមសហគមន៍ សម្រាប់ចុះទៅជួយពន្យល់ណែនាំអ្នកញៀនគ្រឿងញៀន នៅតាមសហគមន៍ និងគ្រួសារឱ្យមកទទួលយកការព្យាបាល និងតាមដានអ្នកប្រើប្រាស់គ្រឿងញៀនក្រោយពេល | ក្រុមផ្តល់ប្រឹក្សានៅតាមសហគមន៍ បានបង្កើតឡើង និងបានជួយពន្យល់ណែនាំអ្នកប្រើគ្រឿងញៀនឱ្យទៅទទួលយកសេវាព្យាបាលនៅមណ្ឌលសុខភាព មណ្ឌលបណ្តោះអាសន្ន អប់រំកែប្រែ | អគ្គលេខាធិការដ្ឋាន ជាអ្នកដឹកនាំ សម្របសម្រួល រួមជាមួយៈ<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ក្រសួងសុខាភិបាល | ✓ | ✓ | ✓ | (ថវិកា[illegible] [illegible]<br>អភិ[illegible]នានា)<br>$ ១[illegible].០០០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ធ្វើសមាហរណកម្ម ដើម្បីបង្ការការលោប់។ | និងបានតាមដានការប្រែប្រួលរបស់អ្នកចាកចេញពីគ្រឿងញៀន នៅតាមសហគមន៍ និងក្រុមគ្រួសារ ។ | - គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | | | | |
| | ៥.២. ក្រុមផ្តល់ប្រឹក្សាត្រូវលើកទឹកចិត្តឱ្យមានការចូលរួមពីសហគមន៍ ក្រុមគ្រួសារអ្នកធ្លាប់ប្រើគ្រឿងញៀន និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម។ ការចូលរួមនេះនឹងត្រូវបានចាត់ទុកជាផ្នែកសំខាន់មួយនៃកម្មវិធីព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍។ | កម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ត្រូវបានលើកទឹកចិត្តឱ្យមានការចូលរួមពីក្រុមគ្រួសារអ្នកធ្លាប់ប្រើគ្រឿងញៀន និងដៃគូអភិវឌ្ឍន៍នានា។ | អគ្គលេខាធិការដ្ឋាន ជាអ្នកដឹកនាំ សម្របសម្រួល រួមជាមួយៈ<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ក្រសួងសុខាភិបាល<br>- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ១២៧.០០០ |
| ៦. ការលើកកម្ពស់សមត្ថភាពមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។ | ៦.១. ជម្រុញកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌល ព្យាបាល និងស្តារនីតិសម្បទាជាមួយនឹងមជ្ឈមណ្ឌលដទៃទៀតនៅក្នុងតំបន់ និងសកលលោក ដើម្បី | សមត្ថភាព និងការយល់ដឹងរបស់មន្ត្រីបំរើការងារនៅក្នុងមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនបានលើក | អគ្គលេខាធិដ្ឋាន ជាអ្នកដឹកនាំ សម្របសម្រួល រួមជាមួយៈ<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ [illegible]៨.០០០ |

| | | | | | | |
|---|---|---|---|---|---|---|
| | លើកកម្ពស់សមត្ថភាពបច្ចេកទេសរបស់បុគ្គលិកមជ្ឈមណ្ឌលដោយមានការគាំទ្រពីក្រុមអង្គការសហប្រជាជាតិ។ | កម្ពស់សមស្របទៅតាមនិយាមរបស់អន្តរជាតិ។ | យុវនីតិសម្បទា<br>- ក្រសួងសុខាភិបាល<br>- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | | | | |
| | ៦.២.រៀបចំកម្មវិធីទស្សនកិច្ចសិក្សា ឬផ្លាស់ប្តូរបទពិសោធន៍នៅមជ្ឈមណ្ឌល ដែលមានលក្ខណៈប្រហាក់ ប្រហែលគ្នាក្នុងតំបន់ដោយមានការគាំទ្រពីក្រុមអង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិ។ | សមត្ថភាព និងការយល់ដឹងរបស់មន្ត្រីបំពេញការងារនៅក្នុងមជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនបានថ្នាក់ជាតិមានកំរិតប្រហាក់ប្រហែលនឹងមន្ត្រីជំនាញក្នុងតំបន់។ | អគ្គលេខាធិការដ្ឋាន ជាអ្នកដឹកនាំ សម្រប សម្រួល រួមជាមួយៈ<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងការពារជាតិ<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ក្រសួងសុខាភិបាល<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ១២៩.០០០ |
| | ៦.៣. រៀបចំបណ្តុះបណ្តាលដល់បុគ្គលិក ដែលបម្រើការក្នុងមជ្ឈមណ្ឌលនូវជំនាញសំខាន់ៗ ដូចជាៈ ការជួយជាបឋម ការពិគ្រោះយោបល់ | កម្មវិធីបណ្តុះបណ្តាលដល់បុគ្គលិកដែលបម្រើការក្នុងមជ្ឈមណ្ឌលនូវជំនាញសំខាន់ៗដូចជាៈ ការជួយជាបឋម ការពិគ្រោះយោ | ក្រសួងសុខាភិបាល ជាអ្នកដឹកនាំ សម្រប សម្រួល រួមជាមួយៈ<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ៧២.០០០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ការបន្សាបជាតិពុល វិធីសាស្ត្រនៃការព្យាបាលបញ្ហាគ្រឿងញៀន និងជំងឺអេដស៍ ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាលជំងឺផ្លូវចិត្ត ការផ្តល់បំនិនជីវិត និងការធ្វើសមាហរណកម្មចូលក្នុងសង្គម។ | បល់ ការបន្សាបជាតិពុល វិធី សាស្ត្រនៃការព្យាបាលបញ្ហាគ្រឿងញៀន និងជំងឺអេដស៍ ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាលជំងឺផ្លូវចិត្ត ការផ្តល់បំនិនជីវិត និងការធ្វើសមាហរណកម្មចូលក្នុងសង្គមបានដំណើរការអនុវត្តន៍។ | យុវនីតិសម្បទា<br>- អគ្គលេខាធិការដ្ឋាន<br>- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត<br>- ដៃគូអភិវឌ្ឍន៍នានា | | | | |
| | ៦.៤.បន្តរៀបចំគោលរបបនិងផ្តល់ការគាំទ្រខាងផ្នែកវេជ្ជសាស្ត្រដើម្បីពង្រឹងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋដែលមានបច្ចុប្បន្ន។ | គោលរបប និងផ្តល់ការគាំទ្រខាងផ្នែកវេជ្ជសាស្ត្រដើម្បីពង្រឹងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋដែលមានបច្ចុប្បន្នបានបន្តផ្តល់ការគាំទ្រ។ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកដឹកនាំសម្របសម្រួល រួមជាមួយ៖<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ក្រសួងសុខាភិបាល<br>- អគ្គលេខាធិការដ្ឋាន<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ១៥០,០០០ |

**វិធានការយុទ្ធសាស្ត្រទី៣៖** ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

ត្រូវការថវិកាចំនួន: ៩.៣៧៩.៧០០

| កម្មវិធី | សកម្មភាព | សូចនាករ | ស្ថាប័នទទួលខុសត្រូវ | ពេលវេលា | | | ការផ្តល់ធនធាន |
|---|---|---|---|---|---|---|---|
| | | | | ២០១៣ | ២០១៤ | ២០១៥ | |
| ១. ការជម្រុញការអនុវត្តការងារនីតិកម្មឱ្យមានប្រសិទ្ធភាព។ | ១.១. ផ្សព្វផ្សាយ និងបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ | មន្ត្រីអនុវត្តច្បាប់ត្រូវបានបណ្តុះបណ្តាលអំពីច្បាប់ត្រួតពិនិត្យគ្រឿងញៀន។ | ក្រសួងយុត្តិធម៌ ជាអ្នកដឹកនាំ សម្របសម្រួលរួមជាមួយ៖<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងការពារជាតិ<br>- អគ្គលេខាធិការដ្ឋាន<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ២០៨.០០០ |
| | ១.២. សម្របសម្រួលជាមួយដៃគូនានា ដើម្បីស្វែងរកការគាំទ្រផ្នែកបច្ចេកទេសក្នុងការរៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងអនុសញ្ញាអន្តរជាតិនានា។ | បានរៀបចំកិច្ចប្រជុំ និងសិក្ខាសាលាស្តីពីច្បាប់ត្រួតពិនិត្យគ្រឿងញៀន ដោយមានការជួយគាំទ្រពីដៃគូអភិវឌ្ឍន៍នានា។ | ក្រសួងយុត្តិធម៌ ជាអ្នកដឹកនាំ សម្របសម្រួលរួមជាមួយ៖<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងការពារជាតិ<br>- អគ្គលេខាធិការដ្ឋាន<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ៣០៣.០០០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ១.៣. អ.ជ.ប.គ.ញ ចាត់តាំងតំណាងស្របច្បាប់ដើម្បីជម្រុញតាមដានការជំនុំជំរះក្តីរបស់តុលាការនៅគ្រប់ករណីដែលពាក់ព័ន្ធបញ្ហាគ្រឿងញៀន។ | -តំណាងស្របច្បាប់របស់ អ.ជ.ប.គ.ញ ត្រូវបានចាត់តាំងដើម្បីតាមដានការអនុវត្តច្បាប់គ្រឿងញៀន។<br>-របាយការណ៍ស្តីពីការអនុវត្តច្បាប់គ្រឿងញៀនត្រូវបានរៀបចំ។ | - អ.ជ.ប.គ.ញ | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ៦០.០០០ |
| ២. ជម្រុញការអនុវត្តអនុសញ្ញាអន្តរជាតិ ឆ្នាំ ១៩៦១,១៩៧១, ១៩៨៨, ពិធីសារ ឆ្នាំ ១៩៧២ និង អនុសញ្ញាស្តីពីការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនឱ្យមានប្រសិទ្ធភាព។ | ២.១. ជម្រុញ ឱ្យបណ្តាស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល អនុវត្តន៍តាមស្មារតីអនុសញ្ញាទាំងបី ១៩៦១ ១៩៧១ ១៩៨៨ ពិធីសារ ឆ្នាំ ១៩៧២ និងអនុសញ្ញាស្តីពីការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនឱ្យមានប្រសិទ្ធិភាព. | ការអនុវត្តអនុសញ្ញាអន្តរជាតិទាំងបី និងអនុសញ្ញាស្តីពីការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន បានអនុវត្តន៍ និងបានលើកកម្ពស់។ | ក្រសួងយុត្តិធម៌ ជាអ្នកដឹកនាំ សម្របសម្រួលរួមជាមួយៈ<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងការពារជាតិ<br>- អគ្គលេខាធិការដ្ឋាន<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ ៣០.០០០ |
| | ២.២. អ.ជ.ប.គ.ញ រាយការ-ណ៍ជូនទៅរាជរដ្ឋាភិបាលកម្ពុជា និងក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ (INCB) អំពីភាពជឿនលឿននៃការអនុវត្ត | របាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តតាម ស្មារតីនៃអនុសញ្ញាអន្តរជាតិបានរាយការណ៍ទៀងទាត់ទៅរាជរដ្ឋាភិបាលនិងក្រុមប្រឹក្សាត្រួត | អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ជាអ្នកដឹកនាំ សម្របសម្រួលរួមជាមួយៈ<br>- ក្រសួងមហាផ្ទៃ | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ [illegible].000 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | តាមស្មារតីនៃអនុសញ្ញាទាំងនោះ។ | ពិនិត្យគ្រឿងញៀនអន្តរជាតិ (INCB)។ | - ក្រសួងការពារជាតិ<br>- ក្រសួងសុខាភិបាល<br>- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>- ដៃគូអភិវឌ្ឍន៍នានា | | | | |
| ៣.ការរៀបចំតាក់តែងបទដ្ឋានគតិយុត្តិនានា និងការជម្រុញការអនុវត្តច្បាប់ទាំងឡាយដែលពាក់ព័ន្ធ នឹងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឱ្យមានប្រសិទ្ធភាព។ | ៣.១.ការរៀបចំបទដ្ឋាននានាទាក់ទងនឹងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឱ្យឆាប់បានចូលជាធរមាន ដូចជា:<br>ក/ ព្រះរាជក្រឹត្យស្តីពីការបង្កើតការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។<br>ខ/ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។<br>គ/ អនុក្រឹត្យស្តីពីការបង្កើតការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការត្រួត | បទដ្ឋាននានាទាក់ទងទៅនឹងការរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងបែបបទ នានាដែលបានកំណត់នៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនបានរៀបចំបង្កើត។ | ក្រសួងយុត្តិធម៌ ជាអ្នកដឹកនាំ សម្របសម្រួលរួមជាមួយ៖<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងការពារជាតិ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- អគ្គលេខាធិការដ្ឋា<br>- ដៃគូអភិវឌ្ឍន៍នានា | ✓ | ✓ | ✓ | (ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍នានា)<br>$ 50 000 |

